ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្ដី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី ១៥ លេខ ៤ | តុលា - ធ្នូ ឆ្នាំ២០១១ | តម្លៃ ១.៥០០រ

# កសិកម្មប្រកបដោយនិរន្តរភាព និងការការពារបរិស្ថាននៅតំបន់វាលទំនាបបឹងទន្លេសាបៈ លើកកម្ពស់ការគ្រប់គ្រងទឹកចម្រុះ និងរបៀបដាំដុះរបស់កសិករ[១]

## សេចក្ដីផ្ដើម

ស្ថានភាពផ្ទៃដី ដែលមានរាងដូចបាតខ្ទះនៅប្រទេសកម្ពុជា[២] បានជួយសម្រួលដល់ការប្រមូល និងចែកចាយទឹកភ្លៀង ក្នុងទូទាំងតំបន់ភាគកណ្ដាលនៃប្រទេស ពោលគឺ វាលទំនាបបឹងទន្លេសាប និងវាលទំនាបទន្លេមេគង្គក្រោម និងលើ ដ៏ធំទូលាយ និងមានជីជាតិល្អ ដែលជាកន្លែងធ្វើកសិកម្ម ជាពិសេស ដំណាំស្រូវ។ តំបន់ខ្ពង់រាប និងភ្នំ (ដូចជា ភ្នំដងរែក នៅភាគខាងជើង និងពាយព្យ និង ភ្នំក្រវាញ នៅខាងទក្សិណ និងនិរតីនៃប្រទេស) បង្កើតបានជាផ្ទៃរងទឹកភ្លៀងធម្មជាតិធំៗចំនួន ១៦ (MOWRAM 2011) ព្រមទាំងស្ទឹង និងអូរមួយចំនួន ដែលហូរនាំទឹក និងល្បាប់ដីមានជីជាតិ ទៅចាក់នៅបឹងទន្លេសាប និង តំបន់វាលទំនាបនៅភាគកណ្ដាលប្រទេស។ វិស័យកសិកម្ម ជាសរសរទ្រូងនៃការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា និងរួមចំណែកប្រមាណ ២៩% នៃផលិតផលក្នុងស្រុកសរុប (MAFF 2010: 15)។ រាជរដ្ឋាភិបាលបានប្រឹងប្រែងជាខ្លាំង និងធ្វើវិនិយោគមូលធនយ៉ាងច្រើនក្នុងការស្ដារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រព ដែលរួមមាន៖ ប្រព័ន្ធប្រឡាយ ទំនប់តូចធំ និងស្ថានីយ៍បូមទឹកជាដើម ដើម្បីធានាការចែកចាយទឹកឲ្យបានគ្រប់គ្រាន់សម្រាប់ទាំងការធ្វើស្រែប្រាំង និងស្រែវស្សា (Nang *et al.* 2007)។ ជាលទ្ធផល ផលស្រូវប្រចាំឆ្នាំក្នុងមួយទសវត្សរ៍ចុងក្រោយនេះ បានកើនឡើងគួរឲ្យកត់សម្គាល់ ពោលគឺពី ៤លានតោនក្នុងឆ្នាំ ២០០១ ដល់ ៨លានតោនក្នុងឆ្នាំ ២០១០ (MAFF 2010: 19)។



*បច្ចុប្បន្នមានកសិករជាច្រើនបានប្រើថ្នាំសម្លាប់សត្វល្អិត ដើម្បីការពារផលដំណាំ ប្រឡាយដំណាក់អំពិល ខេត្តពោធិ៍សាត់។*

ក៏ប៉ុន្តែ ការបាត់បង់គម្របព្រៃឈើដោយសារការកែប្រែដីព្រៃក្នុងតំបន់ផ្ទៃរងទឹកភ្លៀងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងកំណើនការប្រើប្រាស់ជីគីមីដើម្បីបង្កើនទិន្នផល បាននាំឲ្យមានឱនភាពដី និងផលិតភាពកសិកម្ម។ កត្តាទាំងនេះ បានជម្រុញឲ្យស្ថាប័នជាច្រើនគិតគូរពិចារណាឡើងវិញ ពីមាគ៌ាតទៅមុខសម្រាប់ការអភិវឌ្ឍកសិកម្ម និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងដើម្បីទទួលបានផលល្អក្នុងរយៈពេលយូរអង្វែង។

ស្របពេលដែលមានការរេចរឹលតំបន់ទីជម្រាល និងកំណើនការប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF 2011) បានគូសបញ្ជាក់ថា គម្របព្រៃឈើថយចុះអស់ប្រមាណ ១៦,១% ពីឆ្នាំ១៩៦៥ ដល់ឆ្នាំ២០១០ ហើយបានរួមចំណែកធ្វើឲ្យដុះដីល្បាប់គោករាក់ផ្លូវទឹក និងថយចុះគុណភាពទឹកនៅបឹងទន្លេសាប។ ចំណែកឯកំណើនការនាំចូលជីសម្រាប់កសិកម្ម បានកើនឡើងស្ទើរមួយជាពីរ ពោលគឺពី ៦០

១ អត្ថបទនេះ រៀបរៀងដោយលោក ណាំង ភិរុណ លោក រស់ បានសុខ ជាអ្នកស្រាវជ្រាវ និងលោក អ៊ូច ឈួង ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

២ គេស្គាល់ថាជាវាលទំនាបដីល្បាប់ភាគកណ្ដាល។

## មាតិកា

កសិកម្មប្រកបដោយនិរន្តរភាព និងការពារបរិស្ថាននៅតំបន់...... ១
ចំណាកស្រុក ប្រាក់ផ្ញើទៅផ្ទះ និងការកាត់បន្ថយភាពក្រីក្រ ភស្ដុតាងពីកម្ពុជា ........ ៧
អង្គការកសិករនៅកម្ពុជា៖ តើបានជួយលើកកម្ពស់សន្តិសុខស្បៀងអ្នកក្រីក្រនៅជនបទដែរឬទេ ?........ ១៣
តាមដានសេដ្ឋកិច្ច — ស្ថានភាពក្រៅប្រទេស ........ ១៨
— ស្ថានភាពក្នុងប្រទេស........ ២០
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........ ២៨

រូបភាព ១៖ ផែនទីតំបន់សិក្សា




*ប្រភព៖ Yem 2009*

ទៅ ៨០ពាន់តោនក្នុងឆ្នាំ១៩៩៨ ដល់ ១២០ ទៅ ១៤០ពាន់តោន ក្នុងឆ្នាំ២០០៨ ដែលឆ្លុះបញ្ចាំងពីកំណើននៃការប្រើប្រាស់ជីគីមីសម្រាប់កសិកម្ម (MOE 2010)។

ការសិក្សានេះ មានគោលដៅពិនិត្យអំពីរបៀបរបបធ្វើស្រែរបស់កសិករ និងវាយតម្លៃពីនិន្នាការនៃការប្រើប្រាស់ជីគីមីក្នុងប្រព័ន្ធធារាសាស្ត្រ ១០កន្លែង នៅក្នុងខេត្តចំនួនបី នៅជុំវិញបឹងទន្លេសាប។ ស្របតាមគោលការណ៍នៃការគ្រប់គ្រងទឹកចម្រុះ (IWRM) ដែលមានចែងនៅក្នុងច្បាប់គ្រប់គ្រងធនធានទឹកឆ្នាំ ២០០៧ (MOWRAM 2007) និងគោលគំនិតនៃការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព ការសិក្សានេះក៏បានរិះរកវិធានការដែលអាចអនុវត្តបាន ព្រមទាំងកាលានុវត្តភាពល្អៗ ដើម្បីលើកកម្ពស់ផលិតកម្មស្រូវផង និងកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរមកលើធនធានធម្មជាតិ និងបរិស្ថានផង ជាពិសេសឱនភាពដី គុណភាពទឹក ធនធានជលជាតិ និងសុខភាព និងសុខុមាលភាព។

## វិធីសាស្ត្រវិភាគ និងដែនកំណត់នៃការសិក្សា

ទិន្នន័យកសិកម្មជាក់ស្តែងអំពីទិន្នផលស្រូវ ការប្រើប្រាស់ដី (ជាពិសេស ជីគីមី) ការគ្រប់គ្រង និងចែកចាយធនធានទឹក ការគ្រប់គ្រងការប្រើប្រាស់ដី និងរបៀបរបបធ្វើកសិកម្ម របស់កសិករចំនួន ២០៥គ្រួសារ ដែលបានជ្រើសរើសមកពីក្នុងប្រព័ន្ធធារាសាស្ត្រ[៣]សំខាន់ៗចំនួន ១០ នៅខេត្តកំពង់ឆ្នាំង កំពង់ធំ និងពោធិ៍សាត់ (រូបភាព ១) ត្រូវបានប្រមូល និងវិភាគ ដើម្បីកំណត់និន្នាការនៃផលិតកម្មស្រូវ និងការប្រើប្រាស់ជីកសិកម្ម (ជាពិសេសជីអសរីរាង្គ) នាពេលបច្ចុប្បន្ន និងទៅអនាគត។

ទិន្នន័យ និងព័ត៌មានដែលទទួលបានពីកសិករ សហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) អាជ្ញាធរមូលដ្ឋាន មន្ទីរធនធានទឹក និងឧតុនិយមខេត្ត (មធទឧ) និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត (មករន) និងលទ្ធផលវិភាគផ្សេងៗ ត្រូវបានយកមកប្រើ ដើម្បីពិនិត្យផលប៉ះពាល់អាចកើតមានពីបរិមាណជីដែលប្រើប្រាស់ក្នុងការដាំដុះដំណាំស្រូវ និងបញ្ហាប្រឈមចំពោះការគ្រប់គ្រងធនធានទឹក សំដៅកំណត់ចេញនូវយន្តការជាក់ស្តែងសម្រាប់ធានាឲ្យការប្រើប្រាស់ជីគីមី និងថ្នាំកសិកម្មអាចជួយបង្កើនផលិតកម្មស្រូវបានល្អប្រសើរ និងមិនប៉ះពាល់ដល់បរិស្ថាន។ រីឯបញ្ហាទាក់ទិននឹងឱនភាពដី ដោយសារការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ទីជម្រាល គឺស្ថិតនៅក្រៅដែនកំណត់នៃការសិក្សានេះ។

## បញ្ហាប្រឈមក្នុងការបង្កើនផលិតកម្មស្រូវ

### ផលិតកម្មស្រូវ

តាមធម្មតា កសិករជ្រើសរើសពូជស្រូវល្អៗសម្រាប់ដាំដុះក្នុងរដូវប្រាំង និងរដូវវស្សា។ ពូជស្រូវមានច្រើនណាស់ ហើយថ្មីៗនេះកសិករជាច្រើន ជ្រើសរើសយកពូជស្រូវស្រាលដែលផ្តល់ផលក្នុងរយៈពេលខ្លី (រយៈពេល ៩០ ទៅ ១០០ថ្ងៃ) មានទិន្នផលខ្ពស់ ហើយត្រូវការទឹកតិច។

ប្រជាជនទាំង ២០៥គ្រួសារ ដែលបានជ្រើសរើសសម្រាប់ធ្វើអង្កេត សុទ្ធតែធ្វើស្រែវស្សា និងមានតែ ៥៥ គ្រួសារប៉ុណ្ណោះដែលធ្វើស្រែប្រាំងផង ស្រែវស្សាផង។ ផ្ទៃដីដាំដុះរដូវវស្សា មាន

៣ ប្រព័ន្ធធារាសាស្ត្រ ដំណាក់អំពិល កំប៉ាង និងវត្តលៀប ស្ថិតក្នុងខេត្តពោធិ៍សាត់ ប្រព័ន្ធធារាសាស្ត្រ ត្រពាំងត្របែក តាំងក្រសាំង ស្វាយចេក និងប៉ក់ប៉ែន ស្ថិតក្នុងខេត្តកំពង់ឆ្នាំង រីឯប្រព័ន្ធធារាសាស្ត្រ រលួស ស្ទឹងជីនិត និងអូរស្វាយ ស្ថិតនៅខេត្តកំពង់ធំ។

តារាង ១៖ ទិន្នផលស្រូវគិតជាមធ្យម និងការប្រើប្រាស់ជី

| រាយមុខ | វស្សា 2008 | ប្រាំង 2008/09* | វស្សា 2009 | ប្រាំង 2009/10** |
|---|---|---|---|---|
| ចំនួនគ្រួសារ | 205 | 55 | 205 | 55 |
| ទិន្នផលគិតជាមធ្យម (តោន/ហិកតា) | 1.6 | 3.2 | 1.6 | 3.7 |
| ការប្រើប្រាស់ជីគិតជាមធ្យម (គក្រ/ហិកតា) | 68 | 80 | 174 | 194 |

*កំណត់សម្គាល់៖ * ពីខែវិច្ឆិកា ២០០៨ ដល់ខែមីនា ២០០៩; ** ពីខែវិច្ឆិកា ២០០៩ ដល់ខែមីនា ២០១០*

ប្រមាណ ៤២០ហិកតា ក្នុងនោះ ១២០ហិកតា មានលក្ខណៈអំណោយផលសម្រាប់ការធ្វើស្រែប្រាំង។ ផ្ទៃដីដាំដុះរបស់គ្រួសារនីមួយៗ (ដីស្រែ) មានចាប់ពីក្រោម ០,៥ហិកតា ដល់ ៨ហិកតា។

តារាង ១ បង្ហាញថា ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១០ ទិន្នផលស្រូវរដូវវស្សាជាមធ្យមគឺថេរ ត្រឹម ១,៦ តោន/ហិកតា រីឯទិន្នផលស្រូវរដូវប្រាំង បានកើនឡើងប្រមាណ ០,៥ តោន/ហិកតា។

ការធ្វើស្រែ ជាសកម្មភាពកសិកម្មចម្បងនៅគ្រប់ទីកន្លែងដែលជ្រើសរើសយកមកសិក្សា។ កសិករភាគច្រើនប្រើប្រាស់វិធីធ្វើស្រែបែបប្រពៃណី និងបច្ចេកទេសដាំដុះដែលមិនសូវមានប្រសិទ្ធភាព។ បញ្ហាទាំងនេះ គួបផ្សំនឹងកង្វះហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ បានធ្វើឲ្យទិន្នផលស្រូវរបស់កសិករនៅតែមានកម្រិតទាបនៅឡើយ។ ទិន្នផលស្រូវទាប និងតម្រូវការប្រព័ន្ធធារាសាស្ត្រដែលកាន់តែមានការកើនឡើង បានបង្ហាញយ៉ាងច្បាស់ថា ការអភិវឌ្ឍកសិកម្មតាមបែបផែនបច្ចេកទេសទំនើប នៅក្នុងតំបន់សិក្សា ជាតម្រូវការចាំបាច់មិនអាចខ្វះបាន។

### ការប្រើប្រាស់ជី និងនិន្នាការនៃការប្រើប្រាស់

កសិករ ប្រើប្រាស់ជីច្រើនប្រភេទដែលមានលក់នៅទីផ្សារតែប្រភេទ NPK[៤] មានប្រើច្រើនជាងគេ។ ជាទូទៅកសិករដាក់ជី ២ ឬ ៣ដង ក្នុងពេលដំណាំកំពុងលូតលាស់ ហើយចំនួនជីដែលប្រើអាស្រ័យលើលទ្ធភាពរបស់កសិករអាចលៃលកយកបាន និងពេលណាត្រូវប្រើវា ដោយមិនសូវគិតគូរអំពីគុណភាព ឬប្រភេទជី ឬតម្រូវការនៃដំណាំ ឬដីស្រែទេ។ ការដាក់ជីលើកទី ១ គឺជីដែលមាន ផូស្វាត (៦៦%) និង អ៊ុយរ៉េ (២៨%) និងលើកទី ២ ជាជីមានអ៊ុយរ៉េ (៦០%) ផូស្វាត (២៨%) និង អាសូត (ប្រមាណ ៧%) ហើយលើកទី ៣ មាន អ៊ុយរ៉េ (៤០%) និងជីសរីរាង្គផលិតក្នុងស្រុក[៥] (៤០%)។ ការប្រើប្រាស់ជីប្រចាំឆ្នាំជាមធ្យមគឺ ១២៩ គក្រ/ហិកតា (តារាង ១)។

ចំនួនជីប្រើប្រាស់លើដំណាំស្រូវ បានកើនឡើងគួរឲ្យកត់សម្គាល់ គឺពី ៨០គក្រ/ហិកតា ក្នុងឆ្នាំ២០០៨/០៩ ដល់ ១៩៤ គក្រ/ហិកតា ក្នុងឆ្នាំ២០០៩/១០ នៅរដូវប្រាំង និងពី ៦៨គក្រ/ហិកតា ក្នុងឆ្នាំ២០០៨ ដល់ ១៧៤គក្រ/ហិកតា ក្នុងឆ្នាំ២០០៩ នៅរដូវវស្សា (តារាង ១)។ កសិករនៅគ្រប់ប្រព័ន្ធធារាសាស្ត្រដែលបានសិក្សា កាន់តែមានជំនឿថា ផលិតកម្មកសិកម្មអាចកែលម្អបានតាមរយៈការប្រើប្រាស់ជីកាន់តែច្រើន។ ពួកគាត់ភ្លេចគិតថា ទន្ទឹមគ្នានឹងការផ្តល់ជីរជាតិចិញ្ចឹមបន្ថែមដល់ដីស្រែ ការដាក់ជីដែលមានសារធាតុប៉ូប៉ែនចាំបាច់ ដូចជា NPK ច្រើនហួសកម្រិត ក៏អាចធ្វើឲ្យខូចខាតដល់ដី និងដំណាំ ដូចគ្នានឹងការប្រើប្រាស់ជីមិនគ្រប់គ្រាន់ដែរ។ ឧទាហរណ៍កសិករមួយចំនួន បានឲ្យដឹងពីបញ្ហាដីស្រែមួយចំនួនដែលផ្តល់ផលតិចតួចបំផុត ដោយសារតែការប្រើប្រាស់ជីច្រើនហួសប្រមាណ (ដល់ប្រមាណ ៣០០ ទៅ ៥០០គក្រ/ហិកតា) ហើយដីនោះត្រូវតែទុកចោលពី ១ ទៅ ៣ខែ ទៅតាមប្រភេទដី ទើបវាអាចផ្តល់ផលដូចធម្មតាវិញ។

ការសិក្សាខ្លះទៀតបានបង្ហាញថា ថ្វីត្បិតតែកសិករកំពុងប្រើប្រាស់ជីកាន់តែច្រើន ក្នុងកម្រិតប្រើប្រាស់កាន់តែខ្ពស់ ប៉ុន្តែបញ្ហាកង្វះសារធាតុប៉ូប៉ែនសម្រាប់ដី និងដំណាំ នៅតែសង្កេតឃើញមាននៅឡើយ (Bell *et al.* 2004)។ ដំណាំអាចខូចខាតបានប្រសិនបើដាក់ជីច្រើនហួសកំណត់ ដោយវាធ្វើឲ្យស្លោកស្ងួត និងបំផ្លាញឫស ឬរហូតដល់ងាប់ដំណាំទៀតផង (Ecochem 2011)។ MAFF បានលើកឡើងថា ការប្រើប្រាស់ជីច្រើនហួសកំណត់ ឬមិនសមស្របក្នុង ២ទសវត្សរ៍ចុងក្រោយនេះ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និងសុខភាពមនុស្ស (MAFF 2006: 21)។ ដូច្នេះផលប៉ះពាល់លើបរិស្ថានដោយសារការប្រើប្រាស់ជីនៅតែជាបញ្ហាសំខាន់ និងត្រូវតែមានសកម្មភាពដោះស្រាយឱ្យបានសមស្រប។

## របៀបរបបអនុវត្ត និងជម្រើសរបស់កសិករ ដើម្បីឈានទៅធ្វើកសិកម្មប្រកបដោយនិរន្តរភាព

### ការគ្រប់គ្រងដី

ប្រមាណ ៦៤% នៃផ្ទៃដីដាំដុះនៅតំបន់សិក្សា ស្ថិតនៅក្នុងតំបន់វាលទំនាបនៃអាងទន្លេសាប។ ដីប្រភេទនេះ ជាទូទៅមានសណ្ឋានរាបស្មើ មានជីជាតិល្អ និងផ្តល់លក្ខណៈឲ្យទឹកអាចជ្រាបចូលបានពីកម្រិតទាបដល់មធ្យម ហើយចំណោតដីក៏បានជួយសម្រួលដល់ការស្រោចស្រព ដោយប្រើកម្លាំងទឹកហូរចុះតាមលក្ខណៈធម្មជាតិផងដែរ។ លក្ខណៈទាំងអស់នេះអំណោយផលល្អដល់ការដាំដុះដំណាំស្រូវ ទាំងនៅរដូវប្រាំង និងរដូវវស្សា។ ប៉ុន្តែដីស្រែភាគច្រើនមានទំហំតូច និងខ្ពស់ទាបមិនស្មើគ្នាទេ ហើយនៅកន្លែងខ្លះគ្មានទាំងភ្លឺស្រែព័ទ្ធជុំវិញទៀតផង។ បញ្ហានេះបានបង្កការលំបាកដល់ការរក្សាទឹក និងជីនៅក្នុងស្រែ។ កសិករមួយចំនួនបានត្អូញត្អែរពីបញ្ហាទឹកហូរចេញពីស្រែគាត់ចូលទៅស្រែនៅជាប់គ្នា ដោយហូរនាំទាំងជីដែលគាត់ទើបបាចដាក់ក្នុងស្រែគាត់ទៅជាមួយផង ហើយធ្វើឲ្យពួកគាត់ខាតបង់ទាំង ពេលវេលា

៤ "N" តំណាងឲ្យ អាសូត "P" តំណាងឲ្យ ផូស្វាត ហើយ "K" តំណាងឲ្យ ប៉ូតាស្យូម។

៥ តាមធម្មតាកសិករយកលាមកគោ ក្របី លាយនឹងសំណល់កំទេចរុក្ខជាតិផ្សេងៗ មកធ្វើជីសរីរាង្គ។

ពលកម្ម និងលុយកាក់ចំណាយលើជី ហើយទិន្នផលស្រូវ ក៏ធ្លាក់ចុះផងដែរ។ ប្រសិនបើកសិករសហការភ្ជាប់ដីស្រែគ្នាឲ្យក្លាយជាស្រែធំៗមានផ្ទៃដីរាបស្មើល្អ ដូច្នេះការដាក់ជី និងការបែងចែកទឹកអាចធ្វើបានល្អប្រសើរ ហើយទិន្នផលសរុបនឹងកើនឡើង។ ម្យ៉ាងទៀត ការធ្វើភ្លឺស្រែតូចៗនៅជុំវិញស្រែ ក៏អាចធានាឲ្យការប្រើប្រាស់ជី និងការគ្រប់គ្រងទឹកមានប្រសិទ្ធភាពល្អផងដែរ។

ការគ្រប់គ្រងដី និងការបង្កើននូវសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មដល់កសិករ គឺជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុតសម្រាប់ដោះស្រាយតម្រូវការអភិវឌ្ឍន៍ជាអាទិភាព របស់រាជរដ្ឋាភិបាល (CIDA 2009) ដូចមានបង្ហាញច្បាស់ក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត ដែលនៅទីនោះវាលស្រែត្រូវបានពង្រាបហើយរៀបចំឡើងវិញឲ្យទៅជាប្លុកដីស្រែធំៗចំនួន ៤៦ប្លុក មានផ្ទៃដីពី ៤០ ទៅ ១០០ហិកតា មានប្រឡាយរង ប្រឡាយស្រោចស្រព និងប្រព័ន្ធរំដោះទឹក ដើម្បីអាចចែកចាយទឹក និងបង្ហូរទឹកចេញយ៉ាងមានប្រសិទ្ធភាព នៅក្នុងស្រែតាមប្លុកនីមួយៗ។ ការវិភាគតាមប្រព័ន្ធកុំព្យូទ័រ (Regression) បង្ហាញថា ដីស្រែទំហំពី ០,៥ ទៅ ១ហិកតា អាចផ្តល់ទិន្នផលស្រូវប្រមាណ ២ ទៅ ៤ តោន ប្រសិនបើប្រើជីក្នុងកម្រិតសមស្របទៅតាមការណែនាំរបស់ភ្នាក់ងារផ្សព្វផ្សាយសេវាកម្មកសិកម្ម ដែលទទួលបន្ទុកនៅតាមតំបន់នីមួយៗ។ ម្យ៉ាងទៀត ដើម្បីធានាឲ្យបានទិន្នផលខ្ពស់ឲ្យមានប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព និងដើម្បីឲ្យការប្រើប្រាស់ជីមានប្រសិទ្ធភាព និងសន្សំសំចៃ កសិករក៏ត្រូវរៀបចំ និងថែទាំដីស្រែរបស់ខ្លួនឲ្យបានសមស្របផងដែរ។

## លើកកម្ពស់ការប្រើប្រាស់ជីឲ្យមានប្រសិទ្ធភាព

កសិករភាគច្រើនក្នុងតំបន់សិក្សានិយាយថា គាត់មិនធ្លាប់បានចូលរួមការបណ្តុះបណ្តាលអំពីការប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម និងវិធីធ្វើឲ្យសារធាតុបំប៉ន NPK មានតុល្យភាពល្អនោះទេ ហើយការយល់ដឹងតិចតួចសព្វថ្ងៃ គឺគាត់ទទួលបានពីអ្នកជិតខាង។ ក្នុងពេលពិភាក្សាតាមក្រុមស្នូល និងពេលសម្ភាសន៍ជាលក្ខណៈបុគ្គល កសិករបានប្រាប់ថា ការប្រើប្រាស់ជីគីមី និងថ្នាំកសិកម្មកន្លងមក គឺគាត់គ្រាន់តែធ្វើតាម ឬចម្លងតាមកសិករផ្សេងទៀតប៉ុណ្ណោះ។ ការប្រើប្រាស់ជីក្នុងបរិមាណច្រើន អាចបង្កើនការជ្រាបចូលនៃសារធាតុអាសូត ទៅក្នុងទឹកក្រោមដីដែលបន្តហូរជ្រាបចូលទៅក្នុងប្រឡាយ ទន្លេ និងបឹង ហើយសំណល់សារធាតុអាសូតដ៏ច្រើនលើសលុបនេះ អាចពន្លឿនការដុះលូតលាស់នៃពពួកសារាយ ស្លែ ដែលប៉ះពាល់ដល់មុខងារធម្មតារបស់ប្រព័ន្ធអេកូឡូស៊ីនៃទឹក ហើយបំពុល និងសម្លាប់ត្រី[៦]។

ក្នុងការអង្កេតនៅខេត្តកំពង់ធំ និងពោធិ៍សាត់ មានកសិករតិចតួចប៉ុណ្ណោះ ដែលបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងកត្តាចង្រៃតាមវិធីសាស្ត្រចម្រុះ (IPM) ផ្តល់ដោយបុគ្គលិកផ្សព្វផ្សាយបច្ចេកទេសកសិកម្ម[៧] នៃក្រសួងកសិកម្ម និងមន្ទីរកសិកម្មខេត្ត។ នៅពេលសាកសួរពីការប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម កសិករបាននិយាយថា គាត់ធ្លាប់បានរៀនសូត្រពីការធ្វើជីសរីរាង្គខ្លះដែរ ដូចជា៖ កំប៉ុស និងជីលាមកសត្វ ប៉ុន្តែដោយសារវាមានប្រសិទ្ធភាពយឺតជាងជីគីមី ពួកគាត់ក៏លែងប្រើវាទៀត។ ចំណុចនេះបង្ហាញពីតម្រូវការបណ្តុះបណ្តាលថែមទៀតក្នុងចំណោមកសិករ និងអ្នកពាក់ព័ន្ធនានា ស្តីពីការប្រើប្រាស់ថ្នាំកសិកម្ម និងជីគីមីឲ្យបានសមស្រប និងមានប្រសិទ្ធភាព។

## លើកកម្ពស់ការគ្រប់គ្រងទឹកចម្រុះ (IWRM)

### *ពង្រីកលទ្ធភាពទទួលបានទឹកប្រើប្រាស់*

ក្នុងរយៈពេល ១០ ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានបន្តការប្រឹងប្រែង និងវិនិយោគក្នុងកម្មវិធីបច្ចេកទេសជាច្រើន ដើម្បីកាត់បន្ថយការពឹងផ្អែករបស់កសិករទៅលើទឹកភ្លៀង នៅទូទាំងប្រទេស។ ទោះយ៉ាងណា ចំនួនផ្ទៃដីស្រោចស្រពគិតជាភាគរយក្នុងតំបន់សិក្សា នៅមានកម្រិតទាបនៅឡើយ។ សមត្ថភាពស្តុកទឹកសម្រាប់ធ្វើស្រែប្រាំងនៅមានកម្រិត។ តាមរយៈសិទ្ធិជាប្រពៃណី ឬសិទ្ធិស្របច្បាប់ កសិករអាចទទួលបានទឹកសម្រាប់ស្រោចស្រពដំណាំដាំដុះរបស់ពួកគាត់។ សកបទ ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងធនធានទឹក និងប្រមែប្រមូលថ្លៃសេវាកម្មធារាសាស្ត្រដែលកសិករអ្នកប្រើប្រាស់ទឹកត្រូវបង់ឲ្យ សម្រាប់ចំណាយលើប្រតិបត្តិការ និងជួយដល់ប្រជាកសិករ ក្នុងការថែទាំសំណង់ធារាសាស្ត្រ។ ប៉ុន្តែ តាមធម្មតាថ្លៃសេវាកម្មធារាសាស្ត្រនេះ កសិករខ្លះដែលជាសមាជិក សកបទ មិនបានបង់ទេ ហើយ សកបទ មិនដែលប្រមូលបានប្រាក់គ្រប់គ្រាន់ សម្រាប់យកទៅថែទាំសំណង់ធារាសាស្ត្រឡើយ (លើកលែងតែនៅប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត) ដោយសារកសិករភាគច្រើនអះអាងថា ទឹកគួរតែផ្តល់ឲ្យពួកគាត់ប្រើប្រាស់ដោយមិនគិតថ្លៃ។ ចំណុចនេះធ្វើឲ្យ សកបទ លំបាកក្នុងការចែកចាយទឹកឲ្យបានល្អប្រសើរនៅក្នុងប្រព័ន្ធធារាសាស្ត្រ ពីព្រោះពុំមានធនធានសម្រាប់ជួសជុល ពង្រីក ឬសាងសង់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រថ្មីឲ្យបានគ្រប់គ្រាន់តាមតម្រូវការជាក់ស្តែង។

ដោយទទួលស្គាល់ពីតម្រូវការ ឲ្យខាងសហគមន៍ចូលរួមកាន់តែច្រើនក្នុងការកែលម្អដំណើរការប្រព័ន្ធធារាសាស្ត្រ រដ្ឋាភិបាលបានដាក់បញ្ចូល គោលនយោបាយគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រដោយមានការចូលរួមពីអ្នកទទួលផល និងកិច្ចអភិវឌ្ឍ (PIMD)[៨] ទៅក្នុងក្របខ័ណ្ឌការគ្រប់គ្រងធនធានទឹកចម្រុះ (IWRM) ក្នុងលក្ខណៈជាសមាសភាគគោលនយោបាយជាតិដ៏សំខាន់ សម្រាប់លើកកម្ពស់ការចូលរួមរបស់កសិករ នៅក្នុងដំណើរការ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ។ គោលនយោបាយនេះ បានពង្រឹងការចូលរួមរបស់កសិករក្នុងការប្រើប្រាស់ទឹក និងការបង់ថ្លៃសេវាកម្មធារាសាស្ត្រ ដើម្បីឱ្យ សកបទ យកទៅដោះស្រាយចំណាយក្នុងដំណើរការចែកចាយ និងគ្រប់គ្រងធនធានទឹក និងការថែទាំប្រព័ន្ធធារាសាស្ត្រប្រកបដោយនិរន្តរភាព។

---

៦ ដំណើរការនេះ អាចធ្វើឲ្យទឹកឡើងស្រអាប់ និង/ឬ ប្រែពណ៌ជាបៃតង លឿងត្នោត ឬក្រហម។

៧ ក្រសួងកសិកម្ម និងមន្ទីរកសិកម្មខេត្ត បានរៀបចំការបណ្តុះបណ្តាល ២ វគ្គស្តីពី ការប្រើប្រាស់ជី គឺ មួយវគ្គ នៅខេត្តកំពង់ឆ្នាំង និងមួយវគ្គទៀត នៅខេត្តកំពង់ធំ ដោយមានការចូលរួមពីកសិករ អ្នកលក់ជី និងអ្នកពាក់ព័ន្ធផ្សេងៗនៅក្នុងផលិតផលកសិកម្ម ការប្រើប្រាស់ ឬចែកចាយ (ជាពិសេស ជីគីមី និងថ្នាំកសិកម្ម)។

៨ ផ្អែកលើឯកសារបទបង្ហាញនៅក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពី "បទពិសោធន៍រៀនសូត្របាន និងសេចក្តីសម្រេចស្តីពី PIMD" រៀបចំដោយអង្គការ សេដាក់ នៅសណ្ឋាគារភ្នំពេញ កាលពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០០៩។

***កែលម្អផលិតកម្មដំណាំ និងជីវភាពប្រជាជន***

ការប្រើប្រាស់ និងគ្រប់គ្រងធនធានដី និងទឹកប្រកបដោយប្រសិទ្ធភាព ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការលើកកម្ពស់វិស័យកសិកម្ម និងអភិវឌ្ឍន៍ជនបទនៅកម្ពុជា។ ទោះបីទឹកមានច្រើនហូរហៀរនៅរដូវវស្សាក៏ដោយ ក៏កង្វះហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រសម្រាប់ប្រមូល និងស្តុកទឹក អាចនាំឲ្យមានបញ្ហាកង្វះខាតការផ្គត់ផ្គង់ទឹក ពិសេសសម្រាប់ការធ្វើកសិកម្មនៅរដូវប្រាំង។ កសិករភាគច្រើនពឹងផ្អែកលើទឹកភ្លៀងសម្រាប់ដំណាំរដូវវស្សា។ មានតែកសិករមួយចំនួនតូចប៉ុណ្ណោះ ដែលទទួលបានទឹកស្រោចស្រពសម្រាប់ដាំដំណាំបានទាំងរដូវប្រាំង និងរដូវវស្សា។

ក្នុងចំណោមប្រព័ន្ធធារាសាស្ត្រដែលបានសិក្សាទាំង ១០ មានតែប្រព័ន្ធស្ទឹងជីនិតតែមួយគត់ ដែលមានហេដ្ឋារចនាសម្ព័ន្ធសមស្រប និងមានការគ្រប់គ្រងធនធានទឹកតាមលក្ខណៈបច្ចេកទេសបានល្អ។ រីឯប្រព័ន្ធធារាសាស្ត្រ ៩ ទៀតនោះ ជាទូទៅគឺមានទ្វារទឹកមួយ ឬទំនប់បង្វៀរមួយ និងប្រឡាយមេមួយចំនួនប៉ុណ្ណោះ ដូច្នេះ ទឹកមិនអាចស្រោចស្រពទៅដល់វាលស្រែភាគច្រើនបានទេ។ ម្យ៉ាងទៀត ២១% នៃគ្រួសារដែលបានអង្កេត ត្រូវប្រើម៉ាស៊ីនបូមទឹកដាក់ស្រែរបស់ខ្លួន។ កន្លងមក រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការស្តារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដើម្បីគ្រប់គ្រងធនធានទឹកឲ្យបានកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាព ឧទាហរណ៍ ក្នុងគោលនយោបាយគ្រប់គ្រងធនធានទឹកថ្នាក់ជាតិ រាជរដ្ឋាភិបាលមានផែនការច្បាស់លាស់ ក្នុងការពង្រីកតំបន់ស្រោចស្រពឲ្យបាន ៥០.០០០ហិកតា/ឆ្នាំ (MOWRAM 2009: 8)។

***កែលម្អប្រសិទ្ធភាពអភិបាលកិច្ចធនធានទឹក***

ការងារអភិបាលកិច្ចធនធានទឹកនាពេលបច្ចុប្បន្ន កំពុងជួបបញ្ហាកង្វះយន្តការផ្តល់ព័ត៌មានត្រឡប់ និងការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព រវាងផ្នែកពាក់ព័ន្ធកម្រិតផ្សេងៗគ្នានៃរដ្ឋាភិបាល។ ដូចមានចែងក្នុងគោលនយោបាយ PIMD សកបទ មានភារកិច្ចដំណើរការ និងថែទាំប្រព័ន្ធធារាសាស្ត្រ ព្រមទាំងធ្វើការចែកចាយ និងគ្រប់គ្រងធនធានទឹក ដោយមានការសម្របសម្រួលយ៉ាងល្អ រវាងអ្នកប្រើប្រាស់ទឹកនៅតំបន់ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម។ លើសពីនេះទៅទៀត សកបទ ដើរតួយ៉ាងសំខាន់ ជាបណ្តាញដ៏សកម្មសម្រាប់លើកកម្ពស់មុខងារនៃយន្តការអភិបាលកិច្ចតាមខ្សែបណ្តោយ ដែលតភ្ជាប់រដ្ឋបាលកណ្តាល អាជ្ញាធរខេត្ត អាជ្ញាធរមូលដ្ឋាន និងភូមិនានា ព្រមទាំងយន្តការអភិបាលកិច្ចតាមខ្សែទទឹង ដែលគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តនៅតាមមន្ទីរជំនាញខេត្ត និងអាជ្ញាធរឃុំ និងភូមិ ហើយយន្តការទាំងនេះ ក៏នឹងជួយពង្រឹងការងាររបស់ សកបទ នៅក្នុងអភិបាលកិច្ចធនធានទឹកផងដែរ។

***ការគ្រប់គ្រងធនធានទឹក និងដី និងការការពារបរិស្ថាន***

ក្របខ័ណ្ឌ IWRM តម្រូវឲ្យមានការបញ្ចូលសកម្មភាពរួមគ្នានៃតួអង្គពាក់ព័ន្ធមកពីវិស័យផ្សេងៗ រួមមាន៖ កសិករ សកបទ អាជ្ញាធរមូលដ្ឋាន មជ្ឈមណ្ឌលស្រាវជ្រាវ ក្រសួងនានា និងវិស័យឯកជន ដើម្បីសម្រេចបានការគ្រប់គ្រងធនធានដី និងទឹកប្រកបដោយនិរន្តរភាព និងការការពារបរិស្ថាន។ វិធីសាស្ត្រនេះអាចបំផុសចំណាប់អារម្មណ៍របស់តួអង្គពាក់ព័ន្ធនានា អំពីតម្រូវការ និងអត្ថប្រយោជន៍នៃការការពារបរិស្ថាន តាមរយៈដំណើរការពីក្រោមឡើងលើ និងពីលើចុះក្រោម ដើម្បីឲ្យការគិតគូរពីការអភិរក្សបរិស្ថាន ដូចជា ការប្រកួតប្រជែងនៃការអភិវឌ្ឍតាមអនុវិស័យ និងទស្សនវិស័យលើការការពារផ្ទៃរងទឹកភ្លៀងផ្នែកខាងលើ ការត្រួតពិនិត្យការបំពុល និងលំហូរទឹក សម្រាប់បម្រើនិរន្តរភាពបរិស្ថាន មានភាពស៊ីសង្វាក់គ្នាល្អនៅក្នុងការធ្វើផែនការ និងការសម្រេចចិត្ត។ គណៈកម្មាធិការ និងសមាជិករបស់ សកបទ នឹងមានឱកាសសិក្សា និងអនុវត្តយុទ្ធសាស្ត្រ និងវិធីសាស្ត្រផ្សេងៗ ក្នុងការដោះដំណាំកសិកម្មឲ្យបានសមស្រប ដូចជា ការណែនាំ និងការជ្រើសរើសពូជស្រូវសមស្រប ការអភិរក្ស និងរបៀបរៀបចំដីជាដើម។ ពួកគេក៏អាចទទួលបាននូវអត្ថប្រយោជន៍ពីកម្មវិធីរក្សាជីជាតិដី និងគ្រប់គ្រងសត្វចង្រៃ ដើម្បីបង្កើនផលិតកម្មកសិកម្ម ក៏ដូចជាធ្វើការស្តារ កែលម្អ និងថែរក្សាផលិតភាពធនធានដី និងទឹកផងដែរ។

**សេចក្តីសន្និដ្ឋាន**

ការសម្រេចបាន ការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព ជាបញ្ហាធំបំផុតមួយ សម្រាប់ប្រទេសជាច្រើនក្នុងពិភពលោក ដោយសារ វាមិនត្រឹមតែធានាបាននូវការផ្គត់ផ្គង់ស្បៀងជានិរន្តរ៍ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាបាននូវការរក្សាការពារបរិស្ថាននៅជុំវិញ ព្រមទាំងកាត់បន្ថយបាននូវផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គមកិច្ច និងសុខភាពមនុស្សថែមទៀតផង។ គោលគំនិតនេះកំពុងទទួលបានការគាំទ្រ និងគិតគូរដោះស្រាយកាន់តែច្រើន ដោយសហគមន៍កសិករសកលលោក (Gold 2007)។ ការកែលម្អការអនុវត្តគោលការណ៍ IWRM នឹងជួយដោះស្រាយបញ្ហាឱនភាពដី និងទឹក ដោយសាររបៀបរបបធ្វើកសិកម្មមិនសមស្រប។ វិធីនេះក៏នឹងជួយធានាថា ធនធានទាំងនោះនឹងមិនថយចុះនូវគុណភាពរបស់វាទេ ហើយផលិតភាពរបស់វានឹងត្រូវបានរក្សា ការពារ និងស្តារឡើងវិញ ដើម្បីផ្តល់នូវផលិតផល និងសេវាកម្មសំខាន់ៗបានយូរអង្វែង (Torkil 2004)។

ការសិក្សាបង្ហាញថា ទិន្នផលស្រូវវស្សា និងស្រូវប្រាំង មិនបានកើនឡើងគួរឲ្យកត់សម្គាល់ទេ ទោះបីជាបរិមាណជីដែលប្រើប្រាស់បានកើនឡើងជាងពីរដងក្តី។ ដូចបានបញ្ជាក់រួចមក ហើយ ការប្រើប្រាស់ជីហួសកំណត់ដោយមិនមានចំណេះដឹង និងបច្ចេកទេសត្រឹមត្រូវ និងគ្មានការគិតគូរដិតដល់ពីបញ្ហាបរិស្ថាន នឹងប៉ះពាល់ធ្ងន់ធ្ងរដល់ផលិតកម្មស្រូវ និងផលិតភាពដី ហើយអាចធ្វើឲ្យខូចដល់គុណភាពទឹកថែមទៀតផង (eutrophication)។ ការប្រើប្រាស់ឲ្យបានប្រសើរបំផុតនូវជំនាញ និងបច្ចេកទេសក្នុងមូលដ្ឋាន ដើម្បីសម្រេចបានទិន្នផលថេរក្នុងរយៈពេលវែង ការការពារបរិស្ថាន និងសុវត្ថិភាពអ្នកប្រើប្រាស់ នឹងធានាបាននូវការធ្វើកសិកម្មប្រកបដោយនិរន្តរភាព។ ការគ្រប់គ្រងដី និងទឹកប្រកបដោយប្រសិទ្ធភាពនិងស្រមស្របតាមគោលការណ៍ IWRM និងគោលនយោបាយ PIMD នឹងអាចជៀសផុតពីការចំណាយ

លើការប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម រួមទាំងការចំណាយខ្ពស់លើការសម្អាត ការបំពុលកើតចេញពីការធ្វើកសិកម្មមិនសមស្រប (Ecochem 2011)។ គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក (សកបទ) ដែលមានរចនាសម្ព័ន្ធល្អ និងមានការចូលរួមយ៉ាងផុលផុសពីកសិករ ការគ្រប់គ្រងដីស្រែបានត្រឹមត្រូវ ការទទួលបានសេវាកម្មផ្សព្វផ្សាយបច្ចេកទេសកសិកម្មល្អៗ ការមានប្រព័ន្ធប្រឡាយ និងប្រព័ន្ធដោះទឹកខ្វាត់ខ្វែងតាមលក្ខណៈបច្ចេកទេស ការមានទឹកគ្រប់គ្រាន់បន្ទាប់ពីបានស្ដារ និងអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ និងការកែលម្អរបៀបរបបដាំដុះ នឹងអាចជួយឲ្យកសិករទទួលបានទិន្នផលកាន់តែខ្ពស់ ដូចអាចឃើញច្បាស់ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលការណ៍ IWRM និងគោលនយោបាយ PIMD ក្នុងប្រព័ន្ធធារាសាស្ត្រស្ទឹងជីនិត។ កម្មវិធីគ្រប់គ្រងដី ទឹក ជីគីមី និងថ្នាំកសិកម្ម គួរតែអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីដោះស្រាយបញ្ហា និងការលំបាក ដែលកសិករភាគច្រើនកំពុងប្រឈមក្នុងតំបន់សិក្សា។ ម៉្យាងទៀត ផែនការអភិរក្សតំបន់ផ្ទៃរងទឹកភ្លៀង គួរតែរៀបចំ និងអនុវត្តឲ្យបានល្អ ហើយគុណភាពដី និងទឹក គួរតែតាមដានជាប្រចាំ ដើម្បីធានាឲ្យមានតុល្យភាពល្អ រវាងការធ្វើឲ្យដីសម្បូរដោយសារធាតុបំប៉ន ហើយ ទឹកនៅតែមានគុណភាពល្អ។

## ឯកសារយោង


ADBI (2008), "Rice Contract Farming in Cambodia: Empowering Farmers to Move Beyond the Contract Toward Independence", Discussion Paper 109 (Tokyo: ADBI) p.5

Bell, R.W. & V. Seng (2004), Water in Agriculture: Rainfed Lowland Rice-growing Soils of Cambodia, Laos and North-east Thailand, ACIAR Proceedings No. 116e http://aciar.gov.au/files/node/557/pr116--web.pdf (accessed 1/11/11) (Phnom Penh: CARDI)

CDC (2002), "NGO statement to the 2002 consultative group meeting on Cambodia.Agricultural Development" http://www.cdc-crdb.gov.kh/cdc/ngo_statement/agriculture_rural.htm (accessed 19/10/11) (Phnom Penh: RGC)

CIDA (2009), "Effective agriculture extension", http://www.acdi-cida.gc.ca/acdi-cida/acdi-cida.nsf/eng/NAD-99153130-QW9 (accessed 23/9/2011)

Ecochem (2011), "Environmental risks of fertilizer use", http://www.ecochem.com/t_organic_fert.html (accessed 10/5/2011)

Gliessman, S. R. (1998), "An Ecological Definition of Sustainable Agriculture", Principles of Agroecology and Sustainability (1998). http://agroecology.org/Principles_Def.html (accessed 5/10/11)

Gold, M. V. (2007), *Sustainable Agriculture: Definitions and Terms,* Special Reference Briefs Series No. SRB 99-02 (Beltsville,MD: US Department of Agriculture) http://www.nal.usda.gov/afsic/pubs/terms/srb9902.shtml (accessed: 10/5/2011). USDA.

IWMI & GWP (2005), "Reducing Poverty through Intergrated Ground and Surface Water Management", Water Policy Briefing, Issue 13, http://www.iwmi.cgiar.org/publications/Water_Policy_Briefs/PDF/wpb13.pdf (accessed 17/10/11) (Colombo, Sri Lanka: GWP & IWMI)

Khun S. (2002), "Disaster Management in Cambodia" (Phnom Penh: National Committee for Disaster Management)

MAFF (2010), "Annual Report of Agriculture, Fisheries and Forestry Sector for 2009-10 and Direction for 2010-2011" (Phnom Penh: MAFF)

MAFF (2011), "Draft National Action Plan to Combat Land Degradation" (Phnom Penh: MAFF)

MAFF (2006), "Third National Report to the Convention on Combat Desertification", http://www.unccd.int/cop/reports/asia/national/2006/cambodia-eng.pdf (accessed 19/10/11) (Phnom Penh: MAFF)

MOE (2009), "Cambodia Environment Outlook" (Phnom Penh: MOE)

MOE (2006), "Cambodia National Environmental Performance Assessment" (Phnom Penh: UNEP & RRC-AP)

MOE (2010), "Unsustainable Agricultural Practice", presentation handout (Phnom Penh: MOE)

MOWRAM (2009), "Action Plan on the Management and Development of Water Resources and Meteorology" in the Second Implementation of Government Regtangular Strategy 2009-2013 (Phnom Penh: MOWRAM)

MOWRAM (2011), "Draft Sub Decree on River Basin Management" (Phnom Penh: MOWRAM)

MOWRAM (2007), "Law on Water Resources Management of the Kingdom of Cambodia" (Phnom Penh: MOWRAM)

Nang Phirun, Khiev Daravy, Philip Hirsch & Isabelle Whitehead (2011), "Improving the Governance of Water Resources in Cambodia: A Stakeholder Analysis - Understanding Stakeholders" Roles, Perceptions and Constraints for Effective Irrigation and Catchment" (Phnom Penh: CDRI)

NCSC (2005), "Environment and Socio-economy Report", (Phnom Penh: MOE)

Torkil, JØnch-Clausen (2009), "Cambodia: Preparing the Water Resources Management (Sector) Project", http://www.adb.org/Documents/Reports/Consultant/38558-CAM/38558-01-cam-tacr.pdf (accessed 23/10/11) ( Phnom Penh: ADB)

Torkil, JØnch-Clausen (2004), "Integrated Water Resources Management (IWRM) and Water Efficiency Plans by 2005: Why, What and How?" http://hqweb.unep.org/civil_society/GCSF8/pdfs/IWRM_water_efficiency.pdf (accessed 21/10/11) (Stockholm: GWP)

UNEP (2011), "Support for Sustainable Smallholder Agriculture Needed to Fuel an 'Evergreen Revolution'" http://www.unep.org/Documents.Multilingual/Default.Print.asp?DocumentID=2641&ArticleID=8755&l=en (accessed 10/5/2011) (Rome: UNEP)

World Bank (2007), "Strategic Environmental Assessment. Integrated Water Resources Management and Development" (Washington, DC: World Bank)

Yem Dararath (2009), presentation handout at the National Consultative Workshop on "Planned Activities 2009-2011 for Water Resources Management Research Capacity Development Programme" organised by CDRI at Phnom Penh Hotel on 9 December 2009 (Phnom Penh: CDRI)

# ចំណាកស្រុក ប្រាក់ផ្ញើទៅផ្ទះ និងការកាត់បន្ថយភាពក្រីក្រ៖ ករណីសិក្សាពីកម្ពុជា[១]

ខ្លឹមសារសង្ខេប៖ ការសិក្សានេះ ប្រើប្រាស់ទិន្នន័យអង្កេតគ្រួសារមានលក្ខណៈតំណាងឲ្យទូទាំងប្រទេស អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២០០៧ ដើម្បីពិនិត្យពីផលប៉ះពាល់នៃប្រាក់ផ្ញើទៅផ្ទះមានប្រភពពីក្នុង និងក្រៅប្រទេស ទៅលើភាពក្រីក្រ ដោយប្រើប្រាស់ផលធៀបនៃភាពក្រីក្រ គម្លាតភាពក្រីក្រ និងគម្លាតភាពក្រីក្រលើកជាការ៉េ (squared poverty gap)។ លទ្ធផលអង្កេតបង្ហាញថា ទាំងប្រាក់ផ្ញើពីក្នុង និងក្រៅប្រទេស ជួយកាត់បន្ថយទំហំ កម្រិត និងលក្ខណៈធ្ងន់ធ្ងរនៃភាពក្រីក្រ។ ប្រាក់ផ្ញើទៅផ្ទះ ជះឥទ្ធិពលទៅលើលក្ខណៈធ្ងន់ធ្ងរនៃភាពក្រីក្រ ខ្លាំងជាងទៅលើអត្រានៃភាពក្រីក្រ។ លទ្ធផលស្រាវជ្រាវនេះ បង្ហាញថា ប្រាក់ផ្ញើទៅផ្ទះរបស់ជនចំណាកស្រុកទៅក្រៅប្រទេស មានប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្រ ខ្លាំងជាងប្រាក់ផ្ញើទៅផ្ទះរបស់ជនចំណាកស្រុកក្នុងប្រទេស។

## សេចក្ដីផ្ដើម

ចំណាកស្រុកនៅកម្ពុជា ភាគច្រើនជាចំណាកស្រុកក្នុងប្រទេស។ វិទ្យាស្ថានជាតិស្ថិតិ (2004) បានឲ្យដឹងថា ៣៥% នៃប្រជាជនសរុប ជាជនចំណាកស្រុកក្នុងប្រទេស ដែលខ្ពស់ជាងអត្រាក្នុងឆ្នាំ១៩៩៨ ដល់ទៅ ៤ឯកតាភាគរយ។ យុវជនដែលមានអាយុពី១៥-២៥ឆ្នាំ តំណាងឲ្យ ១៨% នៃប្រជាជនសរុប ប៉ុន្តែរួមចំណែកដល់ទៅ ៣០% នៃជនចំណាកស្រុក។

ទីដៅនៅបរទេសចម្បងរបស់ជនចំណាកស្រុកកម្ពុជា គឺប្រទេសថៃ។ ជនចំណាកស្រុកទៅថៃប្រមាណ ៩០% ជាជនចំណាកស្រុកមិនស្របច្បាប់ (គ្មានឯកសារត្រឹមត្រូវ)។ ទោះជាមានអនុស្សរណៈយោគយល់ស្ដីពី ពលករចំណាកស្រុកដែលរដ្ឋាភិបាលថៃ និងកម្ពុជា បានចុះហត្ថលេខាកាលពីឆ្នាំ២០០៣ ក្ដី ក៏ចំនួនជនចំណាកស្រុកមិនស្របច្បាប់ មិនទំនងជាធ្លាក់ចុះនោះទេ ដោយសារការចំណាយខ្ពស់ទៅលើទីភ្នាក់ងារជ្រើសរើសពលករ ទិដ្ឋាការ និងការចុះបញ្ជី (Chan 2009a)។ ម៉ាឡេស៊ី និងសាធារណៈរដ្ឋកូរ៉េ ក៏ជាគោលដៅចម្បងណាស់ដែរ។ ទីភ្នាក់ងារជ្រើសរើសពលករឯកជន ជាអ្នករៀបចំសម្រួលការធ្វើចំណាកស្រុកទៅប្រទេសទាំងពីរនេះ។ ពលករចំណាកស្រុកកម្ពុជាទៅម៉ាឡេស៊ីភាគច្រើន មានឯកសារត្រឹមត្រូវ ប៉ុន្តែក្រោយមកជាច្រើននាក់ក៏បានបាត់បង់ភាពស្របច្បាប់។ ពលករចំណាកស្រុកកម្ពុជាទាំងអស់ដែលធ្វើការនៅសាធារណៈរដ្ឋកូរ៉េ ជាពលករស្របច្បាប់ (Maltoni 2007)។ ពលករចំណាកស្រុកកម្ពុជាក៏មានទៅធ្វើការនៅហុងកុង តៃវ៉ាន់ អារ៉ាប៊ីសាអ៊ូឌីត និងកាតា ដែរ ប៉ុន្តែពុំទាន់មានតួលេខច្បាស់នៃប្រជាជនកម្ពុជាទាំងអស់ដែលរស់នៅ និងធ្វើការនៅទីនោះទេ។

យោងតាម Ratha and Mohapatra (2009) ប្រាក់ផ្ញើជាផ្លូវការពីក្រៅប្រទេស មានដល់ ៣២៥លានដុល្លារ ក្នុងឆ្នាំ២០០៨ ដែលខ្ពស់ជាងប្រាក់ផ្ញើកាលពី ១០ឆ្នាំមុន ប្រមាណ៣ដង។ ទំហំនៃប្រាក់ផ្ញើទៅផ្ទះជាផ្លូវការពីបរទេស បានកើនឡើង ប៉ុន្តែមានការយកចិត្តទុកដាក់តិចតួចនៅឡើយ អំពីផលប៉ះពាល់ខាងសេដ្ឋកិច្ចនៃការផ្ទេរប្រាក់នេះ មកលើសេដ្ឋកិច្ចគ្រួសារ។ ការសិក្សានេះ ព្យាយាមធ្វើការវាស់វែងពីឥទ្ធិពលនៃប្រាក់ផ្ញើទៅផ្ទះ មកពីបរទេស និងពីក្នុងប្រទេស ទៅលើភាពក្រីក្រ។

## ទិន្នន័យ និងលទ្ធផលរកឃើញជាក់ស្ដែង

ការសិក្សានេះ បានប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៧ ដែលប្រមូលដោយវិទ្យាស្ថានជាតិ ស្ថិតិ។ អង្កេតនេះ មានលក្ខណៈតំណាងឲ្យទូទាំងប្រទេស ព្រោះបានធ្វើអង្កេតលើ ៣៥៩៣គ្រួសារ ក្នុងនោះមាន ២២២៨គ្រួសារនៅជនបទ។ អង្កេតនេះ ផ្ដល់ព័ត៌មានលំអិតជាច្រើន រួមមាន លក្ខណៈគ្រួសារ ការចំណាយលើអាហារ និងទំនិញមិនមែនអាហារ ទ្រព្យជាប់លាប់ សត្វចិញ្ចឹម ផលិតកម្មកសិកម្មគ្រួសារ ការប្រមូលអនុផលព្រៃឈើ ផលិតកម្មមិនមែន កសិកម្មផ្សេងទៀត ការងារមានប្រាក់ខែ និងប្រាក់ផ្ញើទៅផ្ទះ។

ទោះយ៉ាងនេះក្ដី CSES នេះ មិនមែនរៀបចំឡើងជាអង្កេតលើចំណាកស្រុក ឬប្រាក់ផ្ញើទៅផ្ទះនោះទេ ដូច្នេះក៏គ្មានការប្រមូលព័ត៌មាន អំពីលក្ខណៈសំគាល់របស់ជនចំណាកស្រុក ដូចជា អាយុ ការអប់រំ ឬប្រាក់ចំណូលរកបាននៅឆ្ងាយពីផ្ទះនោះដែរ។ ក្នុងអង្កេតនេះ មានតែ ២សំណួរប៉ុណ្ណោះ ដែលទាក់ទិននឹងប្រាក់ផ្ញើទៅផ្ទះ៖ (១) ក្នុងរយៈពេល១២ខែចុងក្រោយនេះ តើគ្រួសាររបស់អ្នកទទួលបានប្រាក់ផ្ញើក្នុងស្រុកចំនួនប៉ុន្មានពីសាច់ញាតិ និងអ្នកផ្សេងទៀត? (២) ក្នុងរយៈពេល ១២ខែចុងក្រោយនេះ តើគ្រួសាររបស់អ្នកទទួលបានប្រាក់ផ្ញើពីបរទេសចំនួនប៉ុន្មានពីសាច់ញាតិ និងអ្នកផ្សេងទៀត? ទោះយ៉ាងនេះក្ដី ព័ត៌មានពីចំណូល និងចំណាយរបស់គ្រួសារ អាចឲ្យយើងកំណត់បានពីផលប៉ះពាល់នៃប្រាក់ផ្ញើទៅផ្ទះទៅលើភាពក្រីក្រ។

តារាង១ បង្ហាញថា មាន ២៧៤៣គ្រួសារ (៧៦,៣% នៃគ្រួសារគំរូតាងសរុប) មិនបានទទួលប្រាក់ផ្ញើទៅផ្ទះទេ ហើយ ៧១៤គ្រួសារ (១៩,៩%) ទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និង ១៥៣គ្រួសារ (៤,៣%) ទទួលបានប្រាក់ផ្ញើពីបរទេស។ ក្នុងចំណោមគ្រួសារទទួលបានប្រាក់ផ្ញើទៅផ្ទះ មានតែ ១៧គ្រួសារប៉ុណ្ណោះ ដែលទទួលបានទាំងប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស។

---

[១] អត្ថបទនេះ រៀបរៀងដោយ លោក តុង គឹមស៊ុន ជាអ្នកស្រាវជ្រាវ និងជាអ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់ បណ្ឌិត Hossein Jalilian និងអ្នកកែសម្រួលមកពីខាងក្រៅវិទ្យាស្ថាន ដែលបានជួយផ្ដល់មតិលើអត្ថបទព្រាងពីដំបូង។

តារាង ១៖ ប្រភពប្រាក់ចំណូលសម្រាប់គ្រួសារបានទទួល និងមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ (រៀល/នាក់/ថ្ងៃ)

| ប្រភព | មិនបានទទួលប្រាក់ផ្ញើទៅផ្ទះ | ទទួលប្រាក់ផ្ញើពីក្នុងស្រុក | ទទួលប្រាក់ផ្ញើពីបរទេស |
|---|---|---|---|
| សត្វចិញ្ចឹម | 328.47<br>(2101.15) | 591.92<br>(2077.98) | 240.33<br>(684.80) |
| នេសាទ | 113.21<br>(539.31) | 90.89<br>(579.86) | 60.43<br>(199.48) |
| ព្រៃឈើ | 136.06<br>(372.37) | 146.60<br>(207.08) | 92.83<br>(247.66) |
| ផលិតកម្មមិនមែនកសិកម្ម | 2197.09<br>(19,762.08) | 1852.08<br>(26,091.79) | 2820.01<br>(8029.68) |
| ប្រាក់ផ្ញើពីក្នុងស្រុក | 0 | 619.48<br>(1366.47) | 86.06<br>(373.34) |
| ប្រាក់ផ្ញើពីបរទេស | 0 | 23.438<br>(254.82) | 1938.62<br>(3167.31) |
| បៀវត្សរ៍ | 1807.89<br>(6009.99) | 1686.81<br>(4229.51) | 3775.56<br>(14,941.30) |
| ផលិតកម្មផ្ទាល់ខ្លួនសម្រាប់ប្រើប្រាស់ | 52.81<br>(69.74) | 66.13<br>(75.39) | 59.22<br>(121.76) |
| ផ្សេងៗ | 336.08<br>(3225.52) | 566.55<br>(10711.07) | 426.39<br>(1947.11) |
| ប្រាក់ចំណូលសរុប | 4971.61<br>(21,116.23) | 5643.93<br>(28,543.99) | 9499.50<br>(17,364.90) |
| គំរូតាង | 2743 | 714 | 153 |

*សម្គាល់៖ គំលាតស្តង់ដា (Standard deviations) មានបង្ហាញនៅក្នុងវង់ក្រចក។*
*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ*

ប្រាក់ផ្ញើពីក្នុងស្រុក មានចំណែក ២,៣% និង ពីបរទេសមាន ១,៦% នៅក្នុងប្រាក់ចំណូលសុទ្ធរបស់គ្រួសារគំរូតាងទាំងអស់។ ប្រាក់ផ្ញើពីក្នុងស្រុក មាន ១០,៩% និងពីបរទេសមាន ០,៤% នៅក្នុងប្រាក់ចំណូលសុទ្ធសរុបនៃ ៧១៤គ្រួសារដែលទទួលបានប្រាក់ផ្ញើពីក្នុងស្រុក។ សម្រាប់ ១៥៣គ្រួសារដែលទទួលបានប្រាក់ផ្ញើពីបរទេស ប្រាក់នេះមានចំណែក ២០,៤% នៅក្នុងប្រាក់ចំណូលសុទ្ធសរុប រីឯប្រាក់ផ្ញើពីក្នុងស្រុកមានត្រឹម ០,៩%។ ជាមធ្យម ក្នុងឆ្នាំ២០០៧ ប្រាក់ផ្ញើទៅផ្ទះសម្រាប់គ្រួសារទទួលប្រាក់ផ្ញើពីក្នុងស្រុក មានចំនួន ៦២០រៀល/នាក់/ថ្ងៃ ហើយសម្រាប់គ្រួសារទទួលប្រាក់ផ្ញើពីបរទេសគឺ ១៩៤០រៀលនាក់/ថ្ងៃ។ តួលេខនេះគ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ពីព្រោះពលករនៅបរទេសអាចរកប្រាក់បានច្រើនជាងពលករនៅកម្ពុជា។

តារាង ១ បង្ហាញទៀតថា គ្រួសារមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ មានប្រាក់ចំណូលតិចជាង គ្រួសារដែលទទួលប្រាក់ផ្ញើពីក្នុងស្រុក/ពីបរទេស។ ប៉ុន្តែការប្រៀបធៀបបែបសាមញ្ញនេះ អាចមានការខុសឆ្គង ពីព្រោះគេមិនដឹងពីចំណូលដែលគ្រួសារ ទទួលប្រាក់ផ្ញើទៅផ្ទះអាចរកបាន ប្រសិនបើជនចំណាកស្រុកបានជ្រើសយកការស្នាក់នៅ និងធ្វើការក្នុងស្រុកវិញ។ ដើម្បីដោះស្រាយបញ្ហាចោទខាងវិធីសាស្ត្រនេះ យើងបានអនុវត្តតាមនីតិវិធីរបស់ Adams (2004) ដែលចង្អុលបង្ហាញថា ការប៉ាន់ស្មានពីស្ថានភាពផ្ទុយពីហេតុការណ៍ជាក់ស្តែង គឺជាការចាំបាច់ ហើយលទ្ធផលអាចប្រើជាមូលដ្ឋាន សម្រាប់វាយតម្លៃពីផលប៉ះពាល់នៃប្រាក់ផ្ញើទៅផ្ទះទៅលើភាពក្រីក្រ។ ដើម្បីអនុវត្តវិធីសាស្ត្រនេះ ជាដំបូង ត្រូវកំណត់រកប៉ារ៉ាម៉ែត្រសម្រាប់ប៉ាន់ស្មានពីប្រាក់ចំណូលក្នុងមនុស្សម្នាក់ ដោយយកប្រជាជនទាំង ២៧៤៣គ្រួសារដែលមិនទទួលបានប្រាក់ផ្ញើទៅផ្ទះ ធ្វើជាមូលដ្ឋាន។ បន្ទាប់មកត្រូវយកប៉ារ៉ាម៉ែតទាំងនេះ ទៅអនុវត្តលើ ៨៦៧គ្រួសារដែលទទួលបានប្រាក់ផ្ញើទៅផ្ទះ។ សមីការបានយកមកប្រើដើម្បីប៉ាន់ស្មានពីប៉ារ៉ាម៉ែត្រ៖

$$Y_i = aX + \varepsilon_i \qquad (១)$$

ក្នុងនេះ $Y_i$ ជាប្រាក់ចំណូលរបស់មនុស្សម្នាក់ក្នុងគ្រួសារ $i$, $X_i$ ជាវ៉ិចទ័រនៃលក្ខណៈសំគាល់គ្រួសារ $i$, $a$ ជាវ៉ិចទ័រមេគុណត្រូវធ្វើការប៉ាន់ស្មាន ហើយ $\varepsilon_i$ ជាកត្តាលំអៀង។

ទោះយ៉ាងនេះក្តី Adams (2004) បានកត់សម្គាល់ថា ការកំណត់ឲ្យច្បាស់ថា អថេរណាខ្លះជាកត្តាពីខាងក្រៅសម្រាប់ប្រាក់ចំណូល (ឬចំណាយ) របស់គ្រួសារ វាលំបាក និងស្មុគស្មាញ

ណាស់។ ដូច្នេះបញ្ហាខាងសេដ្ឋមាត្រដ៏សំខាន់ សម្រាប់ការគណនាសមីការ (១) គឺការជ្រើសរើសអថេរ។ យើងបានផ្តល់សម្មតិកម្មថាប្រាក់ចំណូល (ឬចំណាយ) ក្នុងមនុស្សម្នាក់ អាចប៉ាន់ស្មានជាមុខងារនៃលក្ខណៈសំគាល់របស់មេគ្រួសារ (ការអប់រំ អាយុ យេនឌ័រ) និងលក្ខណៈសំគាល់នៃគ្រួសារ (អថេរជាដីកសិកម្ម លក្ខណៈលំនៅឋាន តំបន់ និងជនជាតិ)៖

$$Y_i = \alpha_0 + \alpha_1 HHHAge_i + \alpha_2 HHHGender_i + \alpha_3 HHSize_i + \alpha_4 EDUMale_i + \alpha_5 EDUFemale_i + \alpha_6 Room_i + \alpha_7 Light_i + \alpha_8 Water_i + \alpha_9 Agr_Land_i + \alpha_{10} Rural_i + \alpha_{11} Urban_i + \varepsilon_i \quad (២)$$

ក្នុងនេះ $Y$ ជាប្រាក់ចំណូលគ្រួសារ (ឬចំណាយ) ក្នុងមនុស្សម្នាក់ *HHHAge* ជាអាយុរបស់មេគ្រួសារ *HHHGender* ជាយេនឌ័ររបស់មេគ្រួសារ *HHSize* ជាចំនួនសមាជិកគ្រួសារ *EDUMale* ជាកម្រិតអប់រំមធ្យមរបស់សមាជិកគ្រួសារជាបុរសអាយុលើសពី ១៨ឆ្នាំ *EDUFemale* ជាកម្រិតអប់រំមធ្យមរបស់សមាជិកគ្រួសារជានារីអាយុលើសពី ១៨ឆ្នាំ *Room* ជាចំនួនបន្ទប់ក្នុងគ្រួសារ *Light* ជាប្រភពបំភ្លឺ *Agr_Land* ជាដីកសិកម្ម ហើយ *Rural* និង *Urban* ជាអថេរ បញ្ជាក់ពីតំបន់។ យើងប្រើវិធីសាស្ត្រ *ordinary least squares* ដើម្បីគណនាសមីការ (២)។ ដោយសារតែការសិក្សានេះ សំដៅប៉ាន់ស្មានពីផលប៉ះពាល់នៃប្រាក់ផ្ញើទៅផ្ទះ ទៅលើភាពក្រីក្រ ហើយឯកសារវិភាគពីភាពក្រីក្រទាំងអស់នៅកម្ពុជា សុទ្ធតែប្រើចំណាយប្រើប្រាស់ ធ្វើជាសូចនាករ ដើម្បីវាស់វែងអំពីចំនួនជនក្រីក្រ គម្លាតភាពក្រីក្រ និងគម្លាតភាពក្រីក្រលើកជាការ៉េ ដូច្នេះទើបត្រូវយកចំណាយប្រើប្រាស់ក្នុងមនុស្សម្នាក់ មកប្រើជាអថេរប្រែប្រួលរបស់សមីការ (២)។

ដូចបានបង្ហាញក្នុងតារាង ២ អថេរឯករាជ្យដែលបានជ្រើសរើសមួយចំនួន មានភាពខុសប្លែកគ្នាខាងស្ថិតិរវាងគ្រួសារទទួល និងមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ ខណៈដែលអថេរខ្លះទៀត មានលក្ខណៈស្រដៀងគ្នា។ គ្រួសារទទួលបានប្រាក់ផ្ញើទៅផ្ទះ ច្រើនតែមានមេគ្រួសារជាស្ត្រី និងមានវ័យចំណាស់ជាង មានទំហំគ្រួសារតូចជាង មានបន្ទប់ច្រើនជាងក្នុងផ្ទះ មានអគ្គិសនីប្រើតិចជាង និងរស់នៅតំបន់ជនបទច្រើនជាង គ្រួសារមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ។ ការអប់រំនៃសមាជិកប្រុសស្រី ប្រភពទឹកបរិភោគ ឬការកាន់កាប់ដីកសិកម្ម មិនមានភាពខុសប្លែកគ្នាទេរវាងគ្រួសារទាំងពីរក្រុម។ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលស្រាវជ្រាវជាក់ស្តែងទាំងនេះ យើងធ្វើការប៉ាន់ស្មានពីចំណាយប្រើប្រាស់គិតក្នុងសមាជិកគ្រួសារមួយនាក់ របស់ក្រុមទាំងពីរ សម្រាប់ពីរករណី៖ (a) អថេរឯករាជ្យជ្រើសរើសដែលមិនមានភាពខុសប្លែកគ្នាខាងស្ថិតិរវាងក្រុមទាំងពីរ និង (b) អថេរឯករាជ្យជ្រើសរើសទាំងអស់។ យើងផ្តោតលើគំរូ b សម្រាប់ការបកស្រាយបន្ថែមទៀត។

តារាង ២៖ ទិន្នន័យសង្ខេបអំពីគ្រួសារបានទទួល និងមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ

| អថេរ | មិនបានទទួលប្រាក់ផ្ញើទៅផ្ទះ | បានទទួលប្រាក់ផ្ញើទៅផ្ទះ | t-test |
|---|---|---|---|
| ភេទរបស់មេគ្រួសារ (១=បុរស, 0=នារី) | 0.80 (0.39) | 0.65 (0.47) | 9.09*** |
| អាយុមេគ្រួសារ (ឆ្នាំ) | 43.83 (12.73) | 52.31 (13.89) | -16.47*** |
| ទំហំគ្រួសារ (នាក់) | 4.93 (1.97) | 4.58 (2.05) | 4.47*** |
| កម្រិតការអប់រំមធ្យម(mean)របស់បុរសពេញវ័យ (ឆ្នាំ) | 5.90 (4.10) | 5.65 (4.18) | 1.55 |
| កម្រិតការអប់រំមធ្យម(mean)របស់នារីពេញវ័យ (ឆ្នាំ) | 4.36 (3.42) | 4.16 (3.42) | 1.44 |
| ចំនួនបន្ទប់ក្នុងផ្ទះ | 1.48 (0.94) | 1.58 (1.11) | -2.50** |
| ភ្លើងបំភ្លឺ(១=អគ្គិសនី, 0=ផ្សេងពីនេះ) | 0.36 (0.48) | 0.32 (0.47) | 2.01** |
| ប្រភពទឹកបរិភោគ (១=ទឹកម៉ាស៊ីន, 0=ផ្សេងពីនេះ) | 0.25 (0.43) | 0.24 (0.43) | 0.12 |
| ដីកសិកម្ម (១=មានដីកសិកម្ម, 0=ផ្សេងពីនេះ) | 0.60 (0.48) | 0.64 (0.47) | -1.88 |
| ជនបទ (១= ជនបទ, 0= ផ្សេងពីនេះ) | 0.61 (0.48) | 0.65 (0.47) | -2.09** |

*គម្លាតស្តង់ដា (Standard deviations)៖ លេខក្នុងរង្វង់ក្រចក។*
** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត 0,១។ ** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត0,0៥។ *** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត 0,0១។*
*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ*

តារាង ៣៖ ការប៉ាន់ស្មានពីចំណាយប្រើប្រាស់ក្នុងសមាជិកគ្រួសារ១នាក់ (មិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ)

| | គំរូ a | គំរូ b |
|---|---|---|
| កម្រិតអប់រំមធ្យម (mean) របស់បុរសពេញវ័យ | 0.006*** | 0.006*** |
| កម្រិតអប់រំមធ្យម (mean) របស់នារីពេញវ័យ | 0.004*** | 0.004*** |
| ទឹកហូប (១=ទឹកម៉ាស៊ីន, 0=ផ្សេងពីនេះ) | 0.122*** | 0.100*** |
| ដីកសិកម្ម (១=មានដីកសិកម្ម, 0=ផ្សេងពីនេះ) | -0.007 | 0.001 |
| ជនបទ | -1.125*** | -1.059*** |
| ទីប្រជុំជន | -0.719*** | -0.683*** |
| ភេទរបស់មេគ្រួសារ (១=បុរស, 0=នារី) | | 0.005 |
| អាយុមេគ្រួសារ (ឆ្នាំ) | | 0.001*** |
| ទំហំគ្រួសារ | | -0.019*** |
| ចំនួនបន្ទប់ក្នុងផ្ទះ | | 0.041*** |
| ភ្លើងបំភ្លឺ (១=អគ្គិសនី, 0=ផ្សេងពីនេះ) | | 0.063*** |
| បញ្ចភាគ ២ | 0.408*** | 0.391*** |
| បញ្ចភាគ ៣ | 0.688*** | 0.662*** |
| បញ្ចភាគ ៤ | 0.992*** | 0.948*** |
| បញ្ចភាគ ៥ | 1.573*** | 1.493*** |
| ថេរ | 8.409*** | 8.351*** |
| Adjust R-squared | 0.915 | 0.918 |
| ទំហំគំរូតាង | 2743 | 2743 |

** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត 0,១។ ** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត 0,0៥។ *** ខុសគ្នាគួរកត់សំគាល់ខាងស្ថិតិក្នុងកម្រិត 0,0១។*
*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ*

តារាង ៣ សង្ខេបពីលទ្ធផលទទួលបានពីការប្រើសមីការ (២) ដើម្បីប៉ាន់ស្មានពីចំណាយប្រើប្រាស់គិតក្នុងសមាជិកគ្រួសារមួយនាក់ ដោយមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ។ មេគុណទាំងអស់មានភាពខុសប្លែកគ្នាគួរកត់សំគាល់ខាងស្ថិតិនៅកម្រិត ១% លើកលែងអថេរមួយដែលវាស់វែងពីយេនឌ័ររបស់មេគ្រួសារ។ មេគុណទាំងនេះ អាចយកមកប្រើ ដើម្បីប៉ាន់ស្មានពីចំណាយប្រើប្រាស់គិតក្នុងសមាជិកគ្រួសារមួយនាក់ ក្នុងស្ថានភាពមួយដែលមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ ទាំងសម្រាប់គ្រួសារមិនទទួលបានប្រាក់ផ្ញើទៅផ្ទះ គ្រួសារទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និងគ្រួសារទទួលបានប្រាក់ផ្ញើពីបរទេស។ ក្រោយពេលគណនាឃើញចំណាយប្រើប្រាស់ក្នុងសមាជិកគ្រួសារមួយនាក់ ដោយមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះនោះហើយ ចំណាយប្រើប្រាស់ក្នុងសមាជិកគ្រួសារមួយនាក់ ដែលគិតបញ្ចូលទាំងប្រាក់ផ្ញើទៅផ្ទះ អាចគណនាបានដោយបន្ថែម ៨០% នៃចំនួនជាក់ស្តែងនៃប្រាក់ដែលផ្ញើទៅផ្ទះក្នុងមនុស្សម្នាក់[២]។

តារាង ៤ រាយការណ៍ពីការប៉ាន់ស្មាន ចំណាយប្រើប្រាស់ក្នុងសមាជិកគ្រួសារ១នាក់ សម្រាប់គ្រួសារទាំង៣ក្រុម ក្នុងស្ថានភាព២៖ គិតបញ្ចូល និងមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ។ បើមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ ចំណាយប្រើប្រាស់ក្នុងមនុស្ស១នាក់ នៃគ្រួសារទទួលប្រាក់ផ្ញើពីក្នុងស្រុក មានកម្រិតទាបជាងគ្រួសារមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ ប្រមាណ ២-៤%។ គ្រួសារទទួលបានប្រាក់ផ្ញើពីបរទេស មានចំណាយប្រើប្រាស់ក្នុងមនុស្ស១នាក់ ខ្ពស់ជាងពីរក្រុមផ្សេងទៀត ដែលមានន័យថា គ្រួសារភាគច្រើនដែលមានជនចំណាកស្រុកទៅបរទេស ជាទូទៅមានជីវភាពធូរធារជាងគ្រួសារមានជនចំណាកស្រុកក្នុងប្រទេស និងគ្រួសារមិនមានជនចំណាកស្រុក។ នៅពេលបានគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ ចំណាយប្រើប្រាស់មធ្យមក្នុងមនុស្ស១នាក់ សម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស មានកម្រិត ៦% និង ៨០% ខ្ពស់ជាងគ្រួសារមិនទទួលបានប្រាក់ផ្ញើទៅផ្ទះ។

## ប្រាក់ផ្ញើទៅផ្ទះ និងការកាត់បន្ថយភាពក្រីក្រ

ដើម្បីកំណត់ពីផលប៉ះពាល់នៃប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស ទៅលើភាពក្រីក្រ និងវិសមភាព យើងបានពិចារណាលើសេណារីយ៉ូ២។ នៅក្នុងសេណារីយ៉ូទី១ យើងប៉ាន់ស្មានអំពីអនុបាតចំនួនជនក្រីក្រ គម្លាតភាពក្រីក្រ គម្លាតភាពក្រីក្រលើកជាការ៉េ និងមេគុណ Gini ដោយមិនគិតបញ្ចូលទាំងប្រាក់ផ្ញើទៅផ្ទះ។ នៅក្នុងសេណារីយ៉ូទី២ យើងគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ។ សម្រាប់បន្ទាត់ភាពក្រីក្រ និងការវាស់វែងអំពីភាពក្រីក្រផ្សេងៗទៀត ការ

---

[២] Chan (2009a) កត់សម្គាល់ថា ៨០-៨៧% នៃប្រាក់ផ្ញើទៅផ្ទះ ត្រូវបានចំណាយលើការប្រើប្រាស់ទំនិញ ហើយត្រឹម ១៣%-២០% ប៉ុណ្ណោះ ត្រូវបានចំណាយលើផលិតកម្ម។

តារាង ៤៖ ចំណាយប្រើប្រាស់ប៉ាន់ស្មានក្នុងមនុស្ស១នាក់ សម្រាប់គ្រួសារទទួល និងមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ (គិតជារៀល/នាក់/ថ្ងៃ)

| | មិនទទួលបានប្រាក់ផ្ញើមកផ្ទះ | ទទួលបានប្រាក់ផ្ញើពីក្នុងស្រុក | ទទួលបានប្រាក់ផ្ញើពីបរទេស |
|---|---|---|---|
| គំរូ១ | | | |
| ចំណាយប្រើប្រាស់ប៉ាន់ស្មានមធ្យមមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ | 5961.05<br>(5548.86) | 5700.90<br>(5256.05) | 9503.96<br>(7707.83) |
| ចំណាយប្រើប្រាស់ប៉ាន់ស្មានមធ្យម គិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ | 5961.05<br>(5548.86) | 6193.46<br>(5653.87) | 11150.28<br>(9572.14) |
| គំរូ២ | | | |
| ចំណាយប្រើប្រាស់ប៉ាន់ស្មានមធ្យមមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ | 5975.17<br>(5614.18) | 5828.61<br>(5485.17) | 9708.99<br>(8050.53) |
| ចំណាយប្រើប្រាស់ប៉ាន់ស្មានមធ្យម គិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ | 5975.17<br>(5614.18) | 6321.17<br>(5867.83) | 11355.30<br>(9885.59) |
| គំរូតាង | 2743 | 697 | 136 |

*សម្គាល់៖ គំលាតស្តង់ដា (Standard deviations): លេខក្នុងរង្វង់ក្រចក។*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ។*

គិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ៖ វាកាត់បន្ថយនូវភាពក្រីក្រ គម្លាតភាពក្រីក្រ និងគម្លាតភាពក្រីក្រលើកជាការ៉េ។ ទំហំនៃការកាត់បន្ថយភាពក្រីក្រ គឺអាស្រ័យលើការវាស់វែង និងបន្ទាត់ភាពក្រីក្រ។ ភាពក្រីក្រក្នុង ៣៥៧៦គ្រួសារ ធៀបនឹងបន្ទាត់ភាពក្រីក្រជាតិគឺ ២៤,៣៣% បើគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ៖ និង ២៥,៥៣% បើមិនគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះ៖ (មានកំណើន ១,២ឯកតាភាគរយ)។ ការគិតបញ្ចូលប្រាក់ផ្ញើទៅផ្ទះទៅក្នុងចំណាយគ្រួសារ វាកាត់បន្ថយភាពក្រីក្របានបន្ថែមទៀត សម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើទៅផ្ទះ។ តារាង៥ បង្ហាញថា ប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស បានធ្វើឲ្យកម្រិតភាពក្រីក្រធ្លាក់ចុះ ៤,៧៣ និង ៧,៣៥ឯកតាភាគរយ។ ប៉ុន្តែភាពក្រីក្រត្រូវថយចុះកាន់តែច្រើន នៅពេលយើងវាស់វែង ដោយប្រើគម្លាតភាពក្រីក្រ និង គម្លាតភាពក្រីក្រលើកជាការ៉េ។ ឧទាហរណ៍ ការវាស់ដោយប្រើគម្លាតភាពក្រីក្រលើកជាការ៉េ បង្ហាញថា ប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស

តារាង ៥៖ ផលប៉ះពាល់នៃប្រាក់ផ្ញើទៅផ្ទះទៅលើភាពក្រីក្រ ក្នុងគ្រួសារបានទទួល និងមិនបានទទួលប្រាក់ផ្ញើទៅផ្ទះ

| បន្ទាត់ភាពក្រីក្រជាតិ | | | | | | |
|---|---|---|---|---|---|---|
| | គ្រួសារទាំងអស់ | | គ្រួសារទទួលបានប្រាក់ផ្ញើពីក្នុងស្រុក | | គ្រួសារទទួលបានប្រាក់ផ្ញើពីបរទេស | |
| | មិនបានទទួលប្រាក់ផ្ញើទៅផ្ទះ | គិតបញ្ចូលប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស | មិនបានទទួលប្រាក់ផ្ញើទៅផ្ទះ | គិតបញ្ចូលប្រាក់ផ្ញើពីក្នុងស្រុក | មិនបានទទួលប្រាក់ផ្ញើទៅផ្ទះ | គិតបញ្ចូលប្រាក់ផ្ញើពីបរទេស |
| គំរូ១ | | | | | | |
| ចំនួនជនក្រីក្រ (%) | 27.27 | 25.76 | 28.69 | 22.38 | 13.24 | 5.88 |
| គម្លាតភាពក្រីក្រ (%) | 5.60 | 5.30 | 5.36 | 4.10 | 2.62 | 1.11 |
| គម្លាតភាពក្រីក្រលើកជាការ៉េ (%) | 1.79 | 1.67 | 1.67 | 1.20 | 0.84 | 0.31 |
| មេគុណ Gini | 0.43 | 0.44 | 0.42 | 0.43 | 0.43 | 0.44 |
| គំរូតាង | 3576 | 3576 | 697 | 697 | 136 | 136 |
| គំរូ២ | | | | | | |
| ចំនួនជនក្រីក្រ (%) | 25.53 | 24.33 | 24.39 | 19.66 | 12.50 | 5.15 |
| គម្លាតភាពក្រីក្រ (%) | 5.54 | 5.28 | 5.05 | 3.98 | 2.45 | 1.07 |
| គម្លាតភាពក្រីក្រលើកជាការ៉េ (%) | 1.77 | 1.67 | 1.59 | 1.16 | 0.77 | 0.30 |
| មេគុណ Gini | 0.43 | 0.44 | 0.42 | 0.43 | 0.43 | 0.44 |
| គំរូតាង | 3576 | 3576 | 697 | 697 | 136 | 136 |

*សម្គាល់៖ គ្រួសារទទួលបានទាំងប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស ត្រូវបានដកចេញ។*

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធពី CSES 2007*

អាចកាត់បន្ថយភាពក្រីក្របាន ៥,៧% សម្រាប់គ្រួសារជាគំរូតាងទាំង ៣៥៧៦គ្រួសារ ២៦,៩% សម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និង ៦០,៨% សម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើពីបរទេស។ លទ្ធផលនេះមានន័យថា ប្រាក់ផ្ញើទៅផ្ទះវាកាត់បន្ថយកម្រិតធ្ងន់ធ្ងរនៃភាពក្រីក្រ បានច្រើនជាងចំនួនភាគរយអ្នករស់នៅក្នុងភាពក្រីក្រ។ លទ្ធផលសិក្សានេះ មិនមានការផ្លាស់ប្ដូរទេ នៅពេលបន្ទាត់ភាពក្រីក្រអន្តរជាតិ ត្រូវបានយកមកប្រើប្រាស់ បើទោះជាការកាត់បន្ថយភាពក្រីក្រមានទំហំតូចជាងក្ដី។

តារាង ៥ ក៏បានបង្ហាញថា ប្រាក់ផ្ញើពីក្នុងស្រុក ឬពីបរទេស មានផលប៉ះពាល់តិចលើវិសមភាពចំណាយប្រើប្រាស់ (ប្រាក់ចំណូល) ដែលវាស់វែងតាមមេគុណ Gini។ ចំណុចនេះបង្ហាញថា ឥទ្ធិពលនៃប្រាក់ផ្ញើទៅផ្ទះលើការកាត់បន្ថយភាពក្រីក្រ ភាគច្រើនកើតមានដោយសារកំណើនប្រាក់ចំណូលគ្រួសារមធ្យម ជាជាងការប្រែប្រួលនៃវិសមភាពប្រាក់ចំណូល។

## សេចក្ដីសន្និដ្ឋាន

អត្ថបទនេះ បានប្រើប្រាស់អង្កេតលើ ៣៥៩៣នៃគ្រួសារដែលមានលក្ខណៈតំណាងឲ្យទូទាំងប្រទេស និងធ្វើការប៉ាន់ស្មានមុខងារប្រាក់ចំណូល ដើម្បីវិភាគពីផលប៉ះពាល់នៃប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស ទៅលើភាពក្រីក្រ និងវិសមភាព។ ការសិក្សាបានរកឃើញថា មានគ្រួសារតិចជាង ២៤% ទទួលបានប្រាក់ផ្ញើទៅផ្ទះ ដោយក្នុងនោះ ១៩,៩% ទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និង ៤,៣% ទទួលប្រាក់ផ្ញើពីបរទេស។ ប្រាក់ផ្ញើទៅផ្ទះ រួមចំណែក ១១% ក្នុងប្រាក់ចំណូលសរុបសម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើពីក្នុងស្រុក និង ២០% សម្រាប់គ្រួសារទទួលបានប្រាក់ផ្ញើពីបរទេស។ ប្រាក់ផ្ញើទៅផ្ទះទាំងពីរប្រភេទ ជួយកាត់បន្ថយកម្រិត ជម្រៅ និងលក្ខណៈធ្ងន់ធ្ងរនៃភាពក្រីក្រ។ ទំហំនៃការកាត់បន្ថយភាពក្រីក្រ អាស្រ័យលើវិធីវាស់វែងភាពក្រីក្រ។ នៅពេលប្រើបន្ទាត់ភាពក្រីក្រជាតិ ភាពក្រីក្របានថយចុះប្រមាណ ១ឯកតាភាគរយ ដោយសារប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស។ ប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស អាចកាត់បន្ថយអត្រាក្រីក្របាន ៤,៧៣ និង ៧,៣៥ឯកតាភាគរយរៀងគ្នា។ ប៉ុន្តែតួលេខភាពក្រីក្រត្រូវថយចុះកាន់តែច្រើន នៅពេលយើងវាស់វែងដោយប្រើគម្លាតភាពក្រីក្រ ឬគម្លាតភាពក្រីក្រលើកជាការ៉េ ហើយចំណុចនេះបង្ហាញថា ប្រាក់ផ្ញើទៅផ្ទះមានផលប៉ះពាល់លើកម្រិតធ្ងន់ធ្ងរនៃភាពក្រីក្រ ខ្លាំងជាងលើចំនួនអ្នករស់នៅក្នុងភាពក្រីក្រ។ ការសិក្សានេះក៏បង្ហាញដែរថា ប្រាក់ផ្ញើពីក្នុងស្រុក និងពីបរទេស មានផលប៉ះពាល់តិចតួចទៅលើវិសមភាព ដែលមានន័យថា ការកាត់បន្ថយភាពក្រីក្រ កើតមានជាសំខាន់ដោយសារកំណើននៃប្រាក់ចំណូលមធ្យម។

## ឯកសារយោង


Adams, Richard Jr. (1991), "The Economic Uses and Impact of International Remittances in Rural Egypt", *Economic Development and Cultural Changes*, Vol. 39, No. 4, pp.695-722

Adams, Richard Jr. (1993), "The Economic and Demographic Determinants of International Migration in Rural Egypt", *Journal of Development Studies*, Vol.30, No.1, October, pp. 146-167

Adams, Richard Jr. (2004), *Remittances and Poverty in Guatemala*, Policy Research Working Paper 3418 (Washington, DC: World Bank)

Adams, Richard Jr. (2005a), "Remittances, Selection Bias and Poverty in Guatemala", unpublished manuscript (Washington, DC: World Bank)

Adams, Richard Jr. (2005b), *Remittances, Household Expenditure and Investment in Guatemala.* Policy Research Working Paper 3532 (Washington, DC: World Bank)

Adams, Richard Jr. & John Page (2005), "Do International Migration and Remittances Reduce Poverty in Developing Countries?", *World Development*, 33, pp. 1645-1669

Bauer, Amin, Rana Hasan, Rhoda Magsombol & Guanghua Wan (2008), *The World Bank's New Poverty Data: Implications for the Asian Development Bank*, ADB Sustainable Development Working Paper Series No.2 (Manila: ADB)

Chan, Sophal (2009a), *Economic Costs and Benefits of Cross-Border Labour Migration in the GMS: Cambodia Country Study* (Phnom Penh: CDRI)

Chan, Sophal (2009b), *Review of Labour Migration Management, Policies and Legal Framework in Cambodia* (Bangkok: International Labour Organization Regional Office for Asia and the Pacific)

Chami, Ralph, Connel Fullenkamp & Samir Jahjah (2003), *Are Immigrant Remittance Flows a Source of Capital for Development?*, International Monetary Fund Working Paper 03/189 (Washington, DC: IMF)

Edwards, Alejandra & Manuelita Ureta (2003), "International Migration, Remittances and Schooling: Evidence from El Salvador", *Journal of Development Economics*, 72, pp. 429-461

Lim Sovannara (2007), *Youth Migration and Urbanisation in Cambodia*, Working Paper 36 (Phnom Penh: CDRI)

Maltoni, Bruno (2006), *Impact of Remittances on Local Communities in Cambodia: The Case of Prey Veng Province* (Phnom Penh: International Organisation for Migration).

Maltoni, Bruno (2007), *Migration in Cambodia: Internal vs. External Flows*, mimeographed (Phnom Penh)

National Institute of Statistics (2004), *Statistical Yearbook* (Phnom Penh: Ministry of Planning)

Ratha Dilip & Mohapatra (2009), "Outlook for Remittances Flows 2009-2011: Remittances expected to fall by 7-10 percent in 2009", Migration and Development Brief 10 (Washington, DC: World Bank)

Taylor, J. Edward, Jorge Mora & Richard Adams (2005), "Remittances, Inequality and Poverty: Evidence from Rural Mexico", unpublished manuscript (University of California, Davis)

World Bank (2006), *Cambodia: Halving Poverty by 2015? Poverty Assessment 2006* (East Asia and Pacific Region: World Bank)

World Bank (2008), *Migration and Remittance Factbook 2007* (Washington DC: World Bank)

World Bank (2009), *Poverty Profile and Trends in Cambodia, 2007 - Findings from the Cambodia Socio-Economic Survey (CSES)*, Report No. 48618-KH (East Asia and Pacific Region: World Bank)

World Bank (2010), *Migration and Remittances Factbook 2011* (Washington DC: World Bank

# អង្គការកសិករនៅកម្ពុជា៖ តើបានជួយលើកកម្ពស់សន្តិសុខស្បៀងអ្នកក្រីក្រនៅជនបទដែរឬទេ?[១]

## សេចក្តីផ្តើម

តាមធម្មតាក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ប្រជាជនក្រីក្រភាគច្រើនតែងរស់នៅតាមតំបន់ជនបទ និងរកចិញ្ចឹមជីវិតជាចម្បងដោយការធ្វើកសិកម្មខ្នាតតូច។ សហគមន៍អ្នកផ្តល់ជំនួយអន្តរជាតិ និងរដ្ឋាភិបាល បានទទួលស្គាល់ពីសារៈសំខាន់នៃកសិកម្មខ្នាតតូចនេះ ដូចមានបង្ហាញក្នុងការប្តេជ្ញាចិត្តនានា ដើម្បីចាត់វិធានការដ៏ចាំបាច់ផ្សេងៗ សំដៅបង្កើន និងគាំទ្រដល់ការអភិវឌ្ឍវិស័យកសិកម្ម និងកំណើនសេដ្ឋកិច្ចជនបទ។ គោលនយោបាយអន្តរាគមន៍ជាទូទៅបំផុត អនុម័តដោយប្រទេសកំពុងអភិវឌ្ឍន៍គឺត្រូវលើកកម្ពស់ការបង្កើតអង្គការផលិតករជនបទនានា (Bingen *et al.* 2003; Chirwa *et al.* 2005)។ កម្លាំងជំរុញចំបងសម្រាប់កិច្ចការនេះ គឺសេវាគាំទ្ររួម និងប្រកបដោយប្រសិទ្ធភាពដល់អ្នកធ្វើកសិកម្មខ្នាតតូច ដើម្បីកាត់បន្ថយឧបសគ្គធំៗដែលរារាំងដល់កំណើនផលិតភាព ព្រមទាំងការលើកកម្ពស់សមត្ថភាពជួយខ្លួនឯង និងអំណាចរួមគ្នាក្នុងការគ្រប់គ្រងទីផ្សារ (Barham & Chitemi 2009; Bachke 2010)។

នៅកម្ពុជា ប្រជាជនក្រីក្រជាង ៩០% រស់នៅតំបន់ជនបទ និងពឹងផ្អែកលើកសិកម្មជាប្រភពជីវភាពចម្បង។ វិស័យកសិកម្មកម្ពុជា ភាគច្រើនមានលក្ខណៈជាកសិកម្មខ្នាតតូច៖ កសិករជនបទប្រមាណ ៨៤% មានដីកសិកម្មតិចជាង ១ហិកតា (World Bank 2005, 2009a)។ វិស័យកសិកម្មនៅកម្ពុជាមានសក្តានុពលខ្លាំង ហើយកំណើនផលិតភាព អាចជំរុញដល់ផលិតកម្មប្រកបដោយនិរន្តរភាព ជាពិសេសការងារ និងចំណូលរបស់អ្នកពឹងផ្អែកខ្លាំងលើវិស័យកសិកម្មដើម្បីចិញ្ចឹមជីវិត (Theng & Koy 2011) ដូច្នេះការលើកកម្ពស់សហគ្រាសផ្អែកលើកសិកម្មខ្នាតតូច អាចជួយបង្កើនកម្រិតជីវភាពនៅជនបទ និងកាត់បន្ថយភាពក្រីក្រ។

ដើម្បីជួយទ្រទ្រង់ដល់ជីវភាព របស់អ្នកធ្វើកសិកម្មខ្នាតតូចទាំងនោះ រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពដល់ការអភិវឌ្ឍកសិកម្ម ដូចមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ (RS) ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ (NSDP) និងយុទ្ធសាស្ត្រសម្រាប់វិស័យកសិកម្ម និងទឹក (SAW) ដោយបានទទួលស្គាល់ និងលើកទឹកចិត្តអ្នកធ្វើកសិកម្មខ្នាតតូច និងអង្គការកសិករ (FOs) ដែលជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងកាត់បន្ថយភាពក្រីក្រ (Chea 2010)។

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ច្បាស់ថា អង្គការកសិករជាគន្លឹះសំខាន់ក្នុងការអភិវឌ្ឍវិស័យឯកជន និងកសិកម្មជនបទ ប៉ុន្តែនៅមានការសិក្សាតិចតួចណាស់ស្តីពី ផលប៉ះពាល់នៃអង្គការកសិករទៅលើកម្រិតជីវភាពនៅជនបទ។ លើសពីនេះទៅទៀត នៅមិនទាន់មានការសិក្សាអ្វីសោះទេ ពីផលប៉ះពាល់នៃអង្គការកសិករទៅលើជីវភាពរបស់អ្នកធ្វើកសិកម្មខ្នាតតូចនៅកម្ពុជា កុំថាឡើយដល់ទៅ ផលប៉ះពាល់ផ្សេងៗគ្នានៃអង្គការកសិករ (FOs) ប្រភេទខុសៗគ្នានោះ។ ការយល់ដឹងកាន់តែប្រសើរ អំពីផលប៉ះពាល់នៃសមាជិកភាពនៅក្នុង FO ទៅលើកំណើនប្រាក់ចំណូល និងការកំណត់ពីអត្ថប្រយោជន៍ដែលសមាជិកអង្គការកសិករ (FO) ទទួលបាន និងបញ្ហាដែលអង្គការកសិករត្រូវប្រឈម នឹងជួយបង្កើនការយល់ដឹងអំពីវិស័យអង្គការកសិករនៅកម្ពុជា ជួយរៀបចំឡើងវិញនូវគោលនយោបាយបច្ចុប្បន្ន និងរកឃើញមធ្យោបាយផ្សេងៗដែលមានប្រសិទ្ធភាពល្អ និងអាចឆ្លើយតបបានកាន់តែច្រើន ដល់សេចក្តីត្រូវការរបស់អង្គការកសិករ និងគាំទ្របានកាន់តែប្រសើរដល់អ្នកធ្វើកសិកម្មខ្នាតតូច ដើម្បីកាត់បន្ថយភាពក្រីក្រ។

ការសិក្សានេះ វាយតម្លៃពីផលប៉ះពាល់នៃអង្គការកសិករ (FOs) ទៅលើសន្តិសុខស្បៀងរបស់អ្នកក្រីក្រជនបទ ដោយមានគោលដៅជាក់លាក់៖ (១) ពិនិត្យពីតួនាទី ប្រតិបត្តិការ និងបញ្ហាប្រឈមរបស់ FOs ក្នុងការលើកកម្ពស់សន្តិសុខស្បៀងរបស់គ្រួសារ (២) វិភាគពីលក្ខណៈគ្រួសារដែលកំណត់នូវការចូលរួមក្នុងអង្គការកសិករ (FOs) (៣) វាយតម្លៃពីផលប៉ះពាល់នៃអង្គការកសិករ (FOs) ទៅលើសន្តិសុខស្បៀង និងជីវភាពរស់នៅរបស់អ្នកក្រីក្រនៅជនបទ និង (៤) ផ្តល់អនុសាសន៍ជាក់លាក់សម្រាប់ការកែប្រែក្នុងក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិទាក់ទិននឹងអង្គការកសិករ។

## វិធីសាស្ត្រ

*ប្រភេទអង្គការកសិករ (FOs) និងទីតាំងនៃការសិក្សា៖* នៅកម្ពុជាមានអង្គការកសិករ (FO) ៥ប្រភេទផ្សេងគ្នា គឺក្រុមកសិករ (FG) សហគមន៍កសិករ (FC) សមាគមកសិករ (FA) សហករណ៍កសិកម្ម (AC) និង សហព័ន្ធកសិករ (FF)។ ក្នុងចំណោមអង្គការទាំងនេះ បណ្តា FGs FAs និង ACs ដែលផ្តោតលើការអភិវឌ្ឍវិស័យកសិកម្ម និងលើកកម្ពស់ជីវភាពជនបទឃើញមានច្រើនជាទូទៅជាងគេ។ ដូច្នេះ FOs ទាំង ៣ប្រភេទនេះត្រូវបានជ្រើសរើសមកធ្វើការសិក្សា។ ដើម្បីទទួលបានគំរូតាងតំណាងភូមិសាស្ត្របានល្អ ខេត្តចំនួន៤ ដែលមានដង់ស៊ីតេ FOs

---

១ អត្ថបទនេះ រៀបរៀងដោយ លោក ថេង វុទ្ធី ជាអ្នកសម្របសម្រួលកម្មវិធី ភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅ CDRI។ លោក នូ កែវសុទ្ធា លោក កែវ សុជាតិ និងអ្នកស្រី ស៊ុំ ស្រីមុំ ជាអ្នកស្រាវជ្រាវ និងអ្នកស្រី ខៀវ ភិរម្យ ជាជំនួយការស្រាវជ្រាវ ក្នុងកម្មវិធីនេះដែរ។ អត្ថបទនេះសង្ខេបពីលទ្ធផលជាក់ស្តែងនៃការសិក្សាអំពី *ការវាយតម្លៃពីផលប៉ះពាល់នៃអង្គការកសិករទៅលើសន្តិសុខស្បៀងរបស់ជនក្រីក្រនៅជនបទ* ដែលទទួលមូលនិធិពី ធនាគារពិភពលោក។

តារាង ១៖ ការប៉ាន់ស្មានដោយប្រើ Propensity Score ដើម្បីកំណត់ពីការចូលរួមក្នុង FO ( ការប៉ាន់ស្មានបែប logit )

| អថេរ | FOs ទាំងអស់ | FG | FA | AC |
|---|---|---|---|---|
| | z | z | z | Z |
| អាយុមេគ្រួសារ | 2.58 * * | 0.76 | 2.50 * * | 2.71 * * |
| អាយុមេគ្រួសារលើកជាការ៉េ | -2.40 * * | -0.59 | -2.36 * * | -2.60 * * |
| ចំនួនឆ្នាំសិក្សារបស់មេគ្រួសារ | 0.93 | -0.57 | 1.17 | 1.59 |
| មេគ្រួសារចេះអាន និងសរសេរ | 1.54 | 1.52 | 0.79 | 1.62 |
| មេគ្រួសារជាបុរស | -2.96 * * * | -1.22 | -3.93 * * * | -0.89 |
| មេគ្រួសាររៀបការរួច | 1.46 | 0.59 | 2.78 * * | -0.74 |
| មេគ្រួសារអត់ការងារ | -3.19 * * * | -3.27 * * * | -1.78 * * | -0.61 |
| មេគ្រួសារមានប្រាក់ខែ | -0.36 | -0.82 | 0.72 | -0.04 |
| មេគ្រួសារជាកម្មករកសិកម្ម | -0.95 | -1.22 | 0.3 | -1.43 |
| ចំនួនឆ្នាំដែលមេគ្រួសាររស់នៅក្នុងភូមិ | -0.51 | -0.15 | -1.29 | -0.4 |
| ទំហំគ្រួសារ | -2.48 * * | -1.62 * | -1.83 * * | -1.80 * * |
| ទំហំគ្រួសារលើកជាការ៉េ | 2.40 * * | 1.64 * | 2.12 * * | 1.14 |
| អត្រាអ្នកក្នុងបន្ទុក ( ធៀបនឹងមនុស្សអាយុពី ១៥-៦៥ឆ្នាំ ) | 1.43 | 0.91 | 0.62 | 1.34 |
| ផ្ទៃដីដាំដុះគិតជាម៉ែត្រការ៉េ | -0.47 | -0.37 | 0.4 | -1.52 |
| ផ្ទៃដីដាំដុះគិតជាម៉ែត្រការ៉េលើកជាការ៉េ | 0.25 | 0.4 | -0.36 | 1.25 |
| កសិកម្មជាប្រភពចំបងនៃប្រាក់ចំណូលគ្រួសារ | 0.41 | -0.59 | 1.19 | 0.48 |
| គ្រួសារទទួលបានប្រាក់កម្ចីក្នុងរយៈ១២ខែចុងក្រោយ | 4.10 * * * | 3.50 * * * | 2.50 * * | 2.16 * * |
| សន្ទស្សន៍ទ្រព្យកសិកម្មគ្រួសារ | 1.92 * * | 1.51 | 0.97 | 1.74 * * |
| តម្លៃទ្រព្យសរុប | 1.87 * | 0.64 | 0.11 | 3.74 * * * |
| តម្លៃទ្រព្យសរុបលើកជាការ៉េ | -2.09 * * | -1.05 | 0.05 | -3.27 * * * |
| តម្លៃផ្ទះ | 1.04 | -1.09 | 1.03 | 2.08 * * |
| តម្លៃផ្ទះលើកជាការ៉េ | -1.11 | 0.42 | -1.31 | -1.44 |
| ដីដាំដុះទទួលបានការស្រោចស្រព | 1.11 | 3.11 * * * | -0.92 | -0.95 |
| ខេត្តស្វាយរៀង | -0.28 | 2.04 * * | -1.83 * * | -2.48 * * |
| ខេត្តកំពត | -1.03 | -0.38 | -0.84 | -1.14 |
| ខេត្តបាត់ដំបង | 0.21 | 0.22 | 0.05 | 0.47 |
| ខេត្តកំពង់ធំ | - | - | - | - |
| ថេរ | -2.14 | -1.15 | -2.73 | -3.00 |
| Pseudo $R^2$ | 0.079 | 0.100 | 0.116 | 0.221 |
| ចំនួនសង្កេត | 695 | 510 | 470 | 445 |

*សម្គាល់: *, * *, * * *បង្ហាញពីភាពខុសប្លែកគ្នាគួរកត់សំគាល់ខាងស្ថិតិ ក្នុងកម្រិត ១០% ៥% និង ១%។*

ខ្ពស់ជាងគេ ត្រូវបានជ្រើសរើស គឺមានខេត្ត បាត់ដំបង កំពង់ធំ ស្វាយរៀង និងកំពត។

*ការជ្រើសយកគំរូតាងគ្រួសារ៖* ដើម្បីទទួលបានគំរូតាងល្អ និងធានាឲ្យលទ្ធផលអាចទុកចិត្តបាន និងមានលក្ខណៈតំណាងល្អ FOs ចំនួន៥៤ ត្រូវបានជ្រើសរើសចេញពីខេត្តទាំង៤ ដោយប្រើវិធីជ្រើសដោយចៃដន្យសាមញ្ញ និងសមាមាត្រទៅនឹងចំនួនសរុបនៃ FO ប្រភេទនីមួយៗ នៅក្នុងខេត្តនីមួយៗ។ ចំនួន FGs FAs និង ACs ដែលត្រូវជ្រើសរើស គឺគណនាឡើងដោយផ្អែកតាមសមាមាត្រ ៥០:៣០:២០ ហើយតាមនេះគេទទួលបានគំរូតាងដែលមាន FGs ចំនួន ២៩ FAs ចំនួន ១៥ និង ACs ចំនួន ១០។ ដើម្បីប៉ាន់ស្មានពីផលប៉ះពាល់នៃការចូលរួមក្នុង FOs គ្រួសារដែលមិនមែនជាសមាជិក FO មួយចំនួន ត្រូវបានជ្រើសរើសធ្វើជាក្រុមធៀប។ ការសិក្សាបានធ្វើសម្ភាសន៍ទាំងអស់ ៦៩៩គ្រួសារ ដែលបានជ្រើសរើសដោយចៃដន្យចេញពី ២៥ឃុំ ក្នុង ៤ខេត្តនេះដូចគ្នា[២] គឺមាន ៣៣០គ្រួសារជាសមាជិក FO និង ៣៦៩គ្រួសារមិនមែនជាសមាជិក FO។

២ សូមមើល Theng *et al.* ( 2011 ) ដើម្បីទទួលបានព័ត៌មានលម្អិតពីវិធីសាស្ត្រស្រាវជ្រាវ និងនីតិវិធីជ្រើសគំរូតាង។

តារាង ២៖ ផលប៉ះពាល់ជាមធ្យមទៅលើផលិតភាពស្រូវដោយប្រើវិធីសាស្ត្រ PSM

| អថេរ | Nearest neighbour matching | | | Kernel matching | | |
|---|---|---|---|---|---|---|
| | ភាពខុសគ្នា (ATT) | T-stat | Trt/Cont Obs | ភាពខុសគ្នា (ATT) | T-stat | Trt/Cont Obs |
| **ប្រាក់ចំណូលពីស្រូវ /ហិកតា (0000 រៀល)** | | | | | | |
| គំរូតាង FOs ទាំងអស់ | 8.74 | 0.85 | 292/313 | 8.59 | 0.93 | 299/313 |
| - ក្រុមកសិករ | -4.00 | -0.29 | 129/313 | -1.22 | -0.1 | 132/313 |
| - សមាគមកសិករ | 23.34 | 1.36 | 82/313 | -0.95 | -0.07 | 91/313 |
| - សហករណ៍កសិកម្ម | 35.44 | 1.91** | 75/313 | 32.61 | 2.07** | 74/313 |
| **ប្រាក់ចំណេញពីស្រូវ /ក្នុង១ហិកតា(0000 រៀល)** | | | | | | |
| គំរូតាង FOs ទាំងអស់ | 8.23 | 0.41 | 292/313 | 12.94 | 0.75 | 299/313 |
| - ក្រុមកសិករ | -13.10 | -0.79 | 129/313 | -1.44 | -0.07 | 132/313 |
| - សមាគមកសិករ | 6.07 | 0.23 | 82/313 | 0.37 | 0.01 | 91/313 |
| - សហករណ៍កសិកម្ម | 50.19 | 2.43** | 74/313 | 52.87 | 2.41** | 74/313 |

*សម្គាល់: *, **, *** បង្ហាញពីភាពខុសគ្នាគួរកត់សំគាល់ខាងស្ថិតិ ក្នុងកម្រិត ១០% ៥% និង ១%។*

*ការប៉ាន់ស្មានពីផលប៉ះពាល់៖* ដើម្បីកំណត់ពីផលប៉ះពាល់នៃការចូលរួមក្នុង FOs ទៅលើសន្តិសុខស្បៀងរបស់ប្រជាជនក្រីក្រជនបទ ការសិក្សាបានយកផលិតភាពស្រូវ និងសត្វចិញ្ចឹមរបស់គ្រួសារ មកធ្វើជាតំណាង។ ផលិតផល និងចំណាយសរុបនៃការធ្វើស្រែ និងចិញ្ចឹមសត្វ ក៏បានយកមកប្រើដើម្បីប៉ាន់ស្មានពីលទ្ធផល ចំពោះគ្រួសារដែលបានទទួលអត្ថប្រយោជន៍ពីការចូលរួមក្នុង FO។ វិធីសាស្ត្រ Propensity score matching (PSM) បានយកមកប្រើដើម្បីធ្វើការប៉ាន់ស្មានជាក់ស្តែងពីផលប៉ះពាល់នៃសមាជិកភាពក្នុង FO ទៅលើផលិតភាពស្រូវ និងសត្វចិញ្ចឹមរបស់គ្រួសារ (Caliendo & Kopeinig 2008)។

## លទ្ធផល និងការពិភាក្សា[៣]

### លក្ខណៈនៃការចូលរួមក្នុង FOs

ការវិភាគជាក់ស្តែងលើទិន្នន័យអង្កេត បង្ហាញថា កត្តាប៉ះពាល់ដល់ការចូលរួមក្នុង FO មានភាពខុសប្លែកគ្នារវាងគំរូតាង FOs ទាំងអស់ និងអនុគំរូតាង (FGs, FAs, ACs) (តារាង ១)។ អាយុមេគ្រួសារ មានឥទ្ធិពលវិជ្ជមានគួរកត់សំគាល់លើការចូលរួមក្នុង FOs ប៉ុន្តែមេគ្រួសារមានអាយុលើសពី ៥៦ឆ្នាំ មិនសូវចូលជាសមាជិក FOs ក្នុងគំរូតាង FOs ទាំងអស់ និងអនុគំរូតាង FA និង AC ទេ ហើយអាយុរបស់មេគ្រួសារ ក៏មិនមែនជាកត្តាកំណត់សំខាន់នៃការចូលរួមក្នុងអនុគំរូតាង FG ដែរ។ ទំនាក់ទំនងអវិជ្ជមានគួរកត់សំគាល់រវាង មេគ្រួសារជាបុរស និងការចូលរួមក្នុង FOs បង្ហាញថា គ្រួសារមានមេគ្រួសារជានារី ទំនងជាចូលរួមក្នុងគំរូតាង FOs ទាំងអស់ និង អនុគំរូតាង FA ច្រើនជាងគ្រួសារមានមេគ្រួសារជាបុរស ប៉ុន្តែសម្រាប់អនុគំរូតាង FGs និង ACs វាមិនដូច្នោះទេ។ ភាពអត់ការងារធ្វើរបស់មេគ្រួសារ និងទំហំគ្រួសារ មានផលប៉ះពាល់អវិជ្ជមានគួរកត់សំគាល់លើការចូលរួមក្នុង FOs ប៉ុន្តែការទទួលបានឥណទាន ជាកត្តាវិជ្ជមានចម្បងកំណត់ពីនិន្នាការនៃការចូលរួមក្នុងគំរូតាង Fos ទាំងអស់ និងអនុគំរូតាង ហើយលទ្ធផលស្រាវជ្រាវនេះមានលក្ខណៈស្រដៀងគ្នានឹងលទ្ធផលរបស់ Davis *et al.* (2010), Couturier *et al.* (2006) and Chea (2010)។

គ្រួសារដែលមានទ្រព្យកសិកម្មមានផលិតភាព ច្រើនតែចូលរួមក្នុង FOs ក្នុងគំរូតាង FOs ទាំងអស់ និងអនុគំរូតាង AC (Bernard & Sphienlman 2009)។ ទំហំដីមិនមែនជាសូចនាករសំខាន់នៃការចូលរួមក្នុង FOs ទេ។ សុខមាលភាពរបស់គ្រួសារមានទំនាក់ទំនងវិជ្ជមានជាមួយការចូលរួមក្នុង FOs តែទំនាក់ទំនងនេះ បែរជាមានផលប៉ះពាល់អវិជ្ជមានទៅលើការចូលរួម នៅពេលគ្រួសារមានទ្រព្យសម្បត្តិសរុបឡើងដល់ ឬលើសពី ១៣,៦ លានរៀល។ ដូច្នេះកសិករមានមូលធនផលិតកម្មកាន់តែច្រើន មិនសូវក្លាយជាសមាជិក FOs ក្នុង គំរូតាង FOs ទាំងអស់ និង អនុគំរូតាង AC នោះទេ។ ការអប់រំរបស់មេគ្រួសារក៏មិនមែនជាកត្តាកំណត់សំខាន់នៃការចូលរួម សម្រាប់អនុគំរូតាងទាំងអស់ដែរ ដោយគ្រួសារនៅជនបទតែងទៅចូលរួមក្នុង FOs ដោយមិនគិតពីកម្រិតនៃមូលធនមនុស្សនោះទេ (តារាង ១)។

### ផលប៉ះពាល់នៃការចូលរួមក្នុង FO លើជីវភាពរស់នៅ

ផលប៉ះពាល់នៃការចូលរួមក្នុង FO លើចំណូល និងប្រាក់ចំណេញពីផលិតកម្មស្រូវ និងសត្វចិញ្ចឹម ត្រូវបានប៉ាន់ស្មាន

---

៣ ទាំងវិធីសាស្ត្របែបគុណភាព និងបរិមាណ បានយកមកប្រើដើម្បីប៉ាន់ស្មានពីផលប៉ះពាល់នៃ FOs ទៅលើសន្តិសុខស្បៀងរបស់អ្នកក្រនៅជនបទកម្ពុជា ប៉ុន្តែក្នុងអត្ថបទនេះមានបង្ហាញតែព័ត៌មានបែបបរិមាណប៉ុណ្ណោះ។

តារាង ៣៖ ផលប៉ះពាល់ជាមធ្យមលើផលិតផលសត្វចិញ្ចឹមដោយប្រើប្រាស់វិធីសាស្ត្រ PSM

| អថេរ | Nearest neighbour matching | | | Kernel matching | | |
|---|---|---|---|---|---|---|
| | ភាពខុសគ្នា (ATT) | T-stat | Trt/Cont Obs | ភាពខុសគ្នា (ATT) | T-stat | Trt/Cont Obs |
| **ប្រាក់ចំណូលពីសត្វចិញ្ចឹម** | | | | | | |
| គំរូតាង FOs ទាំងអស់ | 84.30 | 1.48 | 275/297 | 90.33 | 1.79 * | 288/297 |
| - ក្រុមកសិករ | -27.86 | -0.54 | 126/297 | -30.50 | -0.77 | 125/297 |
| - សមាគមកសិករ | 190.14 | 1.44 | 82/297 | 200.92 | 1.76 * | 89/297 |
| - សហករណ៍កសិកម្ម | -17.68 | -0.17 | 69/297 | 150.99 | 1.72 * | 70/297 |
| **ប្រាក់ចំណេញពីសត្វចិញ្ចឹម** | | | | | | |
| គំរូតាង FOs ទាំងអស់ | 41.79 | 0.95 | 275/297 | 55.59 | 1.46 | 288/297 |
| - ក្រុមកសិករ | -12.15 | -0.25 | 123/297 | -18.56 | -0.51 | 125/297 |
| - សមាគមកសិករ | 36.80 | 0.44 | 86/297 | 116.56 | 1.65 * | 89/297 |
| - សហករណ៍កសិកម្ម | -72.51 | -0.84 | 69/297 | 109.16 | 1.67 * | 70/297 |

*សម្គាល់: *, **, *** បង្ហាញពីភាពខុសប្លែកគួរកត់សំគាល់ខាងស្ថិតិ នៅកម្រិត ១០% ៥% និង ១%។*

ជាក់ស្តែង ដោយប្រើគំរូតាង FOs ទាំងអស់ និង អនុគំរូតាងនានា ដើម្បីកំណត់ថា FO ប្រភេទណា មានផលប៉ះពាល់ខ្លាំងទៅលើគ្រួសារជាសមាជិក។ បន្ទាប់ពីធ្វើឲ្យមានតុល្យភាពរវាងគ្រួសារជាសមាជិក និងមិនមែនជាសមាជិក FO ដោយប្រើវិធីសាស្ត្រ PSM លទ្ធផលជាក់ស្តែងបង្ហាញថា ក្នុងគំរូតាង FOs ទាំងអស់ ទោះបីសមាជិក FO មានប្រាក់ចំណូល និងប្រាក់ចំណេញខ្ពស់ជាងគ្រួសារមិនមែនសមាជិក FO ក្តី ក៏ការចូលរួមក្នុង FO (ពោលគឺ សម្រាប់សមាជិក FO) មិនបានជះឥទ្ធិពលអ្វីគួរកត់សំគាល់ទៅលើតម្លៃ (ប្រាក់ចំណូល) និងប្រាក់ចំណេញពីផលិតកម្មស្រូវនោះដែរ។ ប៉ុន្តែនៅកម្រិតអនុគំរូតាង ការចូលរួមក្នុង AC (ពោលគឺ សម្រាប់សមាជិក AC) មានផលប៉ះពាល់វិជ្ជមានគួរកត់សំគាល់ទៅលើផលិតកម្មស្រូវ និងប្រាក់ចំណេញ។ ភាពខុសគ្នារវាងប្រាក់ចំណូលពីស្រូវជាមធ្យមរបស់សមាជិក AC និងគ្រួសារមិនមែនជាសមាជិកអង្គការកសិករ មានប្រហែល ៣២៦.១០០រៀល (៨០,៣២ដុល្លារ) ក្នុង១ហិកតា ហើយប្រាក់ចំណេញទទួលបានពីស្រូវ មានប្រមាណ ៥២៨.៧០០រៀល (១៣០,២២ដុល្លារ) ក្នុងមួយហិកតា ដែលបង្កប់ន័យថា គ្រួសារជាសមាជិកសហករណ៍កសិកម្ម មានបច្ចេកទេសល្អ និងចំណាយមានប្រសិទ្ធភាពខ្ពស់ជាង គ្រួសារមិនមែនជាសមាជិកអង្គការកសិករ (តារាង ២)[៤]។ លទ្ធផលនេះស្របគ្នានឹងការសិក្សារបស់ Bratton (1986), Bachke (2010), and Davis *et al.* (2010)។

ផលប៉ះពាល់នៃការចូលរួមក្នុង FO ទៅលើប្រាក់ចំណូល និងប្រាក់ចំណេញបានពីសត្វចិញ្ចឹមក្នុង ១គ្រួសារ មានបង្ហាញក្នុង តារាង ៣។ ការប៉ាន់ស្មាននេះបង្ហាញថា ការចូលរួមក្នុង FO មានផលប៉ះពាល់វិជ្ជមានគួរកត់សំគាល់ខាងស្ថិតិ ទៅលើប្រាក់ចំណូល (តែមិនមែនប្រាក់ចំណេញទេ) ដែលបានពីផលិតកម្មសត្វចិញ្ចឹមក្នុងគំរូតាងអង្គការកសិករទាំងអស់។ ជាមធ្យមប្រាក់ចំណូលរបស់សមាជិកអង្គការកសិករ ពីផលិតកម្មសត្វចិញ្ចឹមមានប្រមាណ ៩០៣.៣០០រៀល (២២២ដុល្លារ) ក្នុងមួយឆ្នាំខ្ពស់ជាងប្រាក់ចំណូលគ្រួសារមិនមែនជាសមាជិក FOs ហើយភាពខុសគ្នានេះ មានលក្ខណៈគួរកត់សំគាល់ខាងស្ថិតិនៅកម្រិត ១០%។ ទាក់ទិននឹងអនុគំរូតាង ផលប៉ះពាល់មានលក្ខណៈវិជ្ជមានគួរកត់សំគាល់ខាងស្ថិតិទៅលើគ្រួសារសមាជិក FA និងសហករណ៍កសិកម្ម តែមិនមែនលើប្រាក់ចំណូល និងប្រាក់ចំណេញពីផលិតកម្មសត្វចិញ្ចឹមរបស់គ្រួសារសមាជិក FG នោះទេ។ ជាមធ្យម គ្រួសារចូលរួមក្នុង FAs និង ACs រកប្រាក់ចំណូលពីសត្វចិញ្ចឹមបាន ២០០.៩២០រៀល (៥០ដុល្លារ) និង ១៥០.៩៩០រៀល (៣៧ដុល្លារ) រៀងគ្នា ហើយវាមានកម្រិតខ្ពស់ជាងគ្រួសារមិនមែនជាសមាជិក និងមានលក្ខណៈគួរកត់សំគាល់ខាងស្ថិតិនៅកម្រិត ១០%។

ផលប៉ះពាល់វិជ្ជមានគួរកត់សំគាល់នៃ ការចូលរួមក្នុងអង្គការកសិករ ទៅលើតម្លៃផលិតកម្មស្រូវ និងសត្វចិញ្ចឹម ភាគច្រើនកើតឡើងផ្ទាល់ពី ការប្រើប្រាស់បច្ចេកទេសកសិកម្មកាន់តែល្អ ដែលផ្តល់ដោយបណ្តាទីភ្នាក់ងារគាំទ្រ។ លទ្ធផលអង្កេតបានបញ្ជាក់គាំទ្រថា គ្រួសារសមាជិកអង្គការកសិករ ទទួលបានសេវាបច្ចេកទេសកសិកម្ម សម្រាប់លើកកម្ពស់ផលិតភាពដំណាំ និងសត្វចិញ្ចឹមបានច្រើនជាង គ្រួសារមិនមែនជាសមាជិក។ ទោះយ៉ាងនេះក្តី ផលប៉ះពាល់ខ្លាំងទៅលើផលិតភាពស្រូវ និងសត្វចិញ្ចឹមនេះ មិនអាចចាត់ទុកថា បានមកពីសកម្មភាពរួមទាក់ទិននឹងការមានទីផ្សារសម្រាប់ទិញធាតុចូល ឬលក់ផលិតផលនោះទេ។ ដោយសារ សកម្មភាពរួមរបស់សមាជិកអង្គការកសិករមិនសូវមានប្រសិទ្ធភាព ដូច្នេះសមាជិកអង្គការកសិករភាគច្រើន

៤ ការពិភាក្សាពីលទ្ធផលនេះ ផ្តោតលើវិធីសាស្ត្រ Kernel matching algorithm។

ទិញធាតុចូល (៧៦%) និងលក់ផលិតផល (៨១%) ជាលក្ខណៈបុគ្គល ហើយត្រូវបង់ថ្លៃ និងលក់បានថ្លៃ ប្រហាក់ប្រហែលគ្នានឹងគ្រួសារមិនមែនសមាជិកដែរ[៥]។

## សេចក្តីសន្និដ្ឋាន

ការសិក្សានេះសន្និដ្ឋានថា អង្គការកសិករ (FOs) ជាយន្តការអភិវឌ្ឍន៍ជនបទដ៏ល្អមួយ សម្រាប់ពង្រឹងសន្តិសុខស្បៀងគ្រួសារនៅជនបទ តាមរយៈការលើកកម្ពស់ផលិតភាពកសិកម្ម។ ការចូលរួមក្នុង AC មានផលប៉ះពាល់វិជ្ជមានទៅលើសន្តិសុខស្បៀងគ្រួសារជនបទ តាមរយៈការលើកកម្ពស់ផលិតភាពស្រូវ និងផលិតកម្មសត្វចិញ្ចឹម ហើយការចូលរួមក្នុង FA តែមួយមុខ ជះឥទ្ធិពលវិជ្ជមានទៅលើផលិតកម្មសត្វចិញ្ចឹម។ ផលប៉ះពាល់ទាំងនេះ ជាទូទៅអាចចាត់ថា កើតឡើងដោយសារការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម ដោយបណ្តាទីភ្នាក់ងារជួយគាំទ្រ។ ប៉ុន្តែ FOs នៅកម្ពុជា មិនបានលើកកម្ពស់លទ្ធភាពមានទីផ្សាររបស់សមាជិកនានាទេ ពីព្រោះការទិញធាតុចូល និងការលក់ផលិតផលកសិកម្ម ច្រើនធ្វើឡើងជាលក្ខណៈបុគ្គល ដូច្នេះថ្លៃដែលត្រូវចំណាយ ឬតម្លៃដែលអាចលក់បានដោយសមាជិកអង្គការកសិករ គឺវាប្រហាក់ប្រហែលគ្នានឹងគ្រួសារដែលមិនមែនជាសមាជិកដែរ។

ដើម្បីពង្រឹង FOs ឲ្យក្លាយជាឧបករណ៍ដ៏សក្តិសិទ្ធិជួយលើកកម្ពស់ជីវភាពនៅជនបទកម្ពុជា គេត្រូវដោះស្រាយបញ្ហាបារម្ភមួយចំនួនដែលការសិក្សាបានរកឃើញ។ ការបណ្តុះបណ្តាលពីរបៀបធ្វើកសិកម្មឲ្យកាន់តែល្អប្រសើរ គួរតែផ្តល់ជាបន្តបន្ទាប់ទៅដល់ FOs ដើម្បីកែលម្អផលិតភាព។ ក្រៅពីនេះ គោលនយោបាយរដ្ឋាភិបាលក្នុងការផ្តល់ឲ្យ FOs នូវប្រាក់កម្ចីមានរយៈពេលវែង និងការប្រាក់ទាប (ប្រមាណ១០% ក្នុង១ឆ្នាំ និងរយៈពេលបង្វិលសងយ៉ាងតិច ២ឆ្នាំ) អាចជួយឲ្យសមាជិក FOs បង្កើនវិនិយោគក្នុងផលិតកម្មកសិកម្ម។ ម្យ៉ាងទៀតដើម្បីឲ្យការចូលរួមក្នុង FOs ហុចផលបានកាន់តែច្រើនក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពនៅជនបទ អ្នកពាក់ព័ន្ធនានា ជាពិសេសរាជរដ្ឋាភិបាល គួរជួយគាំទ្រជាធាតុចូលបំពេញបន្ថែមមួយចំនួន និងលទ្ធភាពមានទីផ្សារកាន់តែល្អ។ ការធ្វើកសិកម្មតាមកិច្ចសន្យា អាចជាយន្តការដ៏ល្អសម្រាប់ឲ្យ FOs រកបានការចំណាយលើធាតុចូលកម្រិតទាប និងការធានាថ្លៃលើទីផ្សារ។ ដើម្បីធ្វើឲ្យអង្គការកសិករ (FOs) ទាំងអស់នៅកម្ពុជាមាននិរន្តរភាព ជំនួយឧបត្ថម្ភពីខាងក្រៅ (បច្ចេកទេស និងធនធាន) គួរផ្តល់ឲ្យដោយមានផែនការរយៈពេលវែង ដើម្បីអនុញ្ញាតឲ្យអង្គការកសិករ មានពេលរៀនសូត្រធ្វើការងារឲ្យបានសក្តិសិទ្ធិ និងមានប្រសិទ្ធភាព មុនពេលត្រូវដំណើរការដោយឯករាជ្យ។

៥ សូមមើល Theng *et al.* (2011) សម្រាប់លទ្ធផលអង្កេតស្តីពីការទទួលបានសេវាកម្មបណ្តុះបណ្តាល និងការលក់ផលិតផល។

## ឯកសារយោង


Bachke, M.E. (2010), *Do Farmers' Organizations Enhance The Welfare of Small-Scale Farmers?* Working Paper (Aas, Norway: Norwegian University of Life Sciences)

Barham, J. & C. Chitemi (2009), "Collective Action Initiatives to Improve Marketing Performance: Lesson Learn From Farmer Groups in Tanzania," *Food Policy*, Vol. 34, pp. 53-59

Bernard, T. & D. J. Spielman (2009), "Reaching the Poor through Rural Producer Organization? A Study of Agricultural Marketing Cooperatives in Ethiopia", *Food Policy*, Vol. 34, pp. 60-69

Bingen, J., A. Serrano & J. Howard (2003), "Linking Farmer to Market: Different Approaches to Human Capital Development", *Food Policy*, Vol. 28, pp. 405-419

Bratton, Michael (1986), "Farmer Organisations and Food Production", *World Development*, 14 (3), pp. 367-384

Caliendo, M. & S. Kopeinig (2008), "Some Practical Guidance for the Implementation of Propensity Score Matching", *Journal of Economic Surveys*, Vol. 22, No.1, pp. 31-72

Chea, S. (2010), "Final Report on Policy Analysis for Farmer Organisation Development, Department of Agricultural Extension"(Cambodia: MAFF, sponsored by IFAD and FAO)

Chirwa, E., A. Dorward, R. Kachule, I. Kumwenda, J. Kydd, N. Poole, C. Poulton & M. Stockbridge (2005), "Walking Tightropes: Supporting Farmer Organisations for Market Access", Natural Resource Perspective, Number 99 (London: ODI)

Couturier, J., S.O. Savun, & P. Ham (2006), "Inventory of Farmer Organisations in Cambodia". Draft prepared for Office if Farmer Organisation, Department of Agricultural Extension, Ministry of Agriculture, Forestry and Fisheries, Cambodia

Davis, K., Ephraim Nkony, E. Kato, D.A. Mekonnen, M. Orendo, R. Miiro & J. Nkuba (2010), "Impact of Farmer Field Schools on Agricultural Productivity and Productivity and Poverty in East Africa", IFPRI Discussion Paper 00992 (Washington, DC: IFPRI)

Nou Keosothea (2006), "Emerging Structure of Agricultural Cooperative in Cambodia", *Cambodia Development Review* (Phnom Penh: CDRI)

Paula Savanti & Elisabeth Sadoulet (2008), Agriculture's Special Powers in Reducing Poverty. *Special Report: World Bank Institute*, World Bank

Theng V. & Koy R. (2011), "Review of Agricultural Policy and Policy Research", policy discussion paper (Phnom Penh: CDRI)

Theng Vuthy, Nou Keosothea, Keo Socheat, Sum Sreymom & Khiev Pirom (2011), *Do Farmer Organisations Help to Improve Food Security of the Rural Poor in Cambodia: Case Studies of Farmer Groups, Farmer Associations and Agricultural Cooperatives*, CDRI Working Paper Series (forthcoming) (Phnom Penh: CDRI)

World Bank (2005), "Cambodia Rural Sector Strategy Note: Towards a Strategy for Rural Growth and Poverty Reduction" (Washington DC: World Bank)

World Bank (2009), "Poverty Profile and Trend in Cambodia: Findings from the 2007 CSES" (Phnom Penh: World Bank)

# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះ បង្ហាញពីនិន្នាការសូចនាករសេដ្ឋកិច្ចពិភពលោក និងសេដ្ឋកិច្ចនៅអាស៊ីបូព៌ា។

## កំណើនសេដ្ឋកិច្ចពិភពលោក

បណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ អាស៊ីបូព៌ា និងប្រទេសឧស្សាហកម្ម បានព្យាយាមផ្តល់សន្ទុះឡើងវិញ ដល់សេដ្ឋកិច្ចរបស់ខ្លួន ចាប់តាំងពីពេលកើតមានវិបត្តិហិរញ្ញវត្ថុសាកលមក។ បើធៀបនឹងត្រីមាសមុន និងកាលពីមួយឆ្នាំមុន ស្ថានភាពសេដ្ឋកិច្ចនៅត្រីមាសទី២ ឆ្នាំនេះ គួរឲ្យបារម្ភគួរសម ដោយសារប្រទេសជាច្រើនមានកំណើនយឺត។

នៅត្រីមាសទី២ កំណើន ផសស ពិតនៅម៉ាឡេស៊ី ធ្លាក់ចុះមកត្រឹម ៤% ធៀបនឹង ៨,៩% កាលពីមួយឆ្នាំមុន។ កំណើន ផសស នៅសិង្ហបុរី ធ្លាក់ចុះមកត្រឹម ០,៩% ធៀបនឹង ១៨,៧% ដែលជាអត្រាខ្ពស់បំផុតចាប់តាំងពីឆ្នាំ២០០៦។ សេដ្ឋកិច្ចប្រទេសថៃបន្តថយកំណើន ដោយធ្លាក់មកត្រឹម ២,៦% ធៀបនឹង ៩,២% កាលពីមួយឆ្នាំមុន ដោយសារជាចម្បងស្ថានភាពនយោបាយដែលបានប៉ះពាល់ដល់ទំនុកចិត្ត និងវិនិយោគឯកជន ព្រមទាំងទឹកជំនន់ដែលបានប៉ះពាល់ដល់ ប្រជាជនរាប់ពាន់គ្រួសារ។ ទោះបីមានកំណើនយឺតជាងមុនក្តី ក៏ចិន និងហុងកុង នៅតែសម្រេចលទ្ធផលល្អ ដោយមានកំណើន ផសស ពិត ៩,៥% និង ៥,១% រៀងគ្នា ធៀបនឹងមួយឆ្នាំមុន។ កំណើន ផសស នៅកូរ៉េខាងត្បូង ធ្លាក់ចុះពី ៧,១% មកត្រឹម ៣,៤% ហើយកំណើន ផសស នៅតៃវ៉ាន់ ថយចុះមកត្រឹម ៤,៩%។

រហូតមកដល់បច្ចុប្បន្ននេះ ប្រទេសសេដ្ឋកិច្ចជឿនលឿន មិនទាន់កសាងឡើងវិញបានទេ នូវទំនុកចិត្តរបស់អ្នកប្រើប្រាស់ និងវិនិយោគិន។ អត្រាកំណើន ផសស ពីមួយឆ្នាំទៅមួយឆ្នាំ នៅតំបន់អឺរ៉ូ-១២ ធ្លាក់ចុះមកត្រឹម ១,៦% ដោយសារមួយផ្នែកមកពីផលប៉ះពាល់នៃការរឹតវរនយោបាយ និងវិបត្តិបំណុលនៅប្រទេសក្រិច។ ដោយមានកំណើន ផសស ពិត ១,៥% ធៀបនឹង ២,៩% នៅត្រីមាសទី២ ឆ្នាំ២០១០ សហរដ្ឋអាមេរិកបន្តប្រយុទ្ធប្រឆាំងនឹងភាពគ្មានការងារធ្វើ ដែលមានអត្រា ៩,៥% នៅត្រីមាសទី២ ឆ្នាំនេះ។ នៅទីផ្សារ Wall Street ថ្លៃប័ណ្ណភាគហ៊ុនបន្តឡើងចុះ ដែលឆ្លុះបញ្ចាំងពីនិន្នាការពាណិជ្ជកម្មមិនច្បាស់លាស់។ សេដ្ឋកិច្ចប្រទេសជប៉ុន បន្តធ្លាក់ចុះ ហើយ ផសស បានរួមចុះ ១,០% ធៀបនឹងកំណើន ៣,៥% កាលពីមួយឆ្នាំមុន ដោយសារ វិបត្តិមិនទាន់ដោះស្រាយបាននៃការសាយភាយវិទ្យុសកម្មក្រោយពេលមានគ្រោះស៊ូណាមិ និងការប៉ះពាល់ដល់ទំនុកចិត្តរបស់អ្នកប្រើប្រាស់ទៅលើផលិតផលជប៉ុន។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

កំណើនថ្លៃ នៅតែជាបញ្ហាមួយសម្រាប់ប្រទេសសេដ្ឋកិច្ចជឿនលឿនភាគច្រើន ទោះបីជាអត្រាកំណើនស្ថិតនៅកម្រិតមួយសមរម្យក៏ដោយ។ នៅត្រីមាសទី២ ឆ្នាំ២០១១ អតិផរណានៅកម្ពុជា ឡើងដល់ ៦,២% ធៀបនឹង ៤,១% កាលពីមួយឆ្នាំមុន។ ទោះបីគេរំពឹងថា អតិផរណានៅប្រទេសកម្ពុជា នឹងនៅថេរក្នុងឆ្នាំនេះ និងឆ្នាំក្រោយ ប៉ុន្តែអតិផរណាខ្ពស់ដល់ ១៩% នៅប្រទេសវៀតណាម នៅត្រីមាសទី២ ធៀបនឹង ៩% កាលពីមួយឆ្នាំមុន បានបង្កក្តីបារម្ភដល់កម្ពុជា ដោយសារពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ កំពុងកើនឡើង។ ការធ្លាក់ថ្លៃដុល្លារអាមេរិក និងការឡើងថ្លៃប្រេង ក៏អាចប៉ះពាល់ដល់អតិផរណានៅកម្ពុជាដែរ។ នៅត្រីមាសទី២ អតិផរណានៅប្រទេសចិនកើនដល់ ៥,៧% ធៀបនឹង ២,៧% កាលពីមួយឆ្នាំមុន។

នៅត្រីមាសទី២ ប្រាក់រៀលឡើងថ្លៃ ៣,៩% ទល់នឹងដុល្លារអាមេរិក បើធៀបនឹងកាលពីមួយឆ្នាំមុន។ ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ីឡើងថ្លៃ ៦,០% ដុល្លារសិង្ហបុរី ឡើងថ្លៃ ៨,៨% ប្រាក់យន់ចិនឡើងថ្លៃ ៤,០% និង ដុល្លារតៃវ៉ាន់ ឡើងថ្លៃ ៩,៥%។ ប្រាក់ដុងវៀតណាម ធ្លាក់ថ្លៃ ៨,៩%។

## ថ្លៃផលិតផលនៅទីផ្សារពិភពលោក

នៅត្រីមាសទី២ ផលិតផលសំខាន់ៗបន្តឡើងថ្លៃ។ ធៀបនឹងមួយឆ្នាំមុន ពោត (US No. 2) ឡើងថ្លៃ ៩៨% ប្រេងឆា (អឺរ៉ុបពាយព្យ) ឡើងថ្លៃ ៤១% និង កៅស៊ូ (SMR 5) ឡើងថ្លៃ ៦១%។ គ្រោះធម្មជាតិនៅបណ្តាប្រទេសកសិកម្មសំខាន់ៗ ដូចជា ថៃ និង វៀតណាម អាចប៉ះពាល់ដល់ផលស្រូវ និងផលិតផលសំខាន់ៗជាច្រើន។ អង្ករ (Thai 100% B) ឡើងថ្លៃ ១២% ដល់ ៥១៤,៣ដុល្លារក្នុងមួយតោន សណ្តែកសៀង (US No.1) ឡើងថ្លៃ ៤២% ដល់ ៥២៥,៧ដុល្លារ/តោន។ ក្នុងរយៈពេលដដែល ប្រេងឆៅ (OPEC spot) ឡើងថ្លៃ ៤៧% ដល់ ១១៣,៣ដុល្លារក្នុងមួយធុង ប្រេងសាំង (US Gulf Coast) ឡើងថ្លៃ ៤៥% ដល់ ០,៧៨ដុល្លារក្នុងមួយលីត្រ និង ប្រេងម៉ាសូត (Low sulphur No.2) ឡើងថ្លៃ ៣៧% ដល់ ០,៧៦ដុល្លារក្នុងមួយលីត្រ។

---

១ អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១១ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 7.7 | 13.4 | 10.6 | 10.2 | 6.8 | - | - | - | - | - | - | |
| ឥណ្ឌូនេស៊ី | 5.1 | 5.6 | 5.4 | 6.3 | 6.1 | 4.5 | 5.7 | 6.2 | 5.8 | 6.9 | 6.5 | 6.5 |
| ម៉ាឡេស៊ី | 7.0 | 5.2 | 5.9 | 6.3 | 4.6 | -1.7 | 16.9 | 8.9 | 5.3 | 4.8 | 4.6 | 4.0 |
| សិង្ហបុរី | 8.5 | 5.7 | 7.7 | 7.7 | 1.1 | -2.2 | 17.4 | 18.7 | 10.5 | 12.0 | 8.3 | 0.9 |
| ថៃ | 6.0 | 4.5 | 4.8 | 4.9 | 2.6 | -2.3 | 12.0 | 9.2 | 6.7 | 3.8 | 3.0 | 2.6 |
| វៀតណាម | 7.5 | 8.4 | 8.1 | 8.5 | 6.2 | - | 5.8 | 6.4 | 7.2 | 7.3 | 5.4 | 5.7 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 9.5 | 9.6 | 10.5 | 11.9 | 9.0 | 8.2 | 11.9 | 10.3 | 9.7 | 9.8 | 9.7 | 9.5 |
| ហុងកុង | 8.3 | 6.5 | 6.6 | 6.4 | 2.4 | -2.8 | 8.0 | 6.5 | 6.8 | 6.2 | 7.2 | 5.1 |
| កូរ៉េខាងត្បូង | 4.7 | 4.7 | 5.0 | 4.9 | 2.2 | 0.0 | 8.1 | 7.1 | 4.5 | 4.8 | 4.2 | 3.4 |
| តៃវ៉ាន់ | 5.7 | 4.1 | 4.6 | 5.2 | 0.1 | -6.3 | 14.6 | 12.9 | 9.8 | 6.9 | 6.5 | 4.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 1.8 | 1.5 | 2.7 | 2.9 | 0.9 | -3.0 | 0.6 | 1.7 | 1.9 | 2.0 | 2.5 | 1.6 |
| ជប៉ុន | 3.4 | 2.5 | 2.1 | 2.0 | -0.7 | -3.7 | 5.5 | 3.5 | 5.0 | 2.2 | -1.0 | -1.0 |
| សហរដ្ឋអាមេរិក | 4.4 | 3.7 | 3.3 | 2.2 | 1.1 | -2.2 | 2.8 | 2.9 | 2.3 | 2.8 | 2.3 | 1.5 |

*Sources: International Monetary Fund, Economist and countries' statistic offices.*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៤-២០១១ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 4.0 | 5.8 | 4.7 | 10.5 | 19.7 | -0.5 | 7.0 | 4.1 | 1.8 | 3.3 | 3.6 | 6.2 |
| ឥណ្ឌូនេស៊ី | 8.3 | 10.5 | 13.4 | 6.4 | 10.1 | 4.9 | 3.6 | 4.4 | 6.2 | 6.3 | 6.8 | 5.9 |
| ម៉ាឡេស៊ី | 1.6 | 3.1 | 3.7 | 2.0 | 5.3 | 0.6 | 1.3 | 1.6 | 1.9 | 2.1 | 2.8 | 3.3 |
| សិង្ហបុរី | 1.7 | 0.5 | 1.0 | 2.1 | 6.5 | 0.2 | 0.9 | 3.1 | 3.4 | 4.0 | 5.2 | 4.7 |
| ថៃ | 2.7 | 4.5 | 4.7 | 2.2 | 5.5 | -0.8 | 3.7 | 3.3 | 3.3 | 2.0 | 3.0 | 4.1 |
| វៀតណាម | 7.8 | 8.2 | 7.7 | 8.3 | 23.3 | 7.1 | 7.5 | 9.0 | 8.4 | 10.9 | 12.8 | 19.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 3.9 | 1.8 | 1.5 | 4.8 | 5.9 | 0.1 | 2.1 | 2.7 | 3.3 | 4.7 | 5.1 | 5.7 |
| ហុងកុង | -0.4 | 1.1 | 2.2 | 2.0 | 4.3 | 0.5 | 1.9 | 2.6 | 2.3 | 2.9 | 4.0 | 5.1 |
| កូរ៉េខាងត្បូង | 3.5 | 2.8 | 2.4 | 2.5 | 4.6 | 2.8 | 2.7 | 2.6 | 2.9 | 3.6 | 4.4 | 4.2 |
| តៃវ៉ាន់ | 1.6 | 2.3 | 0.6 | 1.8 | 3.2 | -0.7 | 1.3 | 1.1 | 0.4 | 1.1 | 1.3 | 1.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 2.2 | 2.2 | 2.1 | 2.1 | 3.3 | 0.5 | 1.1 | 1.5 | 1.7 | 2.0 | 2.5 | 2.7 |
| ជប៉ុន | Nil | -0.3 | 0.5 | 0.1 | 1.4 | -1.3 | -1.2 | -0.9 | -0.9 | 0.1 | 0.0 | 0.3 |
| សហរដ្ឋអាមេរិក | 2.7 | 3.4 | 3.2 | 2.9 | 3.8 | -0.3 | 2.3 | 1.8 | 1.2 | 1.3 | 2.1 | 3.5 |

*Sources: International Monetary Fund, Economist and National Institute of Statistics.*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៥-២០១១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | |
| កម្ពុជា (រៀល) | 4092.50 | 4103.20 | 4062.70 | 4054.20 | 4141.03 | 4180.11 | 4209.02 | 4236.69 | 4122.58 | 4041.90 | 4044.89 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 9705.00 | 9134.00 | 9419.00 | 9699.00 | 10303.81 | 9266.93 | 9,132.00 | 8995.11 | 8965.70 | 8902.02 | 8593.94 |
| ម៉ាឡេស៊ី (រីងហ្គិត) | 3.80 | 3.70 | 3.30 | 3.30 | 3.50 | 3.37 | 3.24 | 3.15 | 3.11 | 3.05 | 3.02 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.66 | 1.59 | 1.51 | 4.58 | 1.45 | 1.40 | 1.36 | 1.36 | 1.30 | 1.28 | 1.24 |
| ថៃ (បាត) | 40.20 | 37.90 | 32.22 | 33.36 | 34.13 | 32.90 | 32.33 | 31.63 | 29.99 | 30.56 | 30.28 |
| វៀតណាម (ដុង) | 15,859.00 | 15,994.00 | 16,030.00 | 16,382.00 | 17767.00 | 18,825.67 | 18,993.00 | 19,485.00 | 19499.48 | 20273.83 | 20693.58 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | |
| ចិន (យ៉ន់) | 8.19 | 7.97 | 8.03 | 6.94 | 6.83 | 6.83 | 6.77 | 6.77 | 6.66 | 6.58 | 6.50 |
| ហុងកុង (ដុល្លារហុងកុង) | 7.78 | 7.77 | 7.80 | 7.78 | 7.75 | 7.76 | 7.78 | 7.77 | 7.76 | 7.79 | 7.78 |
| កូរ៉េខាងត្បូង (វ៉ុន) | 1024.00 | 955.00 | 929.04 | 1137.23 | 1273.30 | 1143.97 | 1166.04 | 1182.41 | 1132.85 | 1120.19 | 1084.27 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 32.10 | 32.50 | 32.85 | 31.54 | 33.04 | 31.93 | 31.90 | 31.90 | 30.36 | 29.30 | 28.86 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.80 | 0.80 | 0.70 | 0.84 | 0.71 | 0.72 | 0.79 | 0.77 | 0.74 | 0.73 | 0.70 |
| ជប៉ុន (យ៉េន) | 110.20 | 116.40 | 117.80 | 102.46 | 93.26 | 90.73 | 92.20 | 85.74 | 82.53 | 82.33 | 81.66 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៥-២០១១ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ពោត (US No. 2) - USA (USD/តោន) | 110.65 | 111.04 | 149.08 | 218.15 | 167.32 | 162.88 | 157.41 | 176.13 | 238.81 | 280.32 | 311.63 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 427.47 | 433.85 | 707.68 | 912.23 | 686.84 | 807.67 | 813.00 | 874.67 | 1108.00 | 1251.00 | 1147.00 |
| កៅស៊ូ SMR 5 | 1430.5 | 1996.30 | 2202.30 | 2586.30 | 1890.5 | 3105.90 | 3083.73 | 3175.97 | 4257.27 | 5278.03 | 4968.77 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 221.67 | 282.00 | 305.36 | 615.32 | 474.47 | 565.67 | 461.33 | 468.33 | 531.00 | 528.25 | 514.33 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 262.03 | 213.88 | 294.59 | 460.41 | 444.25 | 372.68 | 370.95 | 406.88 | 480.24 | 537.24 | 525.66 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 33.50 | 61.58 | 69.25 | 95.44 | 237.26 | 75.73 | 77.00 | 74.91 | 84.17 | 100.70 | 113.31 |
| សាំង - US Gulf Coast (សេន/លីត្រ) | 30.90 | 47.70 | 53.58 | 62.22 | 51.70 | 53.87 | 54.43 | 51.54 | 57.23 | 67.92 | 78.73 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 29.48 | 51.35 | 55.51 | 76.20 | 42.98 | 53.87 | 55.13 | 53.64 | 61.68 | 72.47 | 75.72 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចចំបងៗ

វិស័យសេវាកម្ម នៅតែជាកត្តាជំរុញចំបងមួយនៃការងើបសេដ្ឋកិច្ចឡើងវិញនៅកម្ពុជា។ នៅត្រីមាសទី២ គម្រោងវិនិយោគឯកជនក្នុងវិស័យសេវាកម្ម អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានចំនួន ២២២៩,២លានដុល្លារ គឺកើនឡើង ៩៦៤% ធៀបនឹងត្រីមាសមុន ឬកើន ១៧៣៣% ធៀបនឹងឆ្នាំមុន។ វិស័យនេះបានកើនឡើង ទោះបីជាមានការធ្លាក់ចុះចំនួនភ្ញៀវបរទេសមកដល់តាមផ្លូវអាកាស (៣៣%) និងតាមផ្លូវគោក និងផ្លូវទឹក (៩%) នៅត្រីមាសទី២ នេះ បើធៀបនឹងត្រីមាសមុនក្ដី។ វិស័យឧស្សាហកម្ម ជាពិសេសវិស័យកាត់ដេរ ក៏បង្ហាញសញ្ញានៃការងើបឡើងវិញដែរ ដោយកើន ៥១៦% ធៀបនឹងត្រីមាសមុន ឬ ៦៥៩% ធៀបនឹងមួយឆ្នាំមុនដល់ ៤១៣,៥លានដុល្លារ។ ប៉ុន្តែចំណែកនៃវិស័យកាត់ដេរ ធ្លាក់ចុះដល់ ២៦% ធៀបនឹង ៨៥% នៅត្រីមាសទី១ និង ៣៩% កាលពីមួយឆ្នាំមុន ដែលអាចបង្ហាញពីពិពិធកម្មនៃវិស័យឧស្សាហកម្ម។

ទោះបីប្រទេសចិន និងប្រទេសអាស៊ាននានា បានចាប់អារម្មណ៍កាន់តែខ្លាំងលើវិនិយោគក្នុងផ្នែកស្រូវអង្ករ និងផ្នែកកសិកម្មផ្សេងៗទៀតក្តី ក៏កម្ពុជានៅតែពិបាកទាក់ទាញបាននូវវិនិយោគក្នុងស្រុក និងបរទេស។ នៅត្រីមាសទី២ នេះ មិនមានការអនុម័តគម្រោងវិនិយោគកសិកម្មថ្មី ឬពង្រីកបន្ថែមទេ។ វិស័យសំណង់ បន្តងើបឡើងវិញ ដោយសារគម្រោងសាងសង់ដែលបានផ្អាក ដូចជា Vattanac Tower បានចាប់ដំណើរការឡើងវិញ។ តម្លៃគម្រោងសំណង់ភូមិគ្រឹះនិងផ្ទះ និងផ្ទះល្វែង បានអនុម័តកើន ៧៧% ដល់ ៧៧,៤លានដុល្លារ ធៀបនឹងត្រីមាសមុន ប៉ុន្តែនៅទាបជាខ្លាំង បើធៀបនឹងមុនពេលមានវិបត្តិ។

នៅត្រីមាសទី២ ការនាំចេញបន្ទុះឡើង ដល់ ១១៣២,១ លានដុល្លារ ឬ កើន ៣៨% ធៀបនឹងឆ្នាំមុន ដោយក្នុងនេះផលិតផលកាត់ដេរ រួមចំណែកបាន ៨៥% និងផ្តោតជាសំខាន់លើទីផ្សារសហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក។ ប៉ុន្តែកំណើនពីមួយឆ្នាំទៅមួយឆ្នាំ នៃការនាំចេញផលិតផលកាត់ដេរ ទៅសហរដ្ឋអាមេរិក (១២%) និងសហភាពអឺរ៉ុប (៦៣%) មានកម្រិតទាបជាងទៅតំបន់អាស៊ាន (១២១,១%) ជប៉ុន (៨៨%) និងប្រទេសផ្សេងៗទៀត (៦៦%)។ ក្នុងរយៈពេលដដែល ការនាំចេញផលិតផលកសិកម្មកើន ៥១៧% ដល់ ១៦៨ លានដុល្លារ ការនាំចេញកៅស៊ូកើន ២៥២% ដល់ ៤៨,៦ លានដុល្លារ និងការនាំចេញឈើកើន ២៧៣% ដល់ ១៦,៨ លានដុល្លារ។ ប៉ុន្តែការនាំចេញត្រីធ្លាក់ចុះ ៤៣% មកត្រឹម ០,៤លានដុល្លារ។

ក្នុងរយៈពេលដដែល ការនាំចូលសរុបកើន ៦៣% ដល់ ៩១៨,៨លានដុល្លារ ក្នុងនេះការនាំចូលប្រេងសាំងមានចំណែក ៨,៣% និង ការនាំចូលប្រេងម៉ាស៊ូតមាន ១៥%។ ការនាំចូលប្រេងសាំងកើន ២៤២% និងការនាំចូលប្រេងម៉ាស៊ូតកើន ១៣៤%។ ការនាំចូលសម្ភារៈសំណង់ ធ្លាក់ចុះ ៤,០% មកត្រឹម ១២,៧លានដុល្លារ ដោយសារកំណើនយឺតនៃវិស័យអចលនទ្រព្យ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី៤ឆ្នាំ២០១០ចំណូលសរុបរបស់រាជរដ្ឋាភិបាលកើន ១៧% ដល់ ១៦៧៥៣ពាន់លានរៀល ធៀបនឹងត្រីមាសទី៣ ក្នុងនោះមាន ៩៤% ជាចំណូលចរន្ត។ ចំណូលពន្ធកើន ០,៣% ដល់ ១២២៩,៦៣ពាន់លានរៀល ស្របពេលដែលចំណូលមិនមែនពន្ធ កើន ៦៦% ដល់ ៣៤០,៩៣ពាន់លានរៀល។ ក្នុងរយៈពេលដដែល ចំណាយសរុបថយចុះ ១៩% មកត្រឹម ១៩៤៥,៤៣ពាន់លានរៀល ក្នុងនោះចំណាយមូលធនធ្លាក់ចុះ ២៤% មកត្រឹម ៦៧៥,៦៣ពាន់លានរៀល ហើយចំណាយចរន្តធ្លាក់ចុះ ១៦% មកត្រឹម ១២៦៩,៨៣ពាន់លានរៀល។ នៅត្រីមាស ទី៤ ចំណាយលើប្រាក់បៀវត្សរ៍សរុប មានចំណែក ៤៥% នៃចំណាយចរន្ត ខណៈដែលឧបត្ថម្ភធន និងជំនួយសង្គមកិច្ច មានចំណែក ១៨%។ ឱនភាពថវិកា មានសរុប ២០៧,៣ពាន់លានរៀល។

## អតិផរណា និងអត្រាប្តូរប្រាក់បរទេស

ការគ្រប់គ្រងអតិផរណា នៅតែមានបញ្ហា។ នៅត្រីមាសទី២ ឆ្នាំ២០១១ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (គ្រប់មុខ) កើន ៦,៣% ធៀបនឹងមួយឆ្នាំមុន។ ថ្លៃអាហារ និងភេសជ្ជៈគ្មានជាតិស្រាកើន ៧,៦% ប៉ុន្តែថ្លៃដឹកជញ្ជូន ធ្លាក់ចុះ ៧,៣%។ ក្នុងរយៈពេលដដែល មាសឡើងថ្លៃ ២៧% ដល់ ១៨១,៥ដុល្លារ/ជី ប្រេងម៉ាស៊ូតឡើងថ្លៃ ២៥% ដល់ ៤៧៨៤,៦រៀល/លីត្រ និង ប្រេងសាំងឡើងថ្លៃ ១៦% ដល់ ៥០៦៥,៥រៀល/លីត្រ។ ប្រាក់រៀលឡើងថ្លៃ ៣,៨% ធៀបនឹងប្រាក់ដុល្លារអាមេរិក ដល់ ៤០៤៤,៩រៀល/ដុល្លារ និង ១១% ធៀបនឹងប្រាក់ដុងវៀតណាម ដល់ ១៩,៦រៀល/១០០ដុង ប៉ុន្តែ ធ្លាក់ថ្លៃ ៣% ទល់នឹងប្រាក់បាតថៃ ដោយប្តូរបាន ១៣៣,៨រៀល/បាត។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី១ ឆ្នាំ២០១១ រូបិយវត្ថុទូទៅ (M2) កើន ១៧,៦% ធៀបនឹងមួយឆ្នាំមុន ដល់ ២០.២៧៨,៣ពាន់លានរៀល ដោយក្នុងនោះ ទ្រព្យសកម្មបរទេសសុទ្ធ កើន ១០,១% ដល់ ១៧.០៧៩ពាន់លានរៀល ហើយទ្រព្យសកម្មក្នុងស្រុកសុទ្ធ កើន ៨៦% ដល់ ៣១៩៩,២ពាន់លានរៀល។ ក្នុងរយៈពេលដដែល រូបិយវត្ថុ M1 កើន ១១,១% ដល់ ៣៤៩៧,២ពាន់លានរៀល និងរូបិយវត្ថុផ្សេងៗ កើន ១៩,១% ដល់ ១៦.៧៨១,១ពាន់លានរៀល។

## ស្ថានភាពក្រីក្រ

យោងតាមអង្កេតពលករងាយរងគ្រោះរបស់ CDRI ក្នុងខែសីហា ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករ ២ក្រុម ក្នុងចំណោម ៩ក្រុមមិនមែនខាងកាត់ដេរ បានធ្លាក់ចុះ។ អ្នកបម្រើតុ

---

១ អត្ថបទនេះ រៀបរៀងដោយលោក វ័ន្ត វណ្ណា អ្នកស្រាវជ្រាវ កញ្ញា អ៊ួន វិមល និង លោកស្រី ប៊ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

តាមភោជនីយដ្ឋាន រងគ្រោះខ្លាំងបំផុត ដោយសារប្រាក់ចំណូលប្រចាំថ្ងៃពិតធ្លាក់ចុះ១៦%បន្ទាប់មកគឺអ្នកលីសែង(ចុះ០,៦%)។ ប្រាក់ចំណូលប្រចាំថ្ងៃពិត កើនឡើងសម្រាប់កម្មករសំណង់មានជំនាញ អ្នកលក់បន្លែតូចតាច អ្នកស៊ីឈ្នួលធ្វើស្រែ អ្នករត់ម៉ូតូឌុប អ្នកធាក់ស៊ីក្លូ អ្នករើសអេតចាយ និងកម្មករសំណង់គ្មានជំនាញ។

ដូចមានបង្ហាញក្នុងតារាង៨ អ្នកបម្រើតុតាមភោជនីយដ្ឋានរងគ្រោះខ្លាំងបំផុត ដោយប្រាក់ចំណូលប្រចាំថ្ងៃពិត ធ្លាក់ចុះ ១៦% មកត្រឹម ៥៤១០រៀល ធៀបនឹង ៦៤២៧រៀល កាលពីខែដូចគ្នា ឆ្នាំ២០១០ ប៉ុន្តែចំណាយប្រចាំថ្ងៃ ក៏ធ្លាក់ចុះ ២,៦% មកត្រឹម ១៤០២,៤រៀលដែរ។ ទោះបីជាប្រាក់ចំណូលធ្លាក់ចុះគួរឱ្យកត់សម្គាល់ដូច្នេះក្តី ក៏មានអ្នកបម្រើតុតែ ១២% ប៉ុណ្ណោះដែលជំពាក់បំណុលគេ។

ក្នុងចំណោមក្រុមពលករមិនមែនខាងកាត់ដេរទាំង ៩ក្រុម ប្រាក់ចំណូលរបស់អ្នកលីសែង បានធ្លាក់ចុះបន្តិច ពី ១០.៥២៥រៀល មកត្រឹម ១០.៤៦៥រៀល ហើយចំណាយប្រចាំថ្ងៃរបស់ពួកគេ កើន ០,៨% ដល់ ៥៦០៥រៀល។ ក្នុងចំណោមអ្នកលីសែងបានឆ្លើយសម្ភាសន៍ មាន ៧៥% ត្រូវជួលកន្លែងស្នាក់នៅ ២២,៥% ស្នាក់នៅផ្ទះបងប្អូន និង ២,៥% រស់នៅតាមដងផ្លូវ ឬនៅវត្ត។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញ ស្ទុះឡើង ២០% ទៀត (ពីមុនបាន ៨៧៤៤រៀល) ដោយសារអនុមតិគម្រោងសាងសង់មានច្រើន ដោយកើនចំនួនដល់ ២៧៨% ចាប់ពីខែសីហា ២០១០ ដល់ខែសីហា ២០១១។ អង្កេតបានរកឃើញថា កម្មករសំណង់គ្មានជំនាញ ៦០% បានរៀបការរួច ៣៧,៥% នៅលីវ និង ២,៥% ជាពោះម៉ាយ ឬមេម៉ាយ។

ប្រាក់ចំណូលរបស់អ្នកស៊ីឈ្នួលធ្វើស្រែ មានកំណើនខ្ពស់បំផុតលំដាប់ទី២ គឺកើនជិតដល់ ១៩% ពី ៦១៨៦រៀល ដល់ ៧៣៤៥រៀល ថ្វីបើវាបានធ្លាក់ចុះកាលពីដើមឆ្នាំក្តី។ អ្នកស៊ីឈ្នួលធ្វើស្រែ ៥៥% គ្មានដីធ្វើស្រែទេ ខណៈដែល ៤០% មានដីកសិកម្ម តិចជាង ១ហិកតា។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នករើសអេតចាយកើន១៧% ដល់ ៧៥៥៧រៀល ធៀបនឹងខែដូចគ្នាឆ្នាំមុន ដោយសាររបស់អេតចាយឡើងថ្លៃ។ ក្នុងចំណោមអ្នករើសអេតចាយបានឆ្លើយសម្ភាសន៍ មាន ៤២,៥% បានចូលរៀនបឋមសិក្សា ១២,៥% ចូលរៀនអនុវិទ្យាល័យ ២,៥% ចូលរៀនវិទ្យាល័យ និង ៤២,៥% មិនបានចូលរៀនទេ។

ប្រាក់ចំណូលរបស់អ្នកធាក់ស៊ីក្លូ ដែលធ្លាក់ចុះកាលពីខែឧសភា បានកើនឡើងវិញនៅខែសីហា។ អ្នកធាក់ស៊ីក្លូបានឆ្លើយសម្ភាសន៍ទាំងអស់ សុទ្ធតែជាអ្នករកចំណូលចម្បងចិញ្ចឹមគ្រួសារ។

ចំណូលប្រចាំថ្ងៃពិតរបស់កម្មករកាត់ដេរ កើនឡើង ២,៦% ដល់ ៨៦៨៧រៀល/ថ្ងៃ ធៀបនឹង ៨៤៧០រៀល/ថ្ងៃ កាលពីខែសីហា ឆ្នាំមុន។ មាន ២៧% នៃកម្មករកាត់ដេរ ឆ្លើយសម្ភាសន៍ទាំងអស់ បានធ្វើការម៉ោងបន្ថែមញឹកញាប់ ៥៨% បានធ្វើការម៉ោងបន្ថែមខ្លះៗ និង ១៥% មិនបានធ្វើការម៉ោងបន្ថែមទេ។

តារាង១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៤-១១

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 12.3 | 26.8 | 498.0 | 135.6 | 92 | 445.8 | 165.7 | 41.4 | 278.0 | 36.7 | 4.1 | 0.0 |
| ឧស្សាហកម្ម | 187.9 | 914.6 | 365.3 | 709.1 | 724.9 | 1043.3 | 247.7 | 54.5 | 44.3 | 87.7 | 67.1 | 413.5 |
| *កាត់ដេរ* | *132.6* | *174.4* | *89.4* | *170.7* | *142.8* | *87.58* | *13.1* | *21.3* | *29.3* | *50.0* | *57.1* | *108.4* |
| សេវាកម្ម | 91.8 | 155.5 | 2939.1 | 1742.5 | 10,003.2 | 4121.5 | 89.5 | 121.6 | 0 | 1096.2 | 209.5 | 2229.2 |
| *សណ្ឋាគារ និងទេសចរណ៍* | *55.9* | *102.6* | *345.0* | *1048.3* | *8758.1* | *3980.1* | *3.78* | *14.0* | *0* | *1087.4* | *107.9* | *2221.9* |
| សរុប | 292.0 | 1096.9 | 3802.4 | 2587.2 | 10570.9 | 5610.6 | 502.9 | 217.5 | 322.3 | 1220.6 | 280.72 | 2642.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | -91.2 | -56.8 | 48.2 | 278.8 | -77.0 | 841.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -5.6 | 275.6 | 246.6 | -32.0 | 308.6 | -46.9 | -59.8 | 452.0 | -16.6 | -71.3 | -44.2 | 1115.0 |

*Including expansion project approvals. Source: Cambodian Investment Board*

តារាង២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៤-១១

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 30.3 | 45.5 | 33.1 | 79.1 | 154.7 | 64.3 | 5.1 | 7.5 | 14.1 | 9.5 | 4.1 | 5.9 |
| ផ្ទះល្វែង | 167.6 | 204.2 | 213.3 | 297.2 | 221.6 | 149.6 | 11.1 | 127.2 | 25.3 | 20.3 | 16.1 | 22.8 |
| ផ្សេងៗ | 65.6 | 109.1 | 76.8 | 259.6 | 740.9 | 187.8 | 35.2 | 67.4 | 38.9 | 76.2 | 23.6 | 48.7 |
| សរុប | 263.5 | 358.8 | 323.3 | 635.8 | 1117.0 | 401.7 | 51.4 | 202.1 | 78.4 | 106.0 | 43.8 | 77.4 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | -23.1 | 293.2 | -61.2 | 35.3 | -58.7 | 76.7 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 32.5 | 36.2 | -9.9 | 96.7 | 75.7 | -64.0 | -71.6 | 224.4 | -14.2 | 58.7 | -14.8 | -61.7 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ចំនួនអ្នកដំណើរមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៤-១១

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 626.1 | 856.5 | 1029.0 | 1296.5 | 1239.4 | 1111.7 | 371.5 | 260.9 | 288.3 | 383.7 | 427.4 | 286.9 |
| តាមផ្លូវគោក និងទឹក | 428.9 | 565.1 | 672.9 | 718.6 | 881.9 | 1049.8 | 312.2 | 276.6 | 293.8 | 321.4 | 351.0 | 319.6 |
| សរុប | 1055.0 | 1421.6 | 1701.9 | 2015.1 | 2121.3 | 2161.5 | 683.7 | 537.5 | 582.0 | 705.1 | 778.4 | 606.5 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | 16.4 | -21.4 | 8.3 | 21.2 | 10.4 | -22.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 50.5 | 34.7 | 19.7 | 28.4 | 5.3 | 1.9 | 9.9 | 15.8 | 19.4 | 20.0 | 13.9 | 12.8 |

*Source: Ministry of Tourism*

## តារាង៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៤-១១

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 2099.4 | 2452.4 | 2922.8 | 3161.6 | 3209.5 | 2889.0 | 693.8 | 820.8 | 1045.4 | 1070.9 | 1017.6 | 1132.1 |
| ក្នុងនេះ៖ សម្លៀកបំពាក់* | 2027.0 | 2352.8 | 2810.8 | 3050.2 | 3097.8 | 2565.3 | 625.5 | 716.9 | 938.3 | 942.7 | 880.5 | 964.2 |
| *- សហរដ្ឋអាមេរិក* | 1270.9 | 1555.6 | 1851.7 | 1959.9 | 1913.0 | 1512.6 | 380.5 | 416.7 | 531.9 | 524.8 | 464.5 | 466.7 |
| *- សហភាពអឺរ៉ុប* | 590.8 | 506.9 | 603.0 | 660.9 | 693.4 | 644.7 | 137.2 | 184.8 | 239.4 | 248.0 | 232.0 | 301.4 |
| *- អាស៊ាន* | 1.7 | 70.7 | 80.4 | 90.3 | 99.6 | 6.9 | 2.2 | 1.9 | 2.9 | 3.0 | 3.8 | 4.2 |
| *- ជប៉ុន* | 22.1 | 25.0 | 40.6 | 30.1 | 26.5 | 44.6 | 19.8 | 14.9 | 25.5 | 26.3 | 34.3 | 28.0 |
| *- ប្រទេសផ្សេងៗ* | 141.5 | 194.6 | 235.1 | 309.0 | 365.3 | 356.5 | 85.7 | 98.6 | 138.6 | 140.7 | 145.9 | 163.9 |
| កសិកម្ម | 53.5 | 61.3 | 59.7 | 55.6 | 44.6 | 60.5 | 21.2 | 27.2 | 44.9 | 72.3 | 74.0 | 167.9 |
| *- កៅស៊ូ* | 30.2 | 36.7 | 41.5 | 41.0 | 35.8 | 39.8 | 11.9 | 13.8 | 25.4 | 38.1 | 49.9 | 48.6 |
| *- ឈើ* | 11.1 | 10.3 | 8.6 | 8.7 | 3.4 | 3.5 | 2.8 | 4.5 | 8.8 | 18.7 | 6.2 | 16.8 |
| *- ត្រី* | 9.8 | 10.1 | 5.9 | 3.2 | 2.3 | 3.2 | 0.8 | 0.7 | 0.5 | 0.8 | 0.6 | 0.4 |
| *- ផ្សេងៗ* | 2.4 | 4.2 | 3.7 | 2.7 | 3.1 | 14.0 | 5.7 | 8.2 | 10.2 | 14.7 | 17.3 | 31.3 |
| ផ្សេងៗ | 18.9 | 38.3 | 52.3 | 55.8 | 67.1 | 263.2 | 47.1 | 76.7 | 62.2 | 55.9 | 63.2 | 70.8 |
| ការនាំចូលសរុប | 871.1 | 2513.0 | 512.2 | 554.8 | 1010.9 | 2239.0 | 505.6 | 563.2 | 731.3 | 677.1 | 728.7 | 918.8 |
| ក្នុងនេះ៖ សាំង | 30.2 | 40.2 | 38.8 | 58.7 | 70.1 | 91.2 | 28.8 | 22.4 | 27.6 | 30.5 | 62.0 | 76.7 |
| ម៉ាស៊ូត | 109.4 | 93.1 | 113.0 | 122.8 | 113.5 | 180.8 | 49.8 | 55.4 | 48.0 | 50.5 | 92.5 | 129.8 |
| សម្ភារៈសំណង់ | 23.2 | 134.7 | 56.5 | 69.0 | 77.8 | 49.7 | 13.7 | 13.2 | 16.7 | 13.8 | 11.8 | 12.7 |
| ផ្សេងៗ | 708.4 | 2245.0 | 303.9 | 304.3 | 749.5 | 1917.3 | 413.3 | 472.2 | 638.9 | 582.3 | 562.4 | 699.6 |
| ជញ្ជីងពាណិជ្ជកម្ម | 1228.3 | -60.6 | 2410.6 | 2606.8 | 2198.6 | 650.0 | 188.2 | 257.6 | 314.1 | 393.8 | 289.0 | 213.3 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | 8.0 | 14.6 | 30.9 | 0.5 | -6.6 | 9.5 |
| ការនាំចេញសរុប | - | - | - | - | - | - | 5.9 | 18.3 | 27.3 | 2.4 | -5.0 | 11.3 |
| ការនាំចូលសរុប | - | - | - | - | - | - | -5.1 | 11.4 | 29.8 | -7.4 | 7.6 | 26.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 24.5 | 16.1 | 19.5 | 8.5 | 1.6 | -10.0 | 4.0 | 45.6 | 75.2 | 62.7 | 40.8 | 34.5 |
| ការនាំចេញសរុប | 23.4 | 16.3 | 19.2 | 8.2 | 1.5 | -17.2 | -2.3 | 46.8 | 68.5 | 63.5 | 46.7 | 37.9 |
| ការនាំចូលសរុប | 13.2 | 189.6 | -79.6 | 8.3 | 82.2 | 121.5 | -14.5 | -7.4 | 51.0 | 27.1 | 44.1 | 63.1 |

*Import data include tax-exempt imports. Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF (website).*

## តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៥-១១ (ពាន់លានរៀល)

| | 2005 | 2006 | 2007 | 2008 | 2009 | | | | 2010 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 |
| ចំណូលសរុប | 2625.0 | 3259.2 | 1146.1 | 5290.0 | 1101.7 | 1252.7 | 1184.7 | 1346.1 | 1536.8 | 1341.1 | 1436.0 | 1675.0 |
| ចំណូលចរន្ត | 2474.0 | 2881.8 | 1141.6 | 5210.7 | 1097.7 | 1245.7 | 1174.9 | 1337.7 | 1526.4 | 1330.9 | 1431.2 | 1570.5 |
| ចំណូលពន្ធ | 1911.0 | 2270.9 | 965.2 | 4409.9 | 947.4 | 1096.5 | 999.5 | 1224.1 | 1094.1 | 1143.8 | 1225.5 | 1229.6 |
| ពន្ធក្នុងស្រុក | - | - | 661.8 | 3248.4 | 712.0 | 838.7 | 731.8 | 808.5 | 820.3 | 890.9 | 916.9 | 905.5 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | 303.5 | 1161.5 | 235.4 | 257.8 | 268.0 | 303.4 | 273.7 | 253.0 | 308.6 | 324.1 |
| ចំណូលមិនមែនពន្ធ | 563.0 | 610.9 | 176.4 | 800.8 | 150.3 | 149.2 | 176.1 | 225.7 | 432.4 | 187.1 | 205.7 | 340.9 |
| ចំណូលលើទ្រព្យសម្បត្តិ | - | - | 13.6 | 78.0 | 13.1 | 9.7 | 27.5 | 14.3 | 237.0 | 20.2 | 19.5 | 14.5 |
| លក់ទំនិញ និងសេវា | - | - | 124.3 | 424.7 | 93.5 | 100.9 | 91.7 | 121.9 | 108.4 | 102.9 | 127.0 | 121.7 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | - | 38.5 | 298.2 | 43.7 | 38.6 | 56.5 | 89.5 | 84.0 | 61.0 | 59.2 | 204.8 |
| ចំណូលជាមូលធន | 152.0 | 377.4 | 4.5 | 79.3 | 4.0 | 7.0 | 9.8 | 8.4 | 10.4 | 10.2 | 4.8 | 104.5 |
| ចំណាយសរុប | 3295.0 | 4174.7 | 1689.7 | 6297.8 | 1650.6 | 1766.1 | 2089.5 | 1877.1 | 2129.4 | 2154.8 | 2390.3 | 1945.4 |
| ចំណាយជាមូលធន | 1328.0 | 1638.1 | 807.4 | 2574.4 | 693.6 | 607.1 | 759.2 | 634.9 | - | 913.0 | 887.0 | 675.6 |
| ចំណាយចរន្ត | 1967.0 | 2536.8 | 882.3 | 3809.0 | 752.4 | 1064.7 | 1290.4 | 1332.3 | 831.8 | 1168.1 | 1503.3 | 1269.8 |
| បៀវត្សរ៍ | 711.0 | 822.0 | 362.6 | 1397.0 | 327.4 | 515.5 | 526.6 | 642.5 | - | 545.6 | 562.4 | 567.4 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | 194.2 | 927.1 | 217.3 | 185.9 | 272.6 | 195.6 | 213.3 | 253.2 | 401.5 | 231.4 |
| ចំណាយចរន្តផ្សេងទៀត | - | - | 325.5 | 1384.9 | 207.7 | 363.2 | 491.2 | 494.3 | 449.6 | 369.3 | 539.4 | 471.0 |
| សមតុល្យជាទូទៅ | -706.0 | -915.6 | -543.6 | -1007.8 | -548.9 | -513.4 | -904.8 | 90.2 | -592.6 | -813.7 | -954.2 | -207.3 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1127.0 | 1360.7 | 741.5 | 2055.1 | 507.8 | 326.7 | 484.5 | -531.0 | 270.8 | 746.0 | 409.1 | 419.3 |
| ហិរញ្ញប្បទានក្នុងស្រុក | -396.0 | -445.1 | -185.8 | -127 | -310.3 | 236.5 | 316.4 | 406.4 | 422.8 | 194.1 | 343.3 | -21.6 |

*Source: MEF website.*

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៤-១០

| | 2004 | 2005 | 2006 | 2007 | 2008 | 2009 | 2010 | | | | 2011 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 3.9 | 5.8 | 4.7 | 5.8 | 19.7 | -0.7 | 7.0 | 4.1 | 1.8 | 3.3 | 3.6 | 6.3 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 6.4 | 8.6 | 6.4 | 9.9 | 33.1 | -0.3 | 7.8 | 3.6 | 1.9 | 4.1 | 3.9 | 7.6 |
| - ដឹកជញ្ជូន | 9.7 | 11.4 | 9.1 | 5.8 | 19.4 | -10.7 | 12.9 | 8.7 | 3.2 | 3.1 | 5.0 | 7.3 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4016.3 | 4119.7 | 4119.0 | 4062.7 | 4058.2 | 4140.5 | 4180.1 | 4209.0 | 4236.7 | 4122.6 | 4041.9 | 4044.9 |
| រៀលក្នុង ១ បាតថៃ | 99.9 | 102.6 | 108.7 | 122.8 | 123.5 | 121.2 | 127.0 | 129.9 | 138.3 | 137.3 | 132.7 | 133.8 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.5 | 25.8 | 25.1 | 25.0 | 24.8 | 23.4 | 22.3 | 22.1 | 21.4 | 21.1 | 19.9 | 19.6 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 54.0 | 70.6 | 83.2 | 105.9 | 118.3 | 133.9 | 142.9 | 147.8 | 165.7 | 147.9 | 181.5 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 2088.0 | 2633.0 | 3140.0 | 3262.3 | 4555.2 | 3294.9 | 3599.5 | 3835.1 | 3936.6 | 4066.1 | 4427.2 | 4784.6 |
| ថ្លៃសាំង (រៀល/លីត្រ) | 2833.0 | 3442.0 | 4004.0 | 4005.0 | 4750.8 | 3469.1 | 4163.0 | 4358.7 | 4415.5 | 4535.2 | 4750.1 | 5065.5 |

*Sources: NIS, NBC and CDRI*

## តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៦-១១ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2006 | 2007 | 2008 | 2009 | | | | 2010 | | | | 2011 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 7224.0 | 10,735.0 | 10,345.0 | 11,222.0 | 12,611.0 | 13,869.0 | 14,655.0 | 15,514.6 | 12,610.9 | 16,903.0 | 16,697.9 | 17,079.1 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -282.0 | 576.0 | 1513.3 | 1266.0 | 1249.0 | 1042.0 | 1573.0 | 1720.0 | 1785.3 | 1984.8 | 2778.9 | 3199.2 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -953.0 | -1816.0 | -2987.0 | -3048.0 | -2889.0 | -2463.0 | -2252.0 | -2484.8 | -2362.7 | -2,120.4 | -2126.6 | -2252.7 |
| ឥណទានដល់ផ្នែកឯកជន | 3630.0 | 6386.0 | 9894.0 | 9814.0 | 10,129.0 | 10,127.0 | 10,532.0 | 11,146.7 | 11,859.1 | 12,479.8 | 13,331.2 | 13,909.0 |
| រូបិយវត្ថុទូទៅ M2 | 6942.0 | 11,311.0 | 11,858.0 | 12,488.0 | 13,859.0 | 14,912.0 | 16,228.0 | 17,234.5 | 18,267.1 | 18,887.8 | 19,476.8 | 20,278.3 |
| រូបិយវត្ថុ M1 | 1658.0 | 2052.0 | 2399.0 | 2545.0 | 2695.0 | 2773.0 | 3120.0 | 3148.5 | 3115.1 | 3061.7 | 3220.9 | 3497.2 |
| រូបិយវត្ថុផ្សេងៗ | 5285.0 | 9259.0 | 9459.0 | 9942.0 | 11,164.0 | 12,139.0 | 13,108.0 | 14,086.0 | 15,152.0 | 15,826.1 | 16,255.9 | 16,781.1 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 38.1 | 62.9 | 4.8 | 3.7 | 9.1 | 18.7 | 36.9 | 38.0 | 31.8 | 26.7 | 20.0 | 17.7 |
| រូបិយវត្ថុ M1 | 25.3 | 23.8 | 16.9 | 6.5 | 9.2 | 18.7 | 30.1 | 23.7 | 15.6 | 10.4 | 3.2 | 11.1 |
| រូបិយវត្ថុផ្សេងៗ | 42.8 | 75.2 | 2.2 | 2.9 | 9.1 | 18.7 | 38.6 | 41.7 | 35.7 | 30.4 | 24.0 | 19.1 |

*Source: National Bank of Cambodia*

## តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2006 | 2007 | 2008 | 2009 | 2010 | | 2011 | | | 2011 | | |
| | | | | | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកធាក់ស៊ីក្លូ | 7469 | 8075 | 12,628 | 8091 | 8404 | 8759 | 10,633 | 8,292 | 9,783 | 13.0 | -13.4 | 16.4 |
| អ្នកលីសែង | 6545 | 8588 | 9005 | 9549 | 10,525 | 9965 | 11,184 | 9861 | 10,465 | 12.4 | 5.6 | -0.6 |
| អ្នកលក់បន្លែតូចតាច | 6390 | 8220 | 9926 | 8273 | 8291 | 8821 | 9149 | 8599 | 8405 | 16.9 | 6.7 | 1.4 |
| អ្នករើសអេតចាយ | 4416 | 5422 | 4652 | 5857 | 6461 | 6628 | 6931 | 8661 | 7557 | 11.1 | 16.9 | 17.0 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 4412 | 4482 | 4327 | 4646 | 6427 | 5448 | 6154 | 6066 | 5410 | 19.9 | 12.7 | -15.8 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 5306 | 5516 | 8697 | 6197 | 6186 | 4912 | 4806 | 5984 | 7345 | -10.3 | -4.4 | 18.7 |
| កម្មកររោងចក្រកាត់ដេរ | 7649 | 7568 | 6554 | 7085 | 8470 | 7944 | 8312 | 7950 | 8687 | 10.0 | 6.1 | 2.6 |
| អ្នករត់ម៉ូតូឌុប | 8201 | 10,634 | 15,691 | 10,685 | 10,558 | 10,278 | 11,444 | 10,630 | 11,146 | 1.3 | 3.5 | 5.6 |
| កម្មករសំណង់គ្មានជំនាញ | 5918 | 6155 | 8779 | 8343 | 8744 | 9636 | 11,291 | 9415 | 10,526 | 46.7 | 4.5 | 20.4 |
| កម្មករសំណង់មានជំនាញ | 10,316 | 11,154 | 12,710 | 12,487 | 11,738 | 12,122 | 12,487 | 12,368 | 12,676 | 4.7 | 3.7 | 8.0 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

## Cambodia Development Review—2011 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

❒ Thailand, Laos, Vietnam ❒ English edition ($25)* ❒ Khmer edition ($15)*
❒ Asia and Europe ❒ English edition ($30)* ❒ Khmer edition ($20)*
❒ Americas and Africa ❒ English edition ($35)* ❒ Khmer edition ($25)*

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to:
Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❒Mr ❒Ms ❒Dr ❒ Other ..........
First name: .......... Last name: .......... Position: ..........
Organisation / Company: ..........
Address (CCC Box if applicable): ..........
City / Province: .......... Country: ..........
Telephone: .......... Fax: ..........
e-mail: .......... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

*តពីទំព័រ ២៨* **ព័ត៌មានថ្មីៗ...**

យុទ្ធសាស្ត្រឆ្នាំ២០១១-១៥ និងយុទ្ធសាស្ត្រស្រាវជ្រាវប្រទេសកម្ពុជាឆ្នាំ២០២០ របស់ CDRI និង កំណត់ពីបញ្ហាផ្សេងៗខាងស្ថាប័នដែលត្រូវយកចិត្តទុកដាក់ជាអាទិភាពនៅឆ្នាំក្រោយ។

## ផ្នែកស្រាវជ្រាវ

**កម្មវិធីអភិបាលកិច្ចបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ**

គម្រោងសិក្សាស្រាវជ្រាវចំនួន ៥ បានបញ្ចប់ជាស្ថាពរ៖ (១) គម្រោង "ការពិនិត្យពីសមត្ថភាពធម្មតារបស់រដ្ឋនៅកម្ពុជានៅពេលសេដ្ឋកិច្ចកំពុងផ្លាស់ប្តូរ" ដើម្បីវាយតម្លៃពីសមត្ថភាពរបស់រដ្ឋនាពេលបច្ចុប្បន្ន។ (២) គម្រោង "អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យក្នុងប្រព័ន្ធនយោបាយបែបកូនកាត់៖ ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) នៅប្រទេសកម្ពុជា" ដើម្បីកំណត់ពីនិន្នាការ និងអនាគតនៃកំណែទម្រង់ D&D ក្នុងបរិបទប្រទេសកម្ពុជាដែលមានប្រព័ន្ធទាំងពីរនៅលាយឡំគ្នា និងស្វែងរកចម្លើយថា តើ D&D ជួយពង្រឹងរបបប្រជាធិបតេយ្យនៅកម្ពុជាដែរឬទេ។ (៣) គម្រោង "អង្កេតមូលដ្ឋានអំពីរដ្ឋបាលថ្នាក់ក្រោមជាតិ៖ ការស្វែងយល់ឲ្យបានកាន់តែប្រសើរពីកំណែទម្រង់ D&D នៅកម្ពុជា" ដើម្បីស្រាវជ្រាវពីចំណាប់អារម្មណ៍ និងការយល់ដឹងរបស់សមាជិកក្រុមប្រឹក្សាឃុំអំពី រដ្ឋបាលថ្នាក់ស្រុក និងខេត្ត (ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក និងខេត្ត) និង ការយល់ដឹងរបស់ថ្នាក់ស្រុក និងខេត្តអំពីក្រុមប្រឹក្សាឃុំវិញ។ (៤) គម្រោង "អភិបាលកិច្ចដែនរងទឹកភ្លៀង និងបញ្ហាចោទក្នុងកិច្ចសហប្រតិបត្តិការ៖ ករណីសិក្សានៅកម្ពុជា" ដើម្បីពិនិត្យពីកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធនានាក្នុងបរិបទកំណែទម្រង់ D&D និង (៥) "អភិបាលកិច្ចតាមបែបវិមជ្ឈការនៃទឹកស្រោចស្រពនៅប្រទេសកម្ពុជា៖ ការផ្គូផ្គងគោលការណ៍ ទៅនឹងស្ថានភាពជាក់ស្តែងនៅមូលដ្ឋាន" ដើម្បីពិនិត្យពីកម្រិតស៊ីគ្នារវាងរបៀបរៀបចំអភិបាលកិច្ច និងតម្រូវការចាំបាច់នៃប្រព័ន្ធធារាសាស្ត្រទាំងនោះ។ អត្ថបទសង្ខេបគោលនយោបាយជាភាសាខ្មែរ និងអង់គ្លេសផ្អែកលើការសិក្សាទី២ ទី៤ និង ទី៥ បានបោះពុម្ព និងចែកចាយរួចរាល់ហើយ។

បច្ចុប្បន្ន ក្រុមស្រាវជ្រាវ កំពុងកំណត់នូវគោលគំនិតធំៗសម្រាប់ការសិក្សាចំនួន ៥ គឺ៖ (១) ផលប៉ះពាល់នៃ D&D លើការកាត់បន្ថយភាពក្រីក្រ (២) ការធ្វើវិមជ្ឈការសារពើពន្ធ និងហេដ្ឋារចនាសម្ព័ន្ធ (៣) បដិការរវាងរដ្ឋ និងសង្គម (៤) ទំនាក់ទំនងរវាងឃុំ និងស្រុក និង (៥) វិមជ្ឈការតាមវិស័យ៖ ករណីសិក្សាក្នុងវិស័យអប់រំ និងសុខាភិបាល។

សិក្ខាសាលាផ្សព្វផ្សាយព័ត៌មានប្រចាំឆ្នាំ បានធ្វើឡើងកាលពីថ្ងៃទី ១៨-១៩ តុលា នៅរាជធានីភ្នំពេញ ដោយមានមន្ត្រីរាជការប្រមាណ ២៨០នាក់ មកចូលរួម ដែលភាគច្រើនមកពីរដ្ឋបាលថ្នាក់ក្រោមជាតិ។

**កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់**

គម្រោង "អង្កេតពលករងាយរងគ្រោះ" និង "អង្កេតថ្លៃទំនិញតាមខេត្ត" កំពុងលូតលាស់ទៅមុខយ៉ាងល្អ។ របាយការណ៍ស្តីពី "ចរន្តពលករខុសៗគ្នា តម្រូវការ និងផលប៉ះពាល់ខុសៗគ្នា៖ ការគ្រប់គ្រងទេសន្តរប្រវេសន៍ពលកម្មអន្តរជាតិនៅអាស៊ាន" កំពុងរៀបចំសម្រាប់ការបោះពុម្ពជាសៀវភៅសិក្សាលំអិតមួយ របស់វិទ្យាស្ថានហ្វីលីពីនសិក្សាពីអភិវឌ្ឍន៍ (PIDS) និងជាឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI។ របាយការណ៍ស្តីពី "ទំនាក់ទំនងរវាងភាពក្រីក្រ និងបរិស្ថាន៖ ករណីសិក្សានៅតំបន់ជនបទកម្ពុជា" និង "ការវិភាគពីវិនិយោគអន្តរជាតិក្នុងវិស័យកសិកម្មនៅកម្ពុជា" កំពុងរៀបចំសម្រាប់ការបោះពុម្ពជាឯកសារពិភាក្សារបស់ CDRI។

របាយការណ៍ព្រាងដំបូងរបស់សមាសភាគទីបី នៃគម្រោង "បណ្តាញភាពក្រីក្រ" ដែលទទួលហិរញ្ញប្បទានពី ADB បានចប់សព្វគ្រប់ ហើយលទ្ធផលស្រាវជ្រាវបឋមបានយកទៅលើកបង្ហាញនៅក្នុងសិក្ខាសាលាថ្នាក់តំបន់ នាទីក្រុងហ្សាការតានៃប្រទេសឥណ្ឌូនេស៊ី កាលពីខែតុលា។ របាយការណ៍ព្រាងដំបូងសម្រាប់គម្រោង "ការវិភាគពីភាពក្រីក្រពុំរ៉ៃនៅជនបទកម្ពុជា៖ ភស្តុតាងបានពីទិន្នន័យអង្កេតជាបន្តបន្ទាប់ (panel data)" កំពុងបន្តរៀបចំ។ ឯកសារព្រាងដំបូងស្តីពី "ការធ្វើរោគវិនិច្ឆ័យលើកំណើនដំណាក់កាលទីពីរ" កំពុងពិនិត្យ និងកែសម្រួល។ របាយការណ៍ព្រាងចុងក្រោយស្តីពី "អាស៊ាន ឆ្នាំ២០៣០៖ ឯកសារសាវតាកម្ពុជា" បានចប់សព្វគ្រប់។ បន្ទាប់ពីបានធ្វើសិក្ខាសាលាផ្នែកគោលនយោបាយ កាលពីថ្ងៃទី៩ សីហា នៅរាជធានីភ្នំពេញ ក្រុមស្រាវជ្រាវបានយកលទ្ធផលសំខាន់ៗនៃគម្រោងសិក្សា "គោលនយោបាយគាំទ្រសហគ្រាសធុនតូច និងមធ្យម" ទៅបង្ហាញ នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង កាលពីខែតុលា ២០១១។

សិក្ខាសាលារបស់បណ្តាញវិភាគអភិវឌ្ឍន៍ នៃមហាអនុតំបន់មេគង្គ (GMS-DAN) ស្តីពី "កិច្ចសហប្រតិបត្តិការស្រាវជ្រាវលើកំណើនមានការរាប់បញ្ចូល និងសមាហរណកម្មក្នុងតំបន់ GMS: មេរៀនទទួលបានពី GMS-DAN 8 និងមាគ៌ាឆ្ពោះទៅមុខ" បានធ្វើឡើងកាលពីថ្ងៃទី៣០ សីហា នៅទីក្រុងបាងកក ហើយសំណើស្តីពី "ការកសាង និងការពង្រឹង GMS-DAN 2011-2014 ឲ្យមាននិរន្តរភាព៖ កិច្ចសហការស្រាវជ្រាវសម្រាប់គោលនយោបាយស្តីពី កំណើនមានការរាប់បញ្ចូល និងសមាហរណកម្មថ្នាក់ក្រោមជាតិក្នុង GMS" បានកែសម្រួលរួចរាល់ និងផ្ញើជូនមូលនិធិ Rockefeller និង មជ្ឈមណ្ឌលស្រាវជាវអភិវឌ្ឍន៍អន្តរជាតិ (IDRC)។ CDRI ក៏បានរៀបចំសិក្ខាសាលាលើកទី២ ស្តីពី "វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល និងភាពងាយរងគ្រោះនៅកម្ពុជា" កាលពីថ្ងៃទី៣ តុលា ហើយដែរ ។

វេទិកាស្រាវជ្រាវអភិវឌ្ឍន៍ឆ្នាំ២០១១ ដែលធ្វើឡើងកាលពីថ្ងៃទី ៨-៩ កញ្ញា សម្រេចបានលទ្ធផលយ៉ាងល្អ។ សំណើសម្រាប់វគ្គទី២ កំពុងពិនិត្យកែសម្រួលដើម្បីដាក់ជូន IDRC។ កាលពីថ្ងៃទី២២ សីហា ដល់ថ្ងៃទី ៧ កញ្ញា ដោយទទួលបានការគាំទ្រពីគណៈកម្មាធិការបម្រើក្វេគ័រអាមេរិកកាំង (American Friend Service Committee-AFSC) និងជាផ្នែកមួយនៃកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ (Exchange Program) រវាង CDRI និងបណ្ឌិតសភាចិន ផ្នែកវិទ្យាសាស្ត្រសង្គមនោះ ក្រុមអ្នកស្រាវជ្រាវរបស់ CDRI បានទៅសិក្សាដល់កន្លែងមួយនៅទីក្រុងប៉េកាំង ដើម្បី

ស្រាវជ្រាវពីបទពិសោធន៍អភិវឌ្ឍន៍របស់ចិន ជាពិសេសការកាត់បន្ថយភាពក្រីក្រ។

គម្រោងស្រាវជ្រាវថ្មីចំនួន៣ ទទួលបានការយល់ព្រមពីម្ចាស់ជំនួយគឺ (១) គម្រោង "ចង្កោមឧស្សាហកម្ម សមាគមពាណិជ្ជកម្ម និងផលិតភាពរបស់ សហគ្រាសធុនតូច និងមធ្យម៖ ភស្តុតាងអង្កេតសហគ្រាសនៅកម្ពុជា (ARTNeT)" (២) គម្រោង "តើកំណើនមានការរាប់បញ្ចូលជួបឧបសគ្គអ្វីខ្លះ? (ARTNeT)" និង (៣) គម្រោង "ការវាយតម្លៃឆាប់រហ័សពីផលប៉ះពាល់នៃកំណើនថ្លៃអាហារលើជនក្រីក្រ និងក្រុមងាយរងគ្រោះ និងគោលនយោបាយឆ្លើយតបនៅកម្ពុជា (វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល)។

## កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន

គម្រោងស្រាវជ្រាវធំៗចំនួន២ គឺ "កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក" និង "ព្រៃត្រូពិចសម្រាប់ការកាត់បន្ថយភាពក្រីក្រ-ការវិភាគទិន្នន័យ តាំងពីកម្រិតគ្រួសារដល់កម្រិតសាកល" បានចប់សព្វគ្រប់។ របាយការណ៍ពេញលេញសម្រាប់គម្រោងទាំងពីរនេះ បានបញ្ចប់ និងបោះពុម្ពរួចរាល់។ គម្រោង "ការពិនិត្យតាមដានផលប៉ះពាល់សង្គម និងអង្កេតមូលដ្ឋានវាយតម្លៃភាពងាយរងគ្រោះ" កំពុងដំណើរការទៅមុខ និងព្យាយាមស្វែងយល់ពី កម្រិតពឹងផ្អែកលើធនធានទឹកនៃប្រជាជនជនបទ នៅតាមដងទន្លេមេគង្គមួយកន្លែងប្រវែង១៥គ.ម ដើម្បីជួយបញ្ជាក់បន្ថែមដល់ការវាយតម្លៃពីភាពងាយរងគ្រោះ និងផលប៉ះពាល់ខាងសង្គម នៅក្នុងគំនិតផ្តួចផ្តើមសិក្សារបស់គណៈកម្មការទន្លេមេគង្គ ស្តីពីការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ របាយការណ៍ព្រាងដំបូងកំពុងកែសម្រួលផ្អែកលើយោបល់ត្រឡប់ បន្ទាប់ពីការធ្វើបទបង្ហាញនៅក្នុងសិក្ខាសាលាបច្ចេកទេសនៅទីក្រុងលួងប្រាបាង នៃប្រទេសឡាវ។ របាយការណ៍កែសម្រួល បានយកទៅបង្ហាញក្នុងសិក្ខាសាលាថ្នាក់ជាតិនៅខេត្តសៀមរាប នៅខែវិច្ឆិកា។ គម្រោង "កសិកម្ម និងការប្រែប្រួលអាកាសធាតុ ដែលជាគម្រោងអនុវត្តរួមគ្នាជាមួយកម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ និងទទួលបានហិរញ្ញប្បទានពី USAID តាមរយៈ វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI) ធ្វើការវិភាគពីសន្តិសុខស្បៀង និងការអភិវឌ្ឍកសិកម្ម ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ ដោយកំណត់ពីឧបសគ្គក្នុងការលើកកម្ពស់ទិន្នផល និងសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ។ របាយការណ៍នេះ កំពុងរៀបចំបញ្ចប់ដោយដាក់បញ្ចូលយោបល់ទទួលបានពីសិក្ខាសាលាថ្នាក់ជាតិនៅខេត្តសៀមរាប កាលពីថ្ងៃទី ២២-២៣ ខែសីហា។

ការសិក្សាថ្មីមួយស្តីពី "ផលប៉ះពាល់ និងភាពធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ៖ ករណីប្រព័ន្ធធារាសាស្ត្រ ការប្រើប្រាស់ដី ការប្រែប្រួលរបបទឹកភ្លៀង និងអភិបាលកិច្ចទឹក" ដែលជាគម្រោងអនុវត្តរួមគ្នាជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) កំពុងចាប់ដំណើរការ។ គម្រោងនេះ សំដៅស្វែងយល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើជលសាស្ត្រ និងការឆ្លើយតបផ្អែកអភិបាលកិច្ច ទៅនឹងការប្រែប្រួលក្នុងសន្តិសុខស្បៀង។ គម្រោងស្រាវជ្រាវថ្មីមួយទៀតស្តីពី "ការពង្រឹងអភិបាលកិច្ចធនធានជលផល (STARGO)" មានគោលដៅលើកកម្ពស់អភិបាលកិច្ចលើ ធនធានជលផល ដែលប្រឈមនឹងការប្រជែងដណ្តើមយក និងជួយគាំទ្រដល់គម្រោង និងអន្តរាគមន៍នានាសំដៅកែលម្អអាហារូបត្ថម្ភ ប្រាក់ចំណូល សុខុមាលភាព និងសន្តិសុខសង្គម។ គម្រោងស្រាវជ្រាវនេះ អនុវត្តឡើងដោយមានការសម្របសម្រួលពីមជ្ឈមណ្ឌលមច្ឆាពិភពលោក និងវិទ្យាស្ថានស្រាវជ្រាវ Adelphi (ទីក្រុងប៊ែឡាំង ប្រទេសអាល្លឺម៉ង់) និងទទួលបានហិរញ្ញប្បទានពី BMZ (ក្រសួងសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហព័ន្ធ នៃប្រទេសអាល្លឺម៉ង់)។

## កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ

កម្មវិធីនេះ កំពុងអនុវត្តគម្រោងស្រាវជ្រាវចំនួន ៦។ របាយការណ៍ព្រាងស្តីពី "ការវាយតម្លៃពីផលប្រយោជន៍នៃអង្គការកសិករចំពោះសន្តិសុខស្បៀងរបស់ជនក្រីក្រនៅជនបទ" បានផ្ញើជូនធនាគារពិភពលោក និង AusAID ពិនិត្យ ហើយការជួយមតិផ្សេងៗក៏បានដោះស្រាយរួចរាល់ដែរ។ គម្រោងស្តីពី "ការកសាងវិធីសាស្ត្រវាយតម្លៃផលប៉ះពាល់ សម្រាប់សកម្មភាពដោះមីននៅកម្ពុជា" ត្រូវបានពង្រីករយៈពេលថែមទៀត។ ជំហានទី២ នៃគម្រោងនេះ គឺមានការធ្វើតេស្តលើឧបករណ៍វាយតម្លៃផលប៉ះពាល់ដែលបានដាក់ស្នើឡើង ក៏ដូចជាការប្រមូលទិន្នន័យបឋម និងការវិភាគទិន្នន័យដែលបានចប់សព្វគ្រប់ ហើយនិងរបាយការណ៍ដែលកំពុងតាក់តែង។ សម្រាប់គម្រោងស្រាវជ្រាវរយៈពេល៣ឆ្នាំ ស្តីពី "គោលនយោបាយកសិកម្ម សម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវនៅប្រទេសកម្ពុជា និងឡាវ" ផ្តល់ហិរញ្ញប្បទានដោយ មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ក្រុមស្រាវជ្រាវកំពុងពិនិត្យឡើងវិញនូវការសិក្សានានាដែលធ្លាប់មានពីមុន និងរៀបចំឧបករណ៍ស្រាវជ្រាវផ្សេងៗ សម្រាប់ផែនការស្រាវជ្រាវឆ្នាំដំបូង។ របាយការណ៍ព្រាងដំបូងនៃគម្រោងស្តីពី "ការលើកកម្ពស់សមភាពយេនឌ័រនៅទីផ្សារពលកម្ម ដើម្បីឲ្យកំណើនអាចផ្តល់ផលចំណេញដល់ទាំងអស់គ្នា" បានចប់សព្វគ្រប់ និងផ្ញើជូនទៅទីប្រឹក្សាអន្តរជាតិ ADB ដើម្បីពិនិត្យ និងផ្តល់យោបល់។ របាយការណ៍ព្រាងចុងក្រោយនៃគម្រោងស្រាវជ្រាវ ស្តីពី "ធនាគារគាំទ្រសហគ្រាសធុនតូច និងមធ្យម" បានប្រគល់ជូនទៅម្ចាស់ជំនួយ ហើយក្រុមស្រាវជ្រាវបានធ្វើបទបង្ហាញពីរបាយការណ៍នេះនៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង កាលពីថ្ងៃទី ៩-១៣ តុលា។ គម្រោង "ការសិក្សាកំណត់តម្លៃសេវានៃក្រុមប្រឹក្សាអាជ្ញាកណ្តាល" ផ្តល់មូលនិធិដោយធនាគារពិភពលោក ចាប់ផ្តើមអនុវត្ត នៅចុងខែវិច្ឆិកា។

## កម្មវិធីអភិវឌ្ឍន៍សង្គម

កម្មវិធីនេះកំពុងអនុវត្តគម្រោងចំនួន ៤។ គម្រោង EQUITAP[១] សម្របសម្រួលដោយ វិទ្យាស្ថានសម្រាប់គោលនយោបាយសុខាភិបាល នៅប្រទេសស្រីលង្កា និងផ្តល់មូលនិធិដោយ AusAID/IDRC មានគោលដៅវាយតម្លៃពី (១) ផលប៉ះពាល់ផ្សេងៗដែលធ្វើឲ្យចុះក្រ និងជួបមហន្តរាយ លក្ខណៈជឿនលឿន

ភាពខុសគ្នាក្នុងការប្រើប្រាស់សេវាថែទាំសុខភាព និង (២) អត្ថប្រយោជន៍ទទួលបានពីចំណាយរដ្ឋាភិបាល។ លទ្ធផលដំបូងនៃការវិភាគលើផ្នែកទី១ នៃគម្រោងនេះ អ្នកសម្របសម្រួលគម្រោង បានពិនិត្យឡើងវិញ និងយល់ស្របហើយ រីឯផ្នែកទី២ គ្រោងបញ្ចប់នៅខែធ្នូ ២០១១។

គម្រោងស្រាវជ្រាវរយៈពេល៦ឆ្នាំ ស្តីពី "ការកសាងប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញ បន្ទាប់ពីបានបញ្ចប់ទំនាស់" ឬហៅកាត់ថា "REBUILD" ផ្តល់មូលនិធិដោយ DFID-UK និងដឹកនាំដោយ Liverpool School of Tropical Medicine និង Queen Margaret University នៃចក្រភពអង់គ្លេសនោះ ជិតដល់ចុងឆ្នាំសម្រាប់កសាងគោលគំនិតនោះហើយ។ ដោយមានគោលដៅចម្បងស្វែងរកភស្តុតាងមានគុណភាពខ្ពស់ ដើម្បីចូលរួមចំណែកជួយលើកកម្ពស់សុខភាពជនក្រីក្រខ្លាំងក្នុងប្រទេសកំពុងអភិវឌ្ឍន៍នោះ ពិធីសារស្រាវជ្រាវចំនួន៣ ត្រូវបានបង្កើតឡើង៖ (១) ផលប៉ះពាល់នៃការផ្លាស់ប្តូរគោលនយោបាយផ្តល់ហិរញ្ញប្បទានផ្នែកសុខាភិបាល ទៅលើលំនាំចំណាយលើការថែទាំសុខភាពរបស់គ្រួសារក្រីក្រនៅជនបទកម្ពុជា៖ ការវិភាគពីចំណាយគ្រួសារលើបញ្ហាសុខភាព (២) គោលនយោបាយទាក់ទាញ និងរក្សាបុគ្គលិកសុខាភិបាលឲ្យធ្វើការនៅតំបន់ជនបទ៖ ការពិនិត្យឡើងវិញពីកត្តាជំរុញផ្នែកគោលនយោបាយ ការអនុវត្ត និងប្រសិទ្ធភាពគោលនយោបាយក្រោយការបញ្ចប់ទំនាស់នៅកម្ពុជា និង (៣) គំរូកិច្ចសន្យា និងការគ្រប់គ្រងលទ្ធផលការងារនៅកម្ពុជា។ កាលពីខែកញ្ញា ក្រុមស្រាវជ្រាវ បានធ្វើបទបង្ហាញពីពិធីសារស្រាវជ្រាវទាំងបីនេះ ជូនដល់ក្រុមការងារបច្ចេកទេសផ្នែកសុខភាព នៃក្រសួងសុខាភិបាល ដើម្បីទទួលយោបល់ត្រឡប់លើសំណួរ និងវិធីសាស្ត្រស្រាវជ្រាវ ពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗ។ នាបច្ចុប្បន្ន ក្រុមស្រាវជ្រាវ កំពុងរៀបចំត្រៀមទៅចូលរួមការប្រជុំសមាគម នៅទីក្រុងកំប៉ាឡា ប្រទេសអ៊ូហ្គង់ដា នៅដើមខែវិច្ឆិកានេះ។

គម្រោងស្តីពី "ស្ថានភាពមូលធនសង្គមនៅកម្ពុជា" ផ្តល់មូលនិធិដោយ Senshu University នៃប្រទេសជប៉ុន មានគោលដៅពិនិត្យពីភាពជាក់ស្តែង និងសក្តានុពលនៃមូលធនសង្គមទាក់ទងនឹង៖ (១) ស្ថានភាព និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន (២) សំណាញ់សុវត្ថិភាពសង្គម និង (៣) ទំនៀមទម្លាប់ បែបបទ និងក្រឹត្យក្រមសង្គម។ វគ្គបណ្តុះបណ្តាលអ្នកចុះធ្វើអង្កេតបានអនុវត្តរួចរាល់ ហើយកម្រងសំណួរក៏បានធ្វើតេស្តសាកល្បងស្រេចបាច់។ ការចុះសិក្សាដល់កន្លែងក្នុងខេត្តព្រៃវែង និងសៀមរាប គ្រោងចប់សព្វគ្រប់នៅចុងខែតុលា។

គម្រោង "មាគ៌ាឈានទៅផ្តល់សេវាសុខភាពឲ្យបានជាទូទៅនៅកម្ពុជា" ដែលជាកិច្ចសហការស្រាវជ្រាវជាមួយវិទ្យាស្ថាន Nossal Institute for Global Health នៃសាកលវិទ្យាល័យមែលប៊ន ប្រទេសអូស្ត្រាលីនោះ មានបំណងកំណត់ពីឧបសគ្គផ្នែកគោលនយោបាយ ធនធាន និងបរិបទនៅកម្ពុជា ដើម្បីផ្តល់ព័ត៌មានដល់ការពិភាក្សាគោលនយោបាយនៅកម្ពុជា និងផ្តល់យោបល់ពីមធ្យោបាយឈានទៅមុខ។ អ្នកស្រាវជ្រាវគម្រោងនេះ នឹងទៅចូលរួមក្នុងកិច្ចប្រជុំអំពីគម្រោង នៅប្រទេសអូស្ត្រាលី ក្នុងខែតុលា។

ការបោះពុម្ពផ្សាយជាអន្តរជាតិមួយរបស់ CDRI មានចំណងជើងថា "ការលើកកម្ពស់លទ្ធផលក្នុងវិស័យសុខាភិបាល៖ ស្ថាប័ន សន្ទុះចិត្ត និងការលើកទឹកចិត្ត-ការពិភាក្សានៅកម្ពុជា" បានអនុវត្តរួចរាល់ដោយ វិទ្យាស្ថានសិក្សាពីអាស៊ីអាគ្នេយ៍ និងបានបញ្ជូនមកដល់ CDRI ហើយ។ នាបច្ចុប្បន្ន សៀវភៅនេះមានដាក់លក់នៅលើទីផ្សារ និងបានចែកជូនដល់អ្នកនិពន្ធនានា និងដល់គ្រប់ៗគ្នា ដែលបានចូលរួមក្នុងសិក្ខាសាលាសុខភាពអន្តរជាតិ កាលពីខែមេសា ២០១០ នៅទីក្រុងភ្នំពេញ និងបានផ្ញើជូនបណ្ណាល័យនានានៅកម្ពុជាផងដែរ។

១ EQUITAP (Equity in Asia-Pacific Health System: សមធម៌ក្នុងប្រព័ន្ធសុខាភិបាលនៅអាស៊ីប៉ាស៊ីហ្វិក) ជាកិច្ចប្រឹងប្រែងរួមគ្នារបស់អ្នកស្រាវជ្រាវ ១៥ក្រុម នៅអាស៊ី និងអឺរ៉ុប ដើម្បីពិនិត្យពីសមធម៌ក្នុងប្រព័ន្ធសុខាភិបាលជាតិនានា នៅអាស៊ី-ប៉ាស៊ីហ្វិក។ កិច្ចសហការណ៍នេះ រួមមាន ការកសាងឧបករណ៍សម្រាប់ស្រាវជ្រាវ និងការវាយតម្លៃជាក់ស្តែងលើការអនុវត្តប្រព័ន្ធសុខាភិបាលនានា។




Special Report 12: **A Baseline Survey of Sub-national Governments: Towards a Better Understanding of Decentralisation and Deconcentration in Cambodia** *by Chheat Sreang, Lun Pide, Kim Sedara, Heng Seiha, Sok Sethea and Chhoun Nareth*

The first election to appoint district and provincial councils in May 2009 offers communes the opportunity to choose councillors from whom they can demand accountability, and introduces a new relationship between commune councillors and higher councils. The main goal of this survey is to gauge the view of commune councillors, district councillors and district boards of governors on accountability, fiscal assignment, service delivery, division of labour between the commune and district, gender issues, unified administration and the reform generally. Despite some divergence, there is now a strong consensus that the reforms have improved local livelihoods, strengthened local leadership and changed the way local and sub-national public business is conducted.

*Special Report 12 in English, 88 p. 2011* *Local: $3.00*

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ផ្នែកគ្រប់គ្រង

វិទ្យាស្ថាន CDRI ដោយសហការជាមួយ វិទ្យាស្ថានកូរ៉េសម្រាប់គោលនយោបាយសេដ្ឋកិច្ចអន្តរជាតិ (Korean Institute for International Economic Policy) បានបើកដំណើរការវេទិកាស្ថាប័នអាស៊ីអាគ្នេយ៍ (East Asian Institutions Forum) លើកទី៧ នៅរាជធានីភ្នំពេញ នៅថ្ងៃទី៦-៧ តុលា ២០១១។ គឺជាលើកដំបូងបំផុតដែលវេទិកានេះ បានប្រារព្ធឡើងនៅក្រៅប្រទេសកូរ៉េខាងត្បូង ដោយមានប្រធានបទ សមាហរណកម្មសេដ្ឋកិច្ចអាស៊ីអាគ្នេយ៍៖ តួនាទីនៃសហប្រតិបត្តិការអភិវឌ្ឍន៍។ CDRI បានបញ្ចូលវគ្គមួយស្តីពី សហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ដែលសម្របសម្រួលដោយ ឯកឧត្តមបណ្ឌិត សុក ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថាន CDRI និង មានបទបង្ហាញរបស់ ឯកឧត្តមបណ្ឌិត ហាង ជួន ណារ៉ុន អតីតប្រធានក្រុមប្រឹក្សាភិបាល CDRI និង លោក Larry Strange នាយកប្រតិបត្តិនៃ CDRI។

នៅថ្ងៃទី៤ វិច្ឆិកា នាយកប្រតិបត្តិនៃ CDRI បានទៅចូលរួមការប្រជុំបំផុសគំនិតមួយ នៅទីស្នាក់ការកណ្តាលរបស់ធនាគារអភិឌ្ឍន៍អាស៊ី (ADB) នៅទីក្រុងម៉ានីល ទាក់ទងនឹងការកសាងគំនិតផ្តួចផ្តើមសំខាន់ថ្មីមួយរបស់វិទ្យាស្ថាន ADB នៃធនាគារ ADB ស្តីពី ការពង្រឹងបណ្តាប្រទេសមានសេដ្ឋកិច្ចអន្តរកាលក្នុងអាស៊ាន៖ ការស្រាវជ្រាវផ្តោតលើគោលនយោបាយ និងកម្មវិធីកសាងសមត្ថភាព។ លោកនាយកប្រតិបត្តិ បានធ្វើបទបង្ហាញស្តីពីតម្រូវការបណ្តុះបណ្តាល និងកសាងសមត្ថភាព-បទពិសោធន៍របស់ CDRI នៅកម្ពុជា៖ តើយើងទទួលបានចំណេះដឹងអ្វីខ្លះ?

នៅថ្ងៃទី២៥ ខែវិច្ឆិកា CDRI បានចូលរួមទទួលស្វាគមន៍ទស្សនកិច្ចមកកាន់ប្រទេសកម្ពុជា របស់លោកស្រី Charlotte Petri-Gornitzka នាយកទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (Sida) ដែលរួមមាន ការពិសាអាហារថ្ងៃត្រង់ មានការសំណេះសំណាលពិភាក្សាពីបញ្ហា យុវជន និងការងារនៅកម្ពុជា។ Sida ជាដៃគូផ្តល់ធនធានដ៏សំខាន់របស់ CDRI ដោយបានផ្តល់ជំនួយទ្រទ្រង់ដល់ការស្រាវជ្រាវ និងប្រតិបត្តិការនានាដែលមានចុះក្នុងផែនការយុទ្ធសាស្ត្រឆ្នាំ២០១១-២០១៥ របស់ CDRI។

នៅថ្ងៃទី៧-៩ ធ្នូ CDRI បានសហការណ៍ជាមួយមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិកាណាដា (IDRC) ដើម្បីទទួលស្វាគមន៍ទស្សនកិច្ចមកកម្ពុជារបស់លោក Rohinton Medhora អនុប្រធានក្រុមប្រឹក្សាភិបាលនៃ IDRC ហើយកម្មវិធីសំខាន់ៗរួមមាន ការផ្តល់ព័ត៌មានសង្ខេបនៅ CDRI ស្តីពី និន្នាការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចសំខាន់ៗ និងបញ្ហាផ្សេងៗនៅកម្ពុជា និងនៅមហាអនុតំបន់មេគង្គ និងការពិភាក្សាតុមូលជាមួយអ្នកតំណាងជាន់ខ្ពស់នៃដៃគូក្នុងប្រទេសនានា នៅក្នុងវេទិកាស្រាវជ្រាវអភិវឌ្ឍន៍ (DRF) នៅកម្ពុជា។ IDRC ផ្តល់ជំនួយទ្រទ្រង់ដល់បណ្តាញវិភាគអភិវឌ្ឍន៍នៃមហាអនុតំបន់មេគង្គ (GMS-DAN) ដែលសម្របសម្រួលដោយ CDRI និងកិច្ចប្រជុំ DRF ព្រមទាំងគម្រោងស្រាវជ្រាវគោលនយោបាយសំខាន់មួយ ដែលវិភាគពីផលប៉ះពាល់រយៈពេលមធ្យម និងវែង នៃវិបត្តិហិរញ្ញវត្ថុសាកល និងការធ្លាក់ចុះសេដ្ឋកិច្ច ទៅលើប្រទេសកម្ពុជា។

នៅថ្ងៃទី១៤-១៦ធ្នូវិទ្យាស្ថានCDRIបានរៀបចំកម្មវិធីសម្រាកដើម្បីពិចារណាប្រចាំឆ្នាំ នៅខេត្តព្រះសីហនុ ដើម្បីវាយតម្លៃ និងអបអរសាទរចំពោះសមិទ្ធផលសម្រេចបាននៅឆ្នាំ២០១១ និងបទពិសោធន៍ទទួលបានកន្លងមក ព្រមទាំងបញ្ជាក់អំពីសកម្មភាពជាអាទិភាពសម្រាប់អនុវត្តឆ្នាំ២០១២ សំដៅបន្តអនុវត្តផែនការ

(តទៅទំព័រ ២៥)

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ទស្សនាវដ្តី
អភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១៥ លេខ៤ ខែតុលា-ធ្នូ ឆ្នាំ២០១១

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិត ត្រូវចុះហត្ថលេខាអាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន ។ អ្នកនិពន្ធ ត្រូវទាក់ទង វបសអ មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
(៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ (៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@cdri.org.kh
website: http://www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសំរួលៈ យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួលៈ ខេង សេង និង អ៊ឹង សុជាតិ
រោងពុម្ពអង្គរអុហ្វសិត ភ្នំពេញ រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០១១ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ *វបសអ* ទេ ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រៈ http://www.cdri.org.kh